


ទស្សនាវដ្ដី

# ខេត្តព្រះវិហារ ២០២៣



# គំនូរបំព្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី ១» ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព ៖ កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០



# មាតិកា


★ អារម្ភកថា ..................................................................................................៣

★ ពិធីអេបអរសាទរ«រម្មណីយដ្ឋានប្រាសាទកោះកេរ»ចុះបញ្ជីក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក...............៤

★ អភិបាលខេត្តចុះសួរសុខទុក្ខកងទ័ព....................................................................................៦

★ ពិធីក្រុងពាលីលើកសសរព្រះវិហារ ៥០០ដើម.........................................................................៨

★ ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ....១០

★ បុណ្យកាត់ឫសសីមាសម្ពោធឆ្លងព្រះវិហារ......................................................................១២

★ កិច្ចប្រជុំបូកសរុបការងារឆ្នាំ២០២២របស់មន្ទីរបរិស្ថាន..........................................................១៤

★ យុទ្ធនាការគោយន្តមានភ្លើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍..........................................១៦

★ កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការលើកទី៩ រវាងខេត្តព្រះវិហារ ជាមួយខេត្តចម្ប៉ាសាក់.......................១៨

★ ពលរដ្ឋជាង ៦០០គ្រួសារ ទទួលបានបណ្ណសម្គាល់ម្ចាស់អចលនវត្ថុ.........................................២០

★ ក្រសួងបរិស្ថាន រៀបចំកម្មវិធីបោះដំរំ និងបំបួសដើមឈើ.........................................................២២

★ ពិធីស្រោចស្រពសុគន្ធវារី ជូនព្រះគ្រូអនុគណស្រុកឆែប.............................................................២៤

★ សិក្ខាសាលាស្តីពី«ដំណើរវិវឌ្ឍន៍របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន.........................................២៦

★ ពិធីសម្ពោធមន្ទីរពេទ្យព្យាបាល និងសម្តពម៉ាលីបុត្រ................................................................២៨

★ ការប្រកួតកីឡាប៊ូល និងប៉េតង់ពានរង្វាន់ស.ស.យ.ក..............................................................៣០

★ សមាគមន៍នារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តជួបសំណេះសំណាលជាមួយសិស្សានុសិស្ស...............៣២

★ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៣ ..........................................................................................៣៤

★ សន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម...............................................................................៣៦

★ ថៃ្ងចុះកិច្ចព្រមព្រៀង ការផ្គត់ផ្គង់ដំឡូងមី ជាមួយសហគមន៍ក្រុមអ្នកផលិតកសិកម្ម........................៣៨

★ បុណ្យកាត់ឫសសីមាសម្ពោធឆ្លងវិហារ និងសមិទ្ធផលនានា......................................................៤០

★ ពិធីបើកផ្តល់ថវិការបបគោលនយោបាយជូនជនពិការក្រីក្រ.......................................................៤២

★ បើកការដ្ឋានសាងសង់ផ្លូវក្រាលកៅស៊ូប្រវែងជាង ២៤គីឡូម៉ែត្រ..................................................៤៤

★ សាខាកាកបាទក្រហមខេត្តនាំយកអំណោយជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយសារខ្យល់កន្ត្រាក់..........៤៦

★ បុណ្យពុទ្ធាភិសេកព្រះអង្គធំ និងសម្ពោធសមិទ្ធផលនានា......................................................៤៨

★ ពិធីសំណេះសំណាលជាមួយបងប្អូនកម្មករ កម្មការនី...............................................................៥០

★ ពិធីចែកអាវភ្លៀងជូនដល់កងកម្លាំងបណ្តារអង្គភាពទិសទី១........................................................៥២

★ យុទ្ធនាការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ..................................................................................៥៤

★ ពិធីប្រគល់ ទទួល និងជូនដំណើរអដ្ឋិធាតុយុទ្ធជនពលីកងទ័ពស្ម័គ្រចិត្តវៀតណាម...........................៥៦

★ ក្រសួងកសិកម្មចុះពិនិត្យវឌ្ឍនភាពការងារកសិកម្ម..........៥៨
★ ពិធីបិទបញ្ចប់វគ្គហ្វឹកហ្វឺនការងាររក្សាសណ្តាប់ធ្នាប់..........៦០
★ ពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតថ្លៃ..........៦២
★ ពិធីចែកអំណោយជូនប្រជាពលរដ្ឋងាយរងគ្រោះ..........៦៤
★ ពិធីអបអរសាទរទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ..........៦៦
★ ក្រសួងកសិកម្ម ចុះទស្សនកិច្ចក្រុមហ៊ុន ស៊ី.អេ.ឌី.អាយ ..........៦៨
★ ពិធីប្រកាសតែងតាំងប្រធានមន្ទីរផែនការ..........៧០
★ ពិធីអបអរសាទរខួបទី ១៥ឆ្នាំនៃការចុះប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក..........៧២
★ ពិធីប្រកាសក្រុមការងារនិស្សិតស្ម័គ្រចិត្ត របស់គម្រោងជំរុញផលិតកម្មគ្រាប់ពូជស្រូវ..........៧៤
★ តំបន់កូនភ្នំ ត្រូវបានរាជរដ្ឋាភិបាលអនុញ្ញាតិឲ្យចុះវាស់វែង..........៧៦
★ កិច្ចប្រជុំពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍កម្មវិធីវិទ្យុមិត្តភាពកម្ពុជា-ថៃ..........៧៨
★ ពិធីសំណេះសំណាល ជាមួយក្រុមនិស្សិតស្ម័គ្រចិត្តមកពីប្រទេសបារាំង..........៨០
★ ពិធីសំណេះសំណាលជាមួយសមាជិក សមាជិកាស.ស.យ.ក..........៨២
★ ពិធីសំណេះសំណាលជាមួយក្រុមអ្នកដើរព្រៃកម្ពុជា..........៨៤
★ ពិធីចុះហត្ថលេខាការផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គ..........៨៦
★ ពិធីដាំកូនឈើអបអរសាទរ រុក្ខទិវា ៩កក្កដា..........៨៨
★ ទិវាអក្ខរកម្មជាតិ អន្តរជាតិ ៨កញ្ញា លើកទី២៣..........៩០
★ ពិធីបិទវគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សា..........៩២
★ ពិធីប្រកាសដាក់បញ្ចូលថ្នាំបង្ការជំងឺមហារីមាត់ស្បូនដល់កុមារី..........៩៤
★ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពកងរុករក និងសង្គ្រោះលេខ៧២១..........៩៦
★ ក្រសួងសុខាភិបាល ចុះពិនិត្យស្ថានភាព និងវឌ្ឍនភាពសុខាភិបាល..........៩៨
★ ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ..........១០០
★ ពិធីបញ្ចុះបឋមសិលា សាងសង់អគារព្យាបាលអ្នករស់នៅជាមួយមេរោគអេដស៍..........១០២
★ កិច្ចប្រជុំពិភាក្សាការបើកឲ្យដំណើរការច្រកទ្វារព្រំដែនអានសេះ..........១០៤
★ សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំកំណត់តំបន់ដីផលិតកម្មដំណាំកសិកម្មសរីរាង្គ..........១០៦
★ សកម្មភាពថ្នាក់ដឹកនាំ..........១០៨

# អារម្ភកថា

ផ្ដើមចេញពីព្រឹត្តការណ៍ជាតិ និងអន្តរជាតិសំខាន់ៗជាច្រើន ដែលបានកើតឡើងក្នុងឆ្នាំ២០២៣ ហើយដែលនឹងត្រូវបញ្ចប់ទៅវិញនាចុងខែធ្នូ ក្នុងគោលបំណងរក្សាទុកជាកម្រងឯកសារ រូបភាព អត្ថបទព័ត៌មាននានាជាច្រើន ដែលជាសកម្មភាពអនុវត្តន៍ជាក់ស្តែងក្នុងការកសាង និងអភិវឌ្ឍន៍មាតុភូមិនៅលើទឹកដីខេត្តព្រះវិហារ ដែលជាចំណែកមួយនៃព្រះរាជាណាចក្រកម្ពុជាឋិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត រួមជាមួយបណ្តាមន្ទីរអង្គភាព ស្ថាប័នពាក់ព័ន្ធជាច្រើន ទាំងក្នុងនិងក្រៅរដ្ឋាភិបាល ដើម្បីបម្រើដល់ការរីកចម្រើន និងតម្រូវការឥតឈប់ឈរក្នុងជីវភាពរស់នៅរបស់ប្រជាជន ។ ក្រោយព្រឹត្តការណ៍ផ្ទុះនូវជំងឺរាតត្បាតកូវីដ-១៩ និងវិបត្តិជាសកលនានាដែលពិភពលោកកំពុងប្រឈមទៅនឹងគ្រោះថ្នាក់ថ្មីៗ (សង្គ្រាមនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ សាសនា) នៅចំពោះមុខស្ថានការណ៍ប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយរវាងមហាអំណាចដែលមាននិន្នាការខុសគ្នាទាំងនៅក្នុងតំបន់ និងពិភពលោក ។

ចំពោះព្រះរាជាណាចក្រកម្ពុជាការរក្សាបាននូវសុខសន្តិភាព ដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាកត្តាសំខាន់បំផុត ។ រាជរដ្ឋាភិបាលអាណត្តិទី៧ ដែលកើតឡើងដោយការបោះឆ្នោតសកល ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដឹកនាំដោយក្រុមមនុស្សជំនាន់បន្តវេន (ឥស្សរជនវ័យយុវជន) បានចេញដំណើរក្នុងបេសកម្មយ៉ាងស្វាហាប់ ដែលកំណត់គោលដៅលើមូលដ្ឋានយុទ្ធសាស្ត្របញ្ចកោណតំណាក់កាលទី១ ជាការស្នងមរតកដែលរៀបចំត្រួសត្រាយផ្លូវ និងការកសាងមូលដ្ឋានគ្រឹះសំខាន់ៗនៃក្រុមមនុស្សជំនាន់មុន ដែលបានបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃនៅកម្ពុជា និងការបង្រួបបង្រួមជាតិឡើងវិញក្រោមម្លប់នៃព្រះមហាក្សត្រវិរៈក្សត្រខ្មែរ ដោយមានការចូលរួមពីគ្រប់ភាគីខ្មែរក្នុងជម្លោះនៃអតីតកាលរបស់ជាតិខ្លួន ។

ព្រឹត្តការណ៍សំខាន់ៗនានា ត្រូវបានមន្ទីរព័ត៌មានខេត្តព្រះវិហារចងក្រងជារូបភាព ឯកសារអត្ថបទព័ត៌មាន ដោយរក្សាសិទ្ធខ្លឹមសារដើម ដែលមន្ទីរព័ត៌មានបានតាក់តែងឡើង និងទទួលខុសត្រូវក្នុងកម្រិតជាអង្គភាពព័ត៌មាននៅថ្នាក់ក្រោមជាតិ តាមសមត្ថកិច្ចកំណត់ដោយច្បាប់។ ដូច្នេះខ្លឹមសារអត្ថបទព័ត៌មានរូបថតដែលមានក្នុងទស្សនាវដ្តីនេះគឺពុំអនុញ្ញាតឲ្យបុគ្គល ឬ ស្ថាប័នព័ត៌មានឯកជននានាចម្លងយកទៅផ្សព្វផ្សាយក្នុងគោលបំណងទុច្ចរិតបំផ្លើសបំផ្លៃ ឬ ក្លែងប្រឌិតខុសពីស្ថានភាពដើមបានឡើយ ។

មន្ទីរព័ត៌មានខេត្តព្រះវិហារ សូមឧទ្ទិសនូវកម្រងរូបភាព ខ្លឹមសារ អត្ថបទព័ត៌មាន និងស្នាដៃទាំងឡាយជូនចំពោះវីរភាពអ្នកស្នេហាជាតិគ្រប់ជំនាន់ ពិសេសរៀមច្បងជំនាន់មុនៗដែលចូលរួមកសាងទឹកដីខេត្តព្រះវិហារ ដែលនៅមុនឆ្នាំ១៩៨១ គឺជាទីរហោស្ថាន ឲ្យមានភាពរស់រវើក និងភាពមនោរម្យដូចមានក្នុងបច្ចុប្បន្ន ៕

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ព្រះវិហារ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
**មន្ទីរព័ត៌មានខេត្តព្រះវិហារ**

# ពិធីបួងសួងរំលឹកគុណបុព្វបុរសខ្មែរ និងអបអរសាទរមេណីយដ្ឋានប្រាសាទ កោះកេរចុះបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក



ពិធីបួងសួងរំលឹកដល់ដួងព្រលឹងបុព្វបុរសខ្មែរ និងការអបអរសាទរ "រមណីយដ្ឋានប្រាសាទកោះកេរ" ត្រូវបានចុះបញ្ជីក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និង លោកជំទាវ បណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត នៅមុខប្រាសាទប្រាង្គ (ប្រាសាទធំ) នៃរមណីយដ្ឋានប្រាសាទកោះកេរ ស្ថិតនៅភូមិស្រយ៉ង់ជើង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ (ប្រាសាទកោះកេរត្រូវបានដាក់ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ (UNESCO) ទីក្រុងរីយ៉ាត ប្រទេសអារ៉ាប៊ីសាអូឌីត នៅថ្ងៃទី១៧ កញ្ញា ឆ្នាំ២០២៣ )









ទិដ្ឋភាពក្នុងអង្គពិធី



# អភិបាលខេត្តបានដឹកនាំមន្ត្រីរាជការ កងកម្លាំងទាំង៣ ចុះសាកសួរសុខទុក្ខ កងទ័ពឈរជើងតាមបន្ទាត់ព្រំដែន




*គណៈអធិបតី ថតរូបអនុស្សាវរីយ៍*

នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០២៣ឯកឧត្តម**គីម រិទ្ធី** អភិបាលខេត្ត អញ្ជើញចុះសួរសុខទុក្ខកងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ស្ថិតក្នុងស្រុកជាំក្សាន្តអមដំណើរនាពេល នោះរួមមានអភិបាលរងខេត្ត មេបញ្ជាការ-មេបញ្ជាការរង កងកម្លាំងទាំង៣ មន្ទីរ-អង្គភាព និងអាជ្ញាធរក្រុង-ស្រុកជាច្រើនរូប ។



*កងទ័ពឈរជើងតាមបន្ទាត់ព្រំដែន*

ក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ព្រមទាំងនាយទាហ៊ាននិងពលទាហ៊ានទាំងអស់ដែលឈរជើងតាមបន្ទាត់ព្រំដែន ដែលបាននិងកំពុងបំពេញភារកិច្ចយ៉ាងសកម្ម ទាំងកិច្ចការងារព្រំដែន និងការងារអភិវឌ្ឍន៍មូលដ្ឋាន ។ឯកឧត្តមបន្តថា ថ្ងៃនេះពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកសួរសុខទុក្ខ ក្នុងឱកាសអបអរសាទរទិវាខួបលើកទី៤៤ នៃថ្ងៃជ័យជំនះ ៧មករា១៩៧៩-៧មករា ២០២៣ ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ប្រទេសជាតិមានសន្តិសុខពេញលេញ និងមានការរីកចម្រើនលើគ្រប់វិស័យ ។



ឯកឧត្តមក៏បានថ្លែងអំណរគុណ ដល់កងកម្លាំង

ប្រដាប់អាវុធទាំងអស់ ដែលខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងការថែរក្សាសុខសន្តិភាព បូរណៈភាពទឹកដី ព្រមទាំងបានលះបង់ទាំង កម្លាំងកាយចិត្ត សាច់ស្រស់ ឈាមស្រស់ ដើម្បីថែរក្សាការពារទឹកដីជូនជាតិមាតុភូមិ។ឯកឧត្តមក៏បានផ្តាំផ្ញើដល់នាយទាហ៊ាន នាយទាហ៊ានរង និងពលទាហ៊ានទាំងអស់ ដែលកំពុងបំពេញភារកិច្ចជូនជាតិមាតុភូមិ ត្រូវខិតខំថែរក្សាសុខភាពឲ្យបានល្អ ដេកក្នុងមុងជាប្រចាំ ពាក់អាវក្រាសៗ ដើម្បីកុំឲ្យមូសខ្លាខាំការពារពីជំងឺគ្រុនចាញ់ និងជំងឺដង្កាត់ផ្សេងៗឲ្យបានគ្រប់ពេលវេលា ៕



គណៈអធិបតីពិនិត្យមើញផែនទីព្រំប្រទល់



គណៈអធិបតី ថតរូបអនុស្សាវរីយ៍



គណៈអធិបតី ថតរូបអនុស្សាវរីយ៍



គណៈអធិបតីក្នុងពិធី

# ពិធីក្រុងពាលីលើកសសរព្រះវិហារ៥០០ ដើម និងពិធីបើកវគ្គបដិបត្តិ សមាធិរយៈពេល ៣ថ្ងៃ នៅវត្តប្រាសាទគោកបេង

នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៣ នៅវត្តប្រាសាទគោកបេង ស្ថិតក្នុងភូមិគោកបេង សង្កាត់កំពង់ប្រណាកក្រុងព្រះវិហារ ខេត្តព្រះវិហារ មានរៀបចំពិធីក្រុងពាលីលើកសសរព្រះវិហារ ៥០០ដើម និងពិធីបើកវគ្គបដិបត្តិសមាធិរយៈពេល ៣ថ្ងៃ ក្រោមអធិបតីភាព ឯកឧត្តម **មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ សម្តេចព្រះឧត្តមចរិយាបណ្ឌិត **ឈឹង ប៊ុនឈា** ព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ និងជាព្រះអនុប្រធានថេរៈសភានៃព្រះពុទ្ធសាសនា ព្រះរាជាណាចក្រកម្ពុជា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់សម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការចូលរួមពីសំណាក់ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត លោកលោកស្រី អភិបាលរងខេត្ត ថ្នាក់ដឹកនាំមន្ទីរអង្គភាពនានាជុំវិញខេត្ត កងកម្លាំងទាំង៣ មន្ត្រីរាជការ ព្រះសង្ឃ តាជីយាយជី និងពុទ្ធបរិស័ទជាច្រើនរូប ។

ព្រះអង្គ **ឡុង សុមុនី** ព្រះមេគណខេត្តព្រះវិហារមានសង្ឃដិកាឲ្យដឹងថា ខេត្តព្រះវិហារមានវត្តសរុបចំនួន ១១៥ វត្ត មានព្រះសង្ឃចំនួន ៨៧៦អង្គ មានសាលាពុទ្ធិកសិក្សាចំនួន៦ និងកម្រងសាលាពុទ្ធិកបឋមសិក្សាចំនួន១ ដែលមានសមណៈសិក្សាពុទ្ធិកចំនួន ៣១៨អង្គ សមណៈសិស្សសិក្សាធម៌វិន័យមានចំនួន ៣១៨អង្គ នៅទូទាំងខេត្តព្រះវិហារ ។ ព្រះអង្គក៏មាន សង្ឃដិការពីរបាយការណ៍រីកចម្រើនរបស់វត្តប្រាសាទគោកបេងផងដែរ ។



*ឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រី*



*គណៈអធិបតីក្នុងពិធី*

មានប្រសាសន៍នាឱកាសនោះឯកឧត្តម**មាស សុភា** បានឲ្យដឹងថា រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជា ណាចក្រកម្ពុជា បានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព ក្រោមគោលនយោបាយឈ្នះឈ្នះ របស់សម្តេច និងបានអភិវឌ្ឍន៍ប្រទេសជាតិមានការរីកចម្រើន យ៉ាងឆាប់រហ័សលើគ្រប់វិស័យ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ។ ជាក់ស្តែងថ្ងៃនេះបានរៀបចំពិធីក្រុងពាលីលើកសសរ៥០០ដើមនៅវត្តប្រាសាទគោកបេងនាពេលនេះ ដែលនិងក្លាយទៅជាបូជនីយដ្ឋានប្រវត្តិសាស្រ្តដ៏សំខាន់ និងមានសក្តានុពលបំផុត សម្រាប់បម្រើអោយផលប្រយោជន៍ដ៏ឧត្តុងឧត្តម មិនអាចកាត់ថ្លៃបានដល់ព្រះពុទ្ធសាសនា និងសង្គមជាតិ ពិសេសរឹតតែធ្វើអោយខេត្តព្រះវិហារ រីកមុខមាត់មួយកម្រិតទៀត ។ ទាំងនេះក៏ដោយសារតែប្រទេសរបស់យើង មានសុខសន្តិភាព ដូច នេះឯកឧត្តម ក៏បានផ្តាំផ្ញើដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បងប្អូនប្រជាពលរដ្ឋ លោកតា លោកយាយ ទាំងអស់គ្នាចូលរួមថែរក្សា និងការពារនូវសុខសន្តិភាពឲ្យបានយូរអង្វែង ដោយបន្តគាំទ្ររាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចតេជោជាបន្តទៀត ។



ទិដ្ឋភាពក្នុងពិធី



មានសង្ឃដីកានាឱកាសនោះ សម្តេចព្រះឧត្តមចរិយាបណ្ឌិត **ឈឹម ប៊ុនឈា** បានកោតសរសើរចំពោះការរីកចម្រើនរបស់វត្តប្រាសាទគោកបេង និងបានឲ្យដឹងអំពីអត្ថ ប្រយោជន៍នៃការបដិបត្តិសមាធិវិបស្សនា ព្រមទាំងបានលើកឡើងអំពី ទំនាក់ទំនងដែលមិនអាចខ្វះបាន រវាងផ្នែកពុទ្ធចក្រ និងអាណាចក្រ ៕



គណៈអធិបតីក្នុងពិធី

# ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេសA ឆ្នាំសិក្សា២០២១-២០២២



គណៈអធិបតីក្នុងពិធី



គណៈអធិបតី ថតរូបអនុស្សាវរីយ៍

ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៣ឯកឧត្តម**មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តព្រះវិហារ ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្ត បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិទ្ទេស A ចំនួន ០៤នាក់ សម័យប្រឡង ៥.ធ្នូ ឆ្នាំ២០២២ ។ពិធីនេះធ្វើឡើងនៅសាលប្រជុំសាលាខេត្តព្រះវិហារ នឹងមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាអភិបាលរងខេត្ត ប្រធានមន្ទីរពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ នឹងអាណាព្យាបាលសិស្សានុសិស្សជាច្រើនរូបទៀត ។

ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តបានមានប្រសាសន៍ណែនាំដល់សិស្សានុសិស្ស និងជាយុវជនបន្តវេនត្រូវកសាងខ្លួនឱ្យក្លាយជាកូនល្អ សិស្សល្អ និងយុវជនល្អនិងត្រូវខិតខំហាត់ពត់ លត់ដំ ព្យាយាមតស៊ូរៀនសូត្របន្ថែមទៀត ទើបមានអនាគតល្អ ដែលអាចក្លាយជាថ្នាក់ដឹក នាំទៅថ្ងៃអនាគត ដើម្បីជួយកសាង និងអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ។ជាមួយនេះ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ មាតាបិតា អាណា ព្យាបាលសិស្សទាំងអស់ដែលបានខិតខំលះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតី ក្នុងការជួយជំរុញ និងបង្ហាត់បង្រៀនកូនបន្ថែមនៅតាមផ្ទះ ដើម្បីធ្វើយ៉ាងណា ឱ្យសិស្សានុសិស្សបានក្លាយជាពលរដ្ឋល្អ ជាទំពាំងស្នងឫស្សី និងជាសសរទ្រូងដ៏រឹងមាំសម្រាប់ប្រទេសជាតិ ។

មានមតិក្នុងឱកាសនោះដែរ ឯកឧត្តម **មាស សុភា** ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា ក្មួយៗចៅៗជំនាន់នេះពិតជាមានសំណាងណាស់ដែលមានឱកាសអង្គុយរៀនក្រោមម្លប់សន្តិភាព មានគ្រូ បង្រៀនល្អៗ មានបន្ទប់រៀន មានសាលារៀនល្អៗ មានសៀវភៅសិក្សារៀនសូត្រសមរម្យ គ្រប់គ្រាន់ មានប្រព័ន្ធអ៊ីនធឺណែត សម្រាប់សិក្សាស្រាវជ្រាវ និងមានអ្នកជួយគាំទ្រសព្វបែបយ៉ាង ដូចនេះក្មួយៗចៅៗត្រូវក្តាប់ឱកាសឱ្យជាប់ហើយ ដើម្បីអភិវឌ្ឍន៍ខ្លួនឯង និងសង្គមជាតិ ។

ឯកឧត្តមបន្តថា រាជរដ្ឋាភិបាលដែលមានសម្តេចតេជោជានាយរដ្ឋមន្ត្រី បានបង្កើត សន្តិភាព ស្ថិរភាព និងសុវត្ថិភាពសង្គមពេញលេញ បង្កលក្ខណៈល្អប្រសើរក្នុងការរៀនសូត្រ ក្រេបជញ្ជក់យកចំណេះដឹង និងបទពិសោធន៍ថ្មីៗល្អៗ ដើម្បីកសាងសមត្ថភាពខ្លួនឱ្យក្លាយជាកូនល្អ មិត្តល្អ សិស្សល្អ និងពលរដ្ឋល្អ មានឧត្តមភាពទាំងកាយ និងបញ្ញារួមគ្នាកសាង និងអភិវឌ្ឍ ប្រទេសជាតិនាពេលអនាគត ។



គណៈអធិបតី ថតរូបអនុស្សាវរីយ៍



គណៈអធិបតី ថតរូបអនុស្សាវរីយ៍

សូមបញ្ជាក់ថា ជាការលើកទឹកចិត្តជូនដល់សិស្សនិទ្ទេសA ទាំង០៤នាក់ ក្នុងម្នាក់ៗ ទទួលបាន កុំព្យូទ័រ ០១គ្រឿង និងថវិកា ០៥លានរៀល ឧបត្ថម្ភដល់លោកគ្រូ អ្នកគ្រូទាំង០២ វិទ្យាល័យ ដែលមានសិស្សទទួលជ័យលាភីក្នុងម្នាក់ៗទទួលបានថវិកា ២០ម៉ឺនរៀលផងដែរ ៕



ទិដ្ឋភាពក្នុងពិធី

# ពិធីបុណ្យកាត់ឫសសីមាសម្ភោធឆ្លងវិហារ និងសមិទ្ធផលនានាក្នុង វត្តពោធិសិលារ៉ាម ហៅវត្តគីឡូលេខ៨



ឯកឧត្តមអភិបាលខេត្ត អញ្ជើញកាត់ខ្សែបូ

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈ អភិបាលខេត្តព្រះវិហារ បានអញ្ជើញជាអធិបតីភាព ក្នុងពិធីបុណ្យកាត់ឫសសីមាសម្ពោធឆ្លងវិហារ និងសមិទ្ធផលនានាក្នុងវត្តពោធិ៍សិលារ៉ាម ហៅវត្តគីឡូលេខ ៨ ស្ថិតនៅភូមិឯកភាព សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលពិធីនេះក៏មានការនិមន្តចូលរួមពីព្រះអង្គ **ឡុង សុមុនី** ព្រះមេគណខេត្តព្រះវិហារ ព្រមទាំងព្រះសង្ឃជាព្រះមេគណ ធម្មយុត្តិកនិកាយខេត្ត និងព្រះចៅអធិការវត្តដែលបាននិមន្តមកពីវត្តផ្សេងៗក្នុងខេត្ត លោក លោកស្រីជាអភិបាលរងខេត្ត លោកឧកញ៉ា អ្នកឧកញ៉ា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកយាយ លោកតា សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងពុទ្ធបរិស័ទច្រើនកុះករ ។

យោងតាមរបាយការណ៍ របស់គណៈកម្មការវត្តពោធិសិលារ៉ាម បានឲ្យដឹងថាសមិទ្ធផលថ្មី ដែលបានសម្ពោធឆ្លងនាពេលនេះ គឺជាព្រះវិហារ ដែលបានកសាងឡើងអំពីថ្មបេតុងអាម៉េ ប្រក់ក្បឿង ដែលមានទទឹង ៩ម៉ែត្រ និងបណ្ដោយ ១៨ ម៉ែត្រ ដែលបានចាប់ផ្ដើមដំណើរសាងសង់នៅថ្ងៃទី៤ ខែមីនា ឆ្នាំ ២០០៩ បានសាងសង់រួចរាល់មួយរយភាគរយ ដោយចំណាយថវិកាអស់ចំនួន ៣៤ ម៉ឺនដុល្លា ដែលថវិកាទាំងអស់នេះ បានមកពីសទ្ធាជ្រះថ្លាដ៏មុតមាំរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាពុទ្ធបរិស័ទមកពីគ្រប់ទិសទី ។



គណៈអធិបតីក្នុងពិធី

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានកោតសរសើរចំពោះការរីកចម្រើនរបស់វត្ត ពោធិសិលារ៉ាម និងបានថ្លែងអំណរគុណដល់ព្រះចៅអធិការ ព្រះសង្ឃគ្រប់ព្រះអង្គ ជាពិសេសឯកឧត្តម លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា លោក លោកស្រី ជាពុទ្ធបរិស័ទទាំងអស់ ដែលមានសទ្ធាជ្រះថ្លាក្នុងវិស័យពុទ្ធសាសនា ដែលបានលះបង់នូវ

ថវិកាផ្ទាល់ខ្លួន ចូលរួមកសាងនូវសមិទ្ធផលនានា ជាពិសេសព្រះវិហារដ៏ស្រស់ស្អាតនាពេលនេះ ទុកជាកេរ្តិ៍មរតកសម្រាប់ព្រះពុទ្ធសាសនា និងបានជាប្រយោជន៍ដល់សាធារណៈជនទូទៅ ។

ឯកឧត្តមក៏បានផ្តាំផ្ញើដល់ព្រះសង្ឃ សូមបន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងអភិបាលកិច្ច និងគោរពប្រតិបត្តិធម៌វិន័យ និងការចូលរួមការងារសង្គមជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអប់រំនូវសីលធម៌សង្គមឲ្យបានល្អផូរផង់ជានាបាននូវសាមគ្គីភាព នៅក្នុងជួរពុទ្ធសាសនិក ដែលជាប្រការដ៏សំខាន់បំផុត និងសុំឲ្យបន្តស្មារតីដឹងគុណនូវគោលនយោបាយ " ឈ្នះ ឈ្នះ " និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបាននូវសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ។

បន្ទាប់មកឯកឧត្តម ក៏បានបំពាក់គ្រឿងឥស្សរិយយសនិងមេដាយជូនដល់សប្បុរសជននិងបានអញ្ជើញកាត់ឫសសីមាសម្ពោធឆ្លងព្រះវិហាជាកិច្ចបញ្ចប់កម្មវិធី ៕


ព្រះមេគុណខេត្ត អញ្ជើញកាត់ខ្សែបូ


គណៈអធិបតីបំពាក់មេដៃ


ឯកឧត្តមអភិបាលខេត្ត អញ្ជើញកាត់ឫសសីមា

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅអនុវត្ត បន្តឆ្នាំ២០២៣ របស់មន្ទីរបរិស្ថានខេត្ត

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ មន្ទីរបរិស្ថានខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុប លទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ូ ខនឫទ្ធីគុណ** រដ្ឋលេខាធិការក្រសួងបរិស្ថាន លោក **សុខ សាន្តតារ៉ា** អភិបាលរងខេត្ត ទទួលបន្ទុកវិស័យបរិស្ថាន និងមានការអញ្ជើញចូលរួមពីសំណាក់ គណៈប្រតិភូអមដំណើរ ប្រធាន-អនុប្រធានមន្ទីរ មន្ត្រីរាជការនៃមន្ទីរបរិស្ថានខេត្ត តំណាងអង្គការជាតិ អន្តរជាតិ មន្ត្រីឧទ្យានុរក្ស និងសហគមន៍តំបន់ការពារធម្មជាតិជាច្រើនរូបទៀត ។

លោក **សុខ ច័ន្ទសុជាតិ** ប្រធានមន្ទីរបរិស្ថានខេត្ត បានអានរបាយការណ៍ឲ្យដឹងថា មន្ទីរបរិស្ថានបានរៀបចំកិច្ចប្រជុំនេះ ឡើងក្នុងគោលបំណងដើម្បីធ្វើបទបង្ហាញពីលទ្ធផលការងារ ដែលសម្រេចបាន និងបញ្ហាប្រឈមដែលកំពុងជួបប្រទះ ក្នុងកំឡុងពេលអនុវត្តសកម្មភាពការងារ ដែលផ្តោតសំខាន់ទៅលើការកសាងរដ្ឋបាលទំនើប ការគាំពារបរិស្ថាន ការអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ការការពារ និងអភិរក្សធនធានធម្មជាតិក្នុងភូមិសាស្ត្រខេត្ត ។

មានមតិនាឱកាសនោះ លោក **សុខ សាន្តតារ៉ា** អភិបាលរងខេត្ត បានឲ្យដឹងថាមន្ទីរបរិស្ថានខេត្ត បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តអនុវត្តតួនាទី និងភារកិច្ចស្នូលរបស់ខ្លួន ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិក្នុងភូមិសាស្ត្រខេត្ត ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែល កំពុងរស់នៅក្នុងតំបន់សហគមន៍ការពារធម្មជាតិ ការអប់រំចំណេះដឹង និងផ្សព្វផ្សាយព័ត៌មាន



ឯកឧត្តម ស៊ូ ខឫទ្ធីគុណ រដ្ឋលេខាធិការ




គណៈអធិបតីក្នុងពិធី

បរិស្ថាន ការលើកទឹកចិត្តក្នុងការអនុវត្តមេត្រីភាពបរិស្ថាន ការគាំទ្រ និងផ្តល់បច្ចេកទេស ក្នុងការអនុវត្តមុខងារ ដែលបានផ្ទេរ និងប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ការអនុវត្តលើការផ្តល់សេវាសាធារណៈ ដើម្បីបង្កើនសេដ្ឋកិច្ចជាតិ ការលើកកម្ពស់កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ និងកិច្ចសហការជាមួយអង្គការដៃគូរក្រៅរដ្ឋាភិបាល ។ លោកបានបន្តទៀតថាមន្ទីរបរិស្ថាន បាននឹងកំពុងសម្របសម្រួលក្នុងការអនុវត្តសកម្មភាព ការងារចម្បងៗមួយចំនួនទៀតពាក់ព័ន្ធទៅ នឹងការរៀបចំកំណត់បែងចែកតំបន់គ្រប់គ្រងបោះបង្គោលព្រំប្រទល់ រៀបចំផែនការគ្រប់គ្រង និងចុះបញ្ជីដីរដ្ឋនៅតាមបណ្តាតំបន់ការពារធម្មជាតិ ។



លោក សុង ច័ន្ទសុជាតិ ប្រធានមន្ទីរបរិស្ថាន


មន្ត្រីមន្ទីរបរិស្ថាន

បន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញ តាមបណ្តាការិយាល័យ នៃមន្ទីរបរិស្ថានរួចមក ឯកឧត្តម **សុ ខនឫទ្ធីគុណា** រដ្ឋលេខាធិការក្រសួងបរិស្ថាន បានថ្លែងកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចរហូតទទួលបានសមិទ្ធផលជោគជ័យ ។ ឯកឧត្តមសូមគាំទ្រ និងសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រី



លោក សុខ សាន្តតារ៉ា អភិបាលរងខេត្ត

ឧទ្យានុរក្សទាំងអស់ ឱ្យបន្តខិត ខំអនុវត្តការងារ ឱ្យបានកាន់តែល្អប្រសើរបន្ថែមទៀត នូវតួនាទីភារកិច្ចរបស់ខ្លួន និងដោះស្រាយបញ្ហាប្រឈមនានា ប្រកបដោយភាពម្ចាស់ការ មនសិការវិជ្ជាជីវៈ ការទទួលខុសត្រូវ និងការច្នៃប្រឌិតខ្ពស់ ព្រមទាំងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូឱ្យកាន់តែជិតស្និទ្ធ ជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀតក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមនិងគោលបំណងជាយុទ្ធសាស្ត្រពោលគឺធានាឲ្យបាននូវកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយ ចីរភាពសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់ ។

ក្នុងឱកាសនោះ ឯកឧត្តមរដ្ឋលេខាធិការ បានប្រគល់នូវប័ណ្ណសរសើរជូនដល់មន្ត្រីរាជ ការនៃមន្ទីរបរិស្ថាន ដែលមានស្នាដៃ ក្នុងការបំពេញតួនាទីភារកិច្ចនាពេលកន្លងមកនិងសម្ភារៈជូលដល់មន្ត្រីឧទ្យានុរក្សមួយចំនួនផងដែរ៕


គណៈអធិបតីថតរូបអនុស្សាវរីយ៍

# យុទ្ធនាការគោយន្តមានភ្លើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងចែកភ្លើងបំភ្លឺទៅដល់អាជ្ញាធរទាំង ០៨ក្រុង-ស្រុក



គណៈអធិបតីក្នុងយុទ្ធនាការគោយន្តមានភ្លើង

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ រដ្ឋបាលខេត្តព្រះវិហារ ក្រោមការដឹកនាំរបស់ ឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្ត និងមានការសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តព្រះវិហារ ព្រមទាំងមានការចូលរួមពីស្នងការដ្ឋាននគរបាលខេត្ត មន្ទីរជំនាញនិងអាជ្ញាធរទាំង ០៨ក្រុង-ស្រុក បានបើកយុទ្ធនាការគោយន្តមានភ្លើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងចែកភ្លើងបំភ្លឺទៅដល់អាជ្ញាធរទាំង០៨ក្រុង-ស្រុកក្នុងខេត្តព្រះវិហារ ដែលពិធីនេះប្រារព្ធឡើង នៅក្នុងបរិវេណសាលាខេត្តព្រះវិហារ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានឱ្យដឹងថា យុទ្ធនាការគោយន្តមានភ្លើង ដែលបានប្រារព្ធឡើងនាពេលនេះ គឺដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលបង្ក ឡើងដោយសារគោយន្តដែលបើកបរលើដងផ្លូវ ដោយគ្មានភ្លើងបំភ្លឺចរាចរណ៍ ។ ហើយយុទ្ធនាការនាពេលនេះជាយុទ្ធការផ្សព្វផ្សាយ និងអប់រំទៅដល់បងប្អូនដើម្បីចូលរួមអនុវត្តន៍ឲ្យបាន គ្រប់ៗគ្នា ដែលមានរយៈពេល៣ខែ ដោយចាប់ផ្តើមពីថ្ងៃបើកយុទ្ធនាការនេះតទៅ ។ ហើយក្នុងដំណាក់កាលទី២ បើសិនបងប្អូនមិនព្រមដាក់ភ្លើងបំភ្លឺចរាចរណ៍នោះទេ មន្ត្រីអនុវត្តន៍ចរាចរណ៍ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ធ្វើការឃាត់គោយន្តរក្សាទុកនៅពេលដែលបងប្អូនធ្វើចរាចរណ៍ នៅតាមដងផ្លូវ រហូតដល់គោយន្តមានភ្លើងបំភ្លឺចរាចរណ៍ទើបអនុញ្ញាតអោយចរាចរណ៍បាន ។ ឯកឧត្តមបន្តថា ក្នុងយុទ្ធការដំណាក់កាលទី១នេះ ឯកឧត្តមបានទទួលថវិកា ដើម្បីទិញភ្លើងបំភ្លឺគោយន្តពីការរៃអង្គាសគ្នា របស់សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តព្រះវិហារ ដោយក្នុង១ក្រុង-ស្រុក ទទួលបាន១០០គោយន្ត ហើយក្នុង



ទិដ្ឋភាពក្នុងយុទ្ធនាការគោយន្តមានភ្លើង

១គោយន្តមានភ្លើងបំភ្លឺ ចំនួន៤ សរុបអស់ភ្លើងបំភ្លឺចំនួន ២៤០០ភ្លើងអំពូល ។

ទន្ទឹមនេះឯកឧត្តមក៏បានផ្តាំផ្ញើទៅដល់ សហភាព



គណៈអធិបតីថតរូបអនុស្សាវរីយ៍

សហព័ន្ធយុវជនកម្ពុជា ត្រូវសហការ គ្នាជាមួយអាជ្ញាធរក្រុង-ស្រុក អធិការស្រុក ប៉ុស្តិ៍រដ្ឋបាល ដើម្បីធ្វើការបំពាក់ជូនបងប្អូនប្រជាពលរដ្ឋ ដែលពួកគាត់មានគោយន្តបើកបរតាមដងផ្លូវ ឬ ឲ្យបងប្អូនមកបំពាក់នៅទីតាំងណាមួយពិសេសនៅតាមសាលាឃុំសង្កាត់។ហើយអាជ្ញាធរត្រូវផ្តល់របាយការណ៍របស់ក្រុមការងារ ស្តីពីសកម្មភាពចុះអនុវត្តន៍យុទ្ធការបំពាក់ភ្លើងបំភ្លឺគោយន្តមករដ្ឋបាលខេត្ត ដើម្បីធ្វើការបូកសរុបលទ្ធផល ។

តាមរបាយការណ៍ របស់អាជ្ញារក្រុង-ស្រុងទាំង ៨ មានគោយន្តសរុប២០,០០០គ្រឿងហើយក្នុងដំណាក់កាលទី២ ឯកឧត្តមនឹងទិញភ្លើងបំភ្លឺបន្ថែមទៀត ដើម្បីផ្តល់ជូនបងប្អូនក្នុង ១ក្រុង-ស្រុក នឹងទទួលបាន១០០០គោយន្ត៕





ទិដ្ឋភាពក្នុងយុទ្ធនាការគោយន្តមានភ្លើង







គណៈអធិបតីថតរូបអនុស្សាវរីយ៍

# កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការលើកទី៩ រវាងខេត្តព្រះវិហារ ជាមួយខេត្តចម្ប៉ាសាក់



*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ឯកឧត្តម**គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្ត បានដឹកនាំគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការលើកទី៩ រវាងខេត្តព្រះវិហារនៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តចម្ប៉ាសាក់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមកិច្ចស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ឯកឧត្តមបណ្ឌិត **វិល័យ វង្ស ប៊ុតដាខាំ** អភិបាលខេត្តចម្ប៉ាសាក់នៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ ។ កិច្ចប្រជុំនេះបានប្រព្រឹត្តិទៅនៅទីក្រុងប៉ាក់សេ ខេត្តចម្ប៉ាសាក់ ដែលធ្វើឡើងក្នុងគោលបំណង ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាព និងការអភិវឌ្ឍន៍រវាងខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរឲ្យបានកាន់តែរឹងមាំបន្ថែមទៀត ។

ក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានសម្តែងនូវក្តីសោមនស្សរីករាយ និងវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍន៍លើគ្រប់វិស័យ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ សំណង់ និងផ្នែកធនធានមនុស្ស នៅក្នុងខេត្តចម្ប៉ាសាក់នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។ ឯឧត្តមក៏បានគូសបញ្ជាក់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ ដោយឈរលើមូលដ្ឋានចំណងមិត្តភាពជាប្រពៃណី និងភាពជាអ្នកជិតខាងល្អ ព្រមទាំងឯកភាពបន្តពង្រឹងទំនាក់ទំនងដ៏ល្អ ក្នុងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងខេត្ត និងខេត្តនៃប្រទេសទាំងពីរ ជាពិសេសវិស័យសំខាន់ៗ ដូចជានយោបាយសន្តិសុខ ពាណិជ្ជកម្ម វិនិយោគ អប់រំ និងវប្បធម៌ ។ ឯកឧត្តមបានបន្តទៀតថា កិច្ចសហប្រតិបត្តិការកន្លងមក បានអនុវត្តទៅលើវិស័យនានា ដែលបង្កលក្ខណៈឲ្យភាគីទាំងពីរសហការ និងដោះស្រាយនូវបញ្ហា ការរក្សាសណ្តាប់ធ្នាប់សន្តិសុខតាម



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*

បណ្តោយព្រំដែន ដូចជាអំពើចោរកម្ម ការឆ្លងចេញចូលសួរសុខទុក្ខរបស់ប្រជាពលរដ្ឋ ការរៀបចំពិធីបុណ្យអុំទូកមិត្តភាពរវាងស្រុកខូង និងស្រុកឆែប ដើម្បីបង្កើនការរឹតចំណងមិត្តភាពកិច្ចសហប្រតិបត្តិការនិងដើម្បីលើកកម្ពស់ការផ្លាស់ប្តូរទំនិញ និងទេសចរណ៍ ។ ស្របជាមួយនិងលទ្ធផលដែលអនុវត្តនាពេលកន្លងមក យើងសង្កេតឃើញថាមានបញ្ហាមួយចំនួន នៅមិនទាន់អនុវត្តបាន ដូចជាបញ្ហាសន្តិសុខសណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន ការជួញដូរគ្រឿងញៀន ការលួចកាប់បំផ្លាញព្រៃឈើ ការរត់ពន្ធ ការបរបាញ់សត្វ ការឆ្លងដែនខុសច្បាប់ ការរៀបអាពាហ៍ពិពាហ៍ខុសច្បាប់ ការផ្លាស់ប្តូរកិច្ចប្រជុំរវាង មន្ទីរជំនាញ និងមន្ទីរជំនាញ កិច្ចប្រជុំថ្នាក់ស្រុក និងថ្នាក់ ស្រុក។ល។



គណៈអធិបតីក្នុងកិច្ចប្រជុំ

ទន្ទឹមនេះ ឯកឧត្តមក៏បានជំរុញឲ្យភាគីទាំងពីរធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ជាពិសេសទៅលើវិស័យកសិកម្ម ដែលបច្ចុប្បន្ននេះនៅទូទាំងប្រទេសកម្ពុជា ខេត្តព្រះវិហារជាខេត្តធំជាងគេដែលនាំចេញនូវស្រូវសរីរាង្គទៅលក់នៅទីផ្សារអ៊ឺរ៉ុប និងកំពុងជំរុញខេត្តមួយនេះឲ្យក្លាយទៅជាខេត្តសរីរាង្គ ៕



ប្រតិភូចូលរួមក្នុងកិច្ចប្រជុំ



ទិដ្ឋភាពរួមក្នុងកិច្ចប្រជុំ

# ពលរដ្ឋជាង ៦០០គ្រួសារ នៅឃុំស្រយ៉ង់ ស្រុកគូលែន ទទួលបានបណ្ណសម្គាល់ម្ចាស់អចលនវត្ថុ



ឯកឧត្តម មាស សុភា ប្រគល់បណ្ណសម្គាល់ម្ចាស់អចលនវត្ថុ



គណៈអធិបតីក្នុងពិធី

ថ្ងៃទី២៥ ខែមករាឆ្នាំ២០២៣ ឯកឧត្តម**មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ អញ្ជើញចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជូនប្រជាពលរដ្ឋ ចំនួន៦១៤ គ្រួសារ ស្មើនិង ១០៦៣ក្បាលដី លើផ្ទៃដីចំនួន ១០,៤៧២ ហិកតា នៅភូមិរំចេក ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ តាមមន្ទីរអង្គភាពជុំវិញខេត្ត និងអាជ្ញាធរស្រុក-ឃុំ-ភូមិ ជាច្រើនរូបទៀត ។

នៅក្នុងឱកាសនោះដែរ ឯកឧត្តម **មាស សុភា** បានថ្លែងពាំនាំប្រសាសន៍ផ្តាំផ្ញើសាកសួរសុខទុក្ខ ពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជូនថ្នាក់ដឹកនាំមន្ត្រីរាជការ និងបងប្អូនប្រជាពលរដ្ឋដែលមានវត្តមាននៅទីនេះ ។ ឯកឧត្តមបានបន្តថា ការប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនាពេលនេះ គឺស្របពេលដែលប្រទេសយើង កំពុងអបអរសាទរបុណ្យឆ្នាំថ្មីឆ្នាំសកល ២០២៣ និងអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាជ័យជម្នះថ្ងៃ៧មករា ។

ឯកឧត្តម ទេសរដ្ឋមន្ត្រីបានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំយកចិត្តទុកដាក់ របស់អាជ្ញាធរខេត្ត-ស្រុក-ឃុំ ក្នុងការរៀបចំកិច្ចដំណើរការ ក្នុងការអនុវត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី របស់រាជរដ្ឋាភិបាលតាមស្រុក-ក្រុង ក្នុងគោលដៅរបស់ខេត្ត តាមជំហាននីមួយៗតាំងពី

ការប្រកាសតំបន់វិនិច្ឆ័យ កំណត់ព្រំប្រទល់ភូមិ ការវាស់វែងក្បាលដីនីមួយៗ គូសក្បាលដីនិងបំពេញទម្រង់បែបបទប្រមូលទិន្នន័យ ម្ចាស់ក្បាលដី ការបញ្ចូលទិន្នន័យម្ចាស់ក្បាលដី និងបិទផ្សាយជាសាធារណៈទិន្នន័យម្ចាស់ក្បាលដីទាំងអស់នៅក្នុងតំបន់វិនិច្ឆ័យ ក្នុងរយៈពេល ១៥ថ្ងៃសម្រាប់ទុកពេលឱ្យម្ចាស់ដីនិងអ្នកពាក់ព័ន្ធ ធ្វើការផ្ទៀងផ្ទាត់សុំកែតម្រូវម្ចាស់ក្បាលដី ហើយបិទផ្សាយបញ្ចប់ជាសាធារណៈរហូតប្រារព្ធពិធីប្រគល់វិញ្ញាបនបត្រនៅពេលនេះ ។



*ឯកឧត្តម គឹម រិទ្ធី ប្រគល់បណ្ណសម្គាល់ម្ចាស់អចលនវត្ថុ*



*អ្នកចូលរួមក្នុងពិធី*

ឯកឧត្តម **មាស សុភា** បានថ្លែងបញ្ជាក់យ៉ាងដូច្នេះថា៖លទ្ធផលដែលសម្រេចបានថ្ងៃនេះ គឺអាស្រ័យដោយកម្លាំងសាមគ្គីទាំងអស់ របស់កម្មវិធីដែលបានបញ្ចេញអស់កម្លាំងកាយ កម្លាំងចិត្ត ប្រកបដោយស្មារតីលះបង់ខ្ពស់ដែលមានជំនឿជាក់ ទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** ស្របតាមលទ្ធផលដ៏ធំធេងការចុះបញ្ជីដីធ្លីដូចបានលើកឡើងខាងលើ កន្លងមករដ្ឋបាលខេត្ត



*ឯកឧត្តម ប្រាក់ សុវណ្ណ ប្រគល់បណ្ណសម្គាល់ម្ចាស់អចលនវត្ថុ*

ព្រះវិហារក៏មានបញ្ហាប្រឈមមួយចំនួនដូចជា ទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និងរដ្ឋ ការកាន់កាប់ទន្ទ្រានដីថ្មីៗបែបអនាធិបតេយ្យពីសំណាក់ជនខិលខូច និងជនឱកាសនិយមដោយទាមទារឱ្យអាជ្ញាធរទទួលស្គាល់ ចេញលិខិតបញ្ជាក់ការកាន់កាប់ និងការប្រើប្រាស់ដីធ្លីដែលមិនមែនជាដីភោគៈ នៅតែបន្តនៅតាមបណ្តាលភូមិ-ឃុំមួយចំនួន ៕



*អភិបាលរងខេត្ត និងភ្ញៀវកិត្តិយសក្នុងពិធី*



*អ្នកចូលរួមក្នុងពិធី*

# ក្រសួងបរិស្ថាន រួមជាមួយអាជ្ញាធរខេត្ត រៀបចំកម្មវិធីបោះជំរំ និងបំបួសដើមឈើ ក្រោមប្រធានបទ “ ក្តីស្រឡាញ់ធនធានធម្មជាតិ និងជីវៈចម្រុះ ”



កម្មវិធីបោះជំរំនិងបំបួសដើមឈើក្រោមប្រធានបទ «ក្តីស្រឡាញ់ធនធានធម្មជាតិ និងជីវៈចម្រុះ» បានរៀបចំឡើងនៅតំបន់បេតិកភណ្ឌធម្មជាតិ «ភ្នំត្បែង» ក្នុងគោលបំណងបំផុសគំនិត និងស្មារតីស្រឡាញ់ និងអភិរក្សធនធានធម្មជាតិដល់ប្រជាជនទូទៅ និងផ្សព្វផ្សាយការយល់ដឹង និងចែករំលែកបទពិសោធន៍ ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រាស្រ័យទាក់ទង របស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ដើម្បីរួមគ្នាការពារ និងអភិរក្សធនធានធម្មជាតិជីវៈចម្រុះ និងបរិស្ថាន ។





*ទិដ្ឋភាពក្នុងពិធី*



*គណៈអធិបតីថតរូបអនុស្សាវរីយ៍*



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត កាត់ខ្សែបូក្នុងពិធី*

កម្មវិធីនេះ បានប្រព្រឹត្តទៅនៅសហគមន៍តំបន់ការពារធម្មជាតិចាក់អង្រែ តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ស្ថិតនៅភូមិបាក់កាំ ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ជួប ប៉ារីស៍** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រមទាំងមានការអញ្ជើញចូលរួម ពីប្រជាសហគមន៍មូលដ្ឋាន យុវជនកាកបាទក្រហម កាយឫទ្ធិ សិស្សានុសិស្ស តំណាងស្ថាប័នរដ្ឋ និងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមអ្នកស្រលាញ់ និងអភិរក្សធន ធានធម្មជាតិប្រមាណ ៣៨០នាក់ ។

ក្នុងឱកាសនោះដែរ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានលើកឡើងថា ការជួបជុំគ្នានាពេលនេះ ជាឱកាសសម្រាប់គ្រប់ភាគីទាំងអស់ ចូលរួមចែករំលែកនូវក្តីស្រឡាញ់ សាមគ្គីភាពរឹងមាំចូលរួមថែរក្សាបរិស្ថាន ក៏ដូចជាការពារអភិរក្សធនធានធម្មជាតិ សម្រាប់អ្នកជំនាន់ក្រោយក្រោមម្លប់នៃសន្តិភាព ។

គួរបញ្ជាក់ឱ្យដឹងថា ក្រសួងបរិស្ថានបាននិងកំពុងគ្រប់គ្រងផ្ទៃដីជាង ៧លានហិកតា ដែលបានបែងចែកជាឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់បេតិកភណ្ឌ និងរបៀងអភិរក្សជីវៈចម្រុះ ។ នៅតាមតំបន់ការពារធម្មជាតិ



*ទិដ្ឋភាពក្នុងពិធី*

ទាំងអស់នេះមានប្រជាសហគមន៍ជាច្រើនគ្រួសារដែលបាន និងកំពុងរស់នៅ ហើយពឹងផ្អែកទៅលើធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិទាំងអស់នោះ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ។ ដើម្បីជានាការការពារនិងគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះដោយនិរន្តរភាព ក្រសួងបរិស្ថានបានដាក់ពង្រាយឧទ្យានុរក្ស ចំនួន ១២៦០នាក់និងបានបង្កើត និងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិចំនួន១៩៣ ៕

# ពិធីស្រោចស្រពសុគន្ធវារី ជូនព្រះគ្រូ អនុគណស្រុកឆែប និងសម្ពោធសមិទ្ធផលនានា ក្នុងវត្តទ្រីសទ្ធារាម ឃុំសង្កែពីរ



*ទិដ្ឋភាពក្នុងពិធី*

ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានអញ្ជើញជាអធិបតីភាព ក្នុងពិធីស្រោចស្រពសុគន្ធវារីប្រគេនប្រកាសសនីយប័ត្រ ព្រះគ្រូវង្គានុរ័ក្ខកោសល **មឿង សុនិមិត្ត** ជាព្រះគ្រូអនុគណស្រុកឆែប ដែលរៀបចំឡើងក្នុងបរិវេណវត្តសុវណ្ណគីរី ស្ថិតក្នុងភូមិឆែបលិច ឃុំឆែបមួយ និងអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសាលាឆាន់ និងសមិទ្ធផលនានាក្នុងវត្តទ្រីសទ្ធារាម ស្ថិតក្នុងឃុំសង្កែពីរ ស្រុកឆែប ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣ ។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានចូលរួមអបអរសាទរចំពោះព្រះគ្រូវង្គានុរ័ក្ខកោសល **មឿង សុនិមិត្ត** ក្នុងឱកាសទទួលបានការតែងតាំង ជាព្រះគ្រូអនុគណស្រុកឆែបបន្ទាប់ពីទទួលបានជំនឿទុកចិត្តពីគណៈសង្ឃគ្រប់ព្រះអង្គ ពិសេសគឺទទួលបាននូវការទុកចិត្តពីជំនឿរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកឆែបទាំងមូល ព្រមទាំងចូលរួមអបអរសាទចំពោះសមិទ្ធផលនានាជាច្រើន ដែលមាននៅក្នុងវត្តទ្រីសទ្ធារាម ដែលកើតចេញពីសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទ និងសប្បុរសជនជិតឆ្ងាយ តាមរយៈការប្រតិបត្តិនូវប្រពៃណីនៃការចែករំលែក បញ្ជាក់ឱ្យឃើញកាន់តែច្បាស់ពីមនោសញ្ចេតនា សាមគ្គីភាព ឯកភាពគ្នាជាធ្លុងមួយ ដែលយើងទាំងអស់គ្នាបានខិតខំ កសាងទុកជាទីគោរពសក្ការៈដើម្បីបានជ្រកក្រោមម្លប់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ។

ឯកឧត្តមអភិបាលខេត្តបានបញ្ជាក់ ថ្ងៃនេះយើងទាំងអស់គ្នាពិតជាមានសេចក្តី សប្បាយរីករាយ ប្រកបទឹក ចិត្តជ្រះថ្លាបរិសុទ្ធក្នុងព្រះពុទ្ធសាសនា ដោយបានប្រារព្ធពិធីបុណ្យ នៅក្រោមម្លប់ដ៏ត្រជាក់នៃសន្តិភាព ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បាននាំមកនូវការអភិវឌ្ឍឥត



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*



ឯកឧត្តមអភិបាលខេត្ត ប្រគល់អនុក្រឹត្យជូនព្រះអនុគុណ

ឈប់ឈរ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខដុមរម្យនា។ ជាមួយគ្នានេះឯកឧត្តមក៏បានផ្តល់នូវអនុសាសន៍មួយចំនួន ដល់បងប្អូនប្រជាពលរដ្ឋពុទ្ធបរិស័ទទាំងអស់សូមបន្តស្មារតី ដឹងគុណនូវគោលនយោបាយឈ្នះៗ និងបន្តគាំទ្ររាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិ បណ្ឌិតរបស់សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ដោយចូលរួមក្នុងការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភានាថ្ងៃ អាទិត្យទី២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខ ដើម្បីទទួល បាននូវសុខសន្តិភាព និងការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់ វិស័យ រួមទាំងសិទ្ធសេរីភាព ជំនឿសាសនា រក្សាបាននូវ សាមគ្គីភាព ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម ដោយ មិនរើសអើង និងមិនមានការបែងចែកសង្គមជំនឿសាសនា និងនិន្នាការនយោបាយ ។

បន្ថែមពីនេះ សូមបន្តប្រពៃណីវប្បធម៌ សន្តិភាពចេះ ស្រលាញ់យោគយល់អធ្យាស្រ័យគ្នា និងរួមរស់ជាមួយគ្នា ចេះគោរពគ្នាទៅវិញទៅមក ប្រកបទៅដោយក្តីមេត្តាករុណា សណ្តោស ប្រណីរវាងសហគមន៍សាសនាផ្សេងៗ ទាំងនៅ ក្នុងថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធ្វើយ៉ាងណាឱ្យសង្គម កម្ពុជា ជាសង្គមមួយប្រកបទៅដោយសុជីវធម៌ សីលធម៌ កិរិយាធម៌ និងគុណធម៌ កើតជាមូលដ្ឋានគ្រឹះនៃគោលការ ណ៍លទ្ធិជំនឿសាសនា និងវិស័យសាសនានីមួយៗ ៕



ទិដ្ឋភាពក្នុងពិធី



ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត កាត់ខ្សែបូក្នុងពិធី



ទិដ្ឋភាពក្នុងពិធី



អ្នកចូលរួមក្នុងពិធី

# សិក្ខាសាលាស្តីពី "ដំណើរវិវឌ្ឍន៍របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន"

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម សហការជាមួយមន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ បានរៀបចំសិក្ខាសាលាស្តីពី"ដំណើរវិវឌ្ឍន៍របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន" ក្រោមអធិបតីភាព លោក **អម ពិឌី** អគ្គនាយករងជំរុញពាណិជ្ជកម្ម លោក **ផាន់ សំអាង** ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ដែលមានការចូលរួមពីសំណាក់ លោក លោកស្រី ថ្នាក់ដឹកនាំមន្ទីរអង្គភាពពាក់ព័ន្ធ ពាណិជ្ជករ អាជីវករ ធុរជន និស្សិត និងមន្ត្រីរាជការជាច្រើនរូបទៀត ។

សិក្ខាសាលានេះ បានប្រព្រឹត្តិទៅនៅសាលប្រជុំនៃមន្ទីរពាណិជ្ជកម្មខេត្ត ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ក្នុងនិងការធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងកម្ពុជាជាមួយបណ្តាប្រទេសជាមិត្ត (ថៃ-ឡាវ) ដែលជាកត្តារួមផ្សំធ្វើឱ្យកម្ពុជា រក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច បង្កើតការងារ និងកាត់បន្ថយការចំណាកស្រុក ។ ទន្ទឹមនេះដែរលោកក៏បានឱ្យដឹងថាមន្ទីរពាណិជ្ជកម្មខេត្ត បានធ្វើការចងក្រងនូវផលិតផលចំនួន ១៤មុខ ដោយបានដាក់ជូនគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ដើម្បីវាយតម្លៃ និងស្នើសុំទទួលស្គាល់ជាភូមិមួយផលិតផលមួយ របស់ខេត្ត។




*គណៈអធិបតីក្នុងពិធី*

គោលបំណងដើម្បី ផ្សព្វផ្សាអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងអនុវត្តន៍យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដែលមានទិសដៅសំខាន់គឺ ដើម្បីឱ្យកម្ពុជាទទួលបាននូវកាលានុវត្តភាពថ្មី ខាងវិនិយោគ និងធុរកិច្ចពីបរទេស និងធ្វើពិពិធ កម្មទីផ្សារទៅក្នុងខ្សែសង្វាក់ផលិតកម្មនៅក្នុងតំបន់និងពិភពលោក ។

ក្នុងឱកាសនោះ លោក **ផាន់ សំអាង** ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ក៏បានលើកឡើងអំពីស្ថានភាពការធ្វើពាណិជ្ជកម្ម ការលក់ដូរ និងការវិនិយោគតាមតំបន់ព្រំដែនពិសេសបានបង្ហាញ អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការចរចា



*លោក ផាន់ សំអាង ប្រធានមន្ទីពាណិជ្ជកម្ម*

# ពិធីសម្ពោធមន្ទីរពេហុព្យាបាល និងសម្ភពម៉ាលីសបុត្រ ខេត្តព្រះវិហារ

មន្ទីរពហុព្យាបាល និងសម្ភពម៉ាលីសបុត្រព្រះវិហារ ស្ថិតនៅក្នុងក្រុងព្រះវិហារ ត្រូវបានសម្ពោធដាក់ឲ្យដំណើរការថ្ងៃទី០២ខែមីនាឆ្នាំ២០២៣ក្រោមអធិបតីភាពឯកឧត្តម **មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនិងជាប្រធានក្រុមការងារចុះជួយខេត្តព្រះវិហារ ។ អញ្ជើញចូលរួមក្នុងពិធីនេះផងដែរ រួមមានឯកឧត្តម **សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ លោកជំទាវ **ចឹក ហេង** សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ៨ ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអភិបាលរងខេត្ត ក្រុមប្រឹក្សាខេត្ត អភិបាលក្រុងស្រុក កងកម្លាំងទាំង៣ ថ្នាក់ដឹកនាំមន្ទីរអង្គភាពជុំវិញខេត្ត និងក្រុមគ្រូពេទ្យជាច្រើនរូបផងដែរ ។

មានប្រសាសន៍នាឱកាសនោះឯកឧត្តម**សួស យ៉ារ៉ា** បានបង្ហាញនូវក្តីរំភើបសប្បាយរីករាយ នឹងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំព្រមទាំងបុគ្គលិក និងក្រុមគ្រូពេទ្យនៃមន្ទីរពហុព្យាបាល និងសម្ភពម៉ាលីសបុត្រព្រះវិហារដែលបានមកបើកដំណើរការនៅក្នុងខេត្តព្រះវិហារ។ទាំងនេះគឺពិតជាបានចូលរួមចំណែកយ៉ាងច្រើន ជាមួយថ្នាក់ដឹកនាំខេត្តព្រះវិហារ ក្នុងការបម្រើ និងផ្តល់សេវាសុខភាពសាធារណៈជូនដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងខេត្ត ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

មានមតិសំណេះសំណាល ឯកឧត្តម **មាស សុភា** បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បាននាំមកនូវសុខសន្តិភាពពេញលេញជូនជាតិមាតុភូមិ ក្រោមគោលនយោបាយឈ្នះឈ្នះរបស់សម្តេច និងបានដឹកនាំប្រទេសជាតិអោយមានការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់វិស័យ ។ ក្នុងនោះវិស័យសុខាភិបាល ពិតជាទទួលបាននូវការយកចិត្តទុកដាក់ និងអភិវឌ្ឍន៍រីកចម្រើនគួរឲ្យកត់សំគាល់ ទាំង



*គណៈអធិបតីក្នុងពិធី*



*គណៈអធិបតីអញ្ជើញកាត់ខ្សែបូរ*

វិស័យឯកជន និងរដ្ឋរហូតទទួលបានការគាំទ្រនិងជឿជាក់ពីប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងការចូលមករកសេវានៅតាមបណ្តាគ្លីនិក និងពហុព្យាបាលនៅគ្រប់ទីកន្លែង ។ សម្រាប់ខេត្តព្រះវិហារនាពេលនេះពិតជាប្រសើរខ្លាំងណាស់ដែលបានសម្ពោធដាក់ឲ្យដំណើរការ នូវមន្ទីរពហុព្យាបាល និងសម្ភពព្រះវិហារ ក្នុងការចូលរួមចំណែកបម្រើឲ្យវិស័យសុខាភិបាល ក្នុងការផ្តល់សេវាសុខភាព ជូនដល់សាធារណជននៅទូទាំងខេត្តព្រះវិហារ និងអាចស្រូបទាញយកបងប្អូនប្រជាពលរដ្ឋពីបណ្តាខេត្តផ្សេងៗទៀត ដែលពួកគាត់ស្វែងរកសេវាសុខភាពប្រកប ដោយប្រសិទ្ធភាពខ្ពស់និងជឿជាក់ ។ ក្នុងឱកាសនោះផងដែរ ឯកឧត្តមក៏បានផ្តាំផ្ញើដល់ថ្នាក់ដឹកនាំព្រមទាំងបុគ្គលិក និងគ្រូពេទ្យទាំងអស់សូមយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាសុខភាព ជូនដល់សាធារណជនដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈជាគ្រូពេទ្យ៕



ឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រី



គណៈអធិបតីថតរូបអនុស្សាវរីយ៍


គណៈអធិបតីថតរូបអនុស្សាវរីយ៍


ទិដ្ឋភាពរួមមន្ទីរពហុព្យាបាល និងសម្ភពម៉ាលីបុត្រ

# ការប្រកួតកីឡាប៊ូល និងប៉េតង់ ដណ្តើមពានរង្វាន់សហភាពសហព័ន្ធយុវជនកម្ពុជាឆ្នាំ២០២៣

ការប្រកួតកីឡាប៊ូល និងប៉េតង់ដណ្តើមពានរង្វាន់សហភាពសហព័ន្ធយុវជនកម្ពុជាឆ្នាំ២០២៣ ដែលប្រព្រឹត្តទៅរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ត្រូវបានបិទបញ្ចប់ដោយជោគជ័យ ក្រោមអធិបតីភាពឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត និងជាអនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាថ្នាក់កណ្តាល ។



គណៈអធិបតីក្នុងពិធី

ថ្លែងក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានសម្តែងការចូលរួមអបអរសាទរទៅដល់ក្រុមកីឡាករ ដែលទទួលបាននូវជ័យលាភី និងកោតសរសើរដល់ក្រុមកីឡាករទាំងអស់ដែលបានចូល រួមប្រកួត ដើម្បីលើកស្ទួយវិស័យសុខុមាលភាព ចំណងសាមគ្គីភាព មិត្តភាព សុខភាព និងបញ្ចេញនូវទេពកោសល្យរបស់ខ្លួន តាមរយៈការប្រកួតយ៉ាងសប្បាយរីករាយនេះ ។

ទន្ទឹមនេះ ឯកឧត្តមក៏បានជំរុញលើកទឹកចិត្តដល់បងប្អូនកីឡាករទាំងអស់ឱ្យបន្តពង្រឹង ការហ្វឹកហាត់ប្រកបដោយគុណភាព គុណផល និងបច្ចេកទេសដោយតម្រូវឱ្យមានការប្រកួតប្រជែងជាប្រចាំ ដើម្បីជាការវាស់ស្ទង់កម្រិតសមត្ថភាព ព្រមទាំងដកស្រង់បទពិសោធន៍ពីដៃគូ ប្រកួតរបស់ខ្លួន ដើម្បីបន្តជុសខាត់សមត្ថភាពសម្រាប់ការប្រកួតនាពេលបន្តបន្ទាប់ ។

សូមបញ្ជាក់ជូនថា កម្មវិធីប្រកួតកីឡាប៊ូល និងប៉េតង់ ដណ្តើមពានរង្វាន់សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តព្រះវិហារ ឆ្នាំ២០២៣ មានកីឡាករចូលរួមប្រកួតចំនួន ២៣ក្រុម មកពី៨ ក្រុង-ស្រុក និងមន្ទីរអង្គភាពមួយចំនួន



អភិបាលខេត្តប្រគល់ពានរង្វាន់ជ័យលាភីលេខ១

ដែលមានប្រតិភូ គ្រូបង្វឹក និងកីឡាករសរុបចំនួន១១៥ នាក់ ។

ឆ្លងកាត់ការប្រកួតរយៈពេល០២ថ្ងៃ ជាលទ្ធផលការប្រកួតរកឃើញនូវជ័យលាភីចំណាត់ ថ្នាក់លេខ១ បានទៅលើក្រុមកីឡាករ ស.ស.យ.ក ស្រុកសង្គមថ្មី, ចំណាត់ថ្នាក់លេខ២ បានទៅក្រុមកីឡាករ ស.ស.យ.ក ស្រុកគូលែន និងចំណាត់ថ្នាក់លេខ៣ បានទៅលើក្រុមកីឡាករ ស.ស.យ.ក វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសជាស៊ីម ត្បែងមានជ័យ។ ក្នុងនោះរង្វាន់ ជ័យលាភីលេខ១ ទទួលបានពានរង្វាន់ចំនួន១ ទង់ជ័យលាភី លិខិតថ្លែងអំណរគុណ និងទឹកប្រាក់ចំនួន ៨០ម៉ឺនរៀល, លេខ២ ទទួលបានទង់ជ័យលាភី លិខិតថ្លែងអំណរគុណ និងទឹក ប្រាក់ ៦០ម៉ឺនរៀល និង លេខ៣ ទទួលបានទង់ជ័យលាភី លិខិតថ្លែងអំណរគុណ និងទឹកប្រាក់ ៤០ម៉ឺនរៀល ៕



គណៈអធិបតីក្នុងពិធី



គណៈអធិបតីក្នុងពិធី



អ្នកចូលរួមក្នុងពិធី



កីឡាករប្រកួត



កីឡាករប្រកួត



កីឡាករប្រកួត

បីជាស្ថិតនៅក្នុងតម្លៃណាក៏ដោយ ត្រូវការពារព្រះមហាក្សត្រ និងរាជរដ្ឋាភិបាលស្របច្បាប់ ដែលបានដឹកនាំកម្ពុជាទទួលបាននូវសុខសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ។

សូមបញ្ជាក់ថា៖ រយៈពេលហ្វឹកហ្វឺនមានចំនួន១៥ថ្ងៃ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ។ ក្នុងនោះពេលវេលារៀនសូត្រជាក់ស្តែងចំនួន ១០ថ្ងៃ ស្មើនឹង ៦០ម៉ោង ដោយឈប់សម្រាកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ នឹងថ្ងៃបើកនិងបិទវគ្គចំនួន ០៥ថ្ងៃ ។



គណៈអធិបតីក្នុងពិធី



កងកម្លាំងចូលរួមក្នុងពិធី




សកម្មភាពក្នុងពិធីបិទវគ្គ




សកម្មភាពក្នុងពិធីបិទវគ្គ

# សមាគមន៍នារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តបានចុះជួបសំណេះសំណាល ជាមួយសិស្សានុសិស្ស នៅសាលាបឋមសិក្សាអភិវឌ្ឍន៍យុវជន



លោកជំទាវ សុខា គងពិសី ប្រធានកត្តិយសសមាគមន៍

នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ សមាគមន៍នារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តព្រះវិហារ ក្រោមការដឹកនាំរបស់លោកជំទាវ **សុខា គងពិសី** ជាប្រធានកត្តិយសសមាគមន៍ និងមានការអញ្ជើញដោយឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានដឹកនាំក្រុមការងារចុះជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមាតាបិតាអាណាព្យាបាលសិស្ស នៅសាលាបឋមសិក្សាអភិវឌ្ឍន៍យុវជន ស្ថិតនៅក្នុងភូមិអភិវឌ្ឍន៍ សង្កាត់ប៉ាលហាល ក្រុងព្រះ វិហារ ខេត្តព្រះវិហារ ។

មានប្រសាសន៍ទៅកាន់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សព្រម ទាំងអាណាព្យាបាលនាឱកាស នោះ លោកជំទាវ**សុខា គងពិសី** បានបង្ហាញនូវក្តីសប្បាយរីករាយប្រកបដោយមនោសញ្ចេតនា យ៉ាងជ្រាលជ្រៅ និង ទទួលបាននូវការស្វាគមន៍យ៉ាងរាក់ទាក់ និងកក់ក្តៅពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងអាណាព្យាបាលសិស្ស ។ លោកជំទាវក៏បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធ បណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ដែលជានិច្ចកាលសម្តេច តែងតែបានយកចិត្តទុកដាក់គិតគូរ អំពីសុខទុក្ខរបស់បងប្អូន ប្រជាពលរដ្ឋនៅ គ្រប់ទីកន្លែងដោយមិនប្រកាន់និន្នាការ នយោបាយ ឬសាសនាអ្វីឡើយ ។

មានមតិសំណេះសំណាលនាឱកាសនោះឯកឧត្តម **គីម រិទ្ធី** បានឲ្យដឹងថាថ្ងៃនេះសមាគមន៍នារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្ត ក្រោមការដឹកនាំរបស់លោកជំទាវ **សុខា គងពិសី** ជាប្រធានកិត្តយសសមាគមន៍នារីខេត្តព្រះវិហារក្នុងឱកាសនៃទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា ឆ្នាំ២០២៣



គណៈអធិបតីក្នុងពិធី

ចុះជួបសំណេះសំណាល និងសួរសុខទុក្ខព្រមទាំងបាននាំយកអំណោយរបស់សម្តេចទាំងទ្វេ ដែលមានជាសម្ភារៈសិក្សា និងថវិការមួយចំនួនជូនដល់សិស្សានុសិស្ស នៅក្នុងសាលាបឋមសិក្សាយុវជនអភិវឌ្ឍន៍សរុបជាង ១០០នាក់ ។ ទាំង នេះ ពិតជាសបញ្ជាក់ឲ្យឃើញពីការយកចិត្តទុកដាក់គិតគូរ ដល់សុខទុក្ខរបស់ប្រជាពលរដ្ឋពីសំណាក់សម្តេចទាំងពីរ ។ ដូចនេះ ឯកឧត្តមបានសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់បន្តគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចជាបន្តទៀត ៕



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ពិធីចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ របស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ឯកឧត្តម ហ៊ុន ម៉ានី




*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៣ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ឯកឧត្តម **ហ៊ុន ម៉ានី** សហការជាមួយមន្ទីរសុខាភិបាលខេត្ត បានចុះពិនិត្យព្យាបាលជំងឺដោយឥតគិត ថ្លៃជូនដល់បងប្អូនប្រជាពលរដ្ឋនៅឃុំចំនួន៤ ក្នុងស្រុកចំនួន០២ ស្ថិតក្នុងខេត្តព្រះវិហារ ក្រោមការចូលរួមនិងបើកយុទ្ធនាការដោយឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្ត ដែលមានវត្តមានចូលរួមនាឱកាសនោះរួមមាន ឯកឧត្តម លោកជំទាវ លោក លោកស្រីជាអភិបាលរងខេត្ត អភិបាល និងអភិបាលរងស្រុកទាំង០២ ក្រុមការងារចុះជួយឃុំសហភាពសហព័ន្ធយុវជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋមកពីឃុំទាំង០៤ ជាច្រើនរូប ដែលពិធីនេះប្រព្រឹត្តធ្វើឡើងនៅក្នុងបរិវេណសាលាបឋមសិក្សាព្រះឃ្លាំង ស្ថិតក្នុង ភូមិអន្លង់ស្វាយ ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

មានប្រសាសន៍ទៅកាន់បងប្អូនលោកយាយ លោកតានាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានឲ្យដឹងថាថ្ងៃនេះ ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់ និងអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការអប់រំយុវជនកីឡា ធម្មការកិច្ចការសាសនាវប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា និងជាប្រធានកិត្តិយសក្រុមគ្រូពេទ្យស្ម័គ្រចិត្ត បានចង្អុលបង្ហាញដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ឯកឧត្តម **ហ៊ុន ម៉ានី** ខេត្តព្រះវិហារ សហការជាមួយមន្ទីរសុខាភិបាលខេត្ត ចុះពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃ ជូនដល់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះវិហារ ដែលនេះគឺជាការបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ ទៅលើសុខុមាលភាពរបស់ប្រជាពលរដ្ឋដោយពុំមានការរើសអើង ។ ឯកឧត្តមក៏បានផ្តាំផ្ញើរឲ្យបងប្អូនមេត្តាយកចិត្តទុកដាក់ថែរក្សាសុខភាពរបស់ខ្លួនឲ្យបានល្អ និងបានអញ្ជើញចុះពិនិត្យមើលការ ពិនិត្យនិងព្យាបាលដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋ ទៅតាមផ្នែកនីមួយៗ នៃជំនាញ



*គណៈអធិបតីក្នុងពិធី*

របស់ក្រុមគ្រូពេទ្យ ។

យោងតាមរបាយការណ៍លទ្ធផលរបស់ ឯកឧត្តម **គួង ឡូ** ប្រធានមន្ទីរសុខាភិបាលខេត្ត និងជាប្រធានប្រតិបត្តិក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ឯកឧត្តម **ហ៊ុន ម៉ានី** ខេត្តព្រះវិហារ បានឲ្យដឹងថា ប្រជាពលរដ្ឋដែលបានអញ្ជើញមកទទួលយកការពិនិត្យ និងព្យាបាលពីក្រុមគ្រូពេទ្យស្ម័គ្រចិត្តនាថ្ងៃនេះមានចំនួនសរុប ៦០៩នាក់ ក្នុងនោះស្រី ៣៧៣នាក់មកពីឃុំចំនួន០៤ ក្នុងស្រុក០២ រួមមាន ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ និងឃុំរក្សា ឃុំរំដោះ ឃុំរមទម ស្ថិតក្នុងស្រុករវៀង ខេត្តព្រះវិហារ ។ សម្រាប់ក្រុមគ្រូពេទ្យដែលបានចូលរួមក្នុងឱកាសនេះសរុប ចំនួន ១៥១នាក់ និងបានបែងចែកជា ១៦ក្រុម ។ លទ្ធផលទទួលបានរួមមានផ្នែកអេកូសាស្ត្រ មាន ចំនួន ៤២នាក់ ស្រី ៣៤នាក់ ផ្នែកវះកាត់តូច ចំនួន ១៣ នាក់ស្រី ០៧ ផ្នែកជំងឺកុមារ ២៩នាក់ស្រី ១៤នាក់ផ្នែកជំងឺទូទៅ ១៧៣នាក់ ស្រី ៨៩នាក់ ផ្នែកជំងឺទឹកនោមផ្អែម និងលើសសម្ពាធឈាម ៨២នាក់ ស្រី ៧១នាក់ ផ្នែកសុខភាពផ្លូវចិត្ត ២៣នាក់ ស្រី ២២នាក់ ផ្នែកត្រចៀក ច្រមុះ បំពង់ក ២៥នាក់ ស្រី ១៤នាក់ ផ្នែកសុខភាពមាត់ធ្មេញ ១៨ នាក់ ស្រី០៩ ផ្នែកសម្ភពនិងរោគស្ត្រី ៤១ករណី ផ្នែកចក្ខុរោគ ១៤៣នាក់ ស្រី ៨១នាក់ ផ្នែកផ្តល់វ៉ាក់សាំងកូវីដ១៩ ចំនួន ២០នាក់ ស្រី ០៩នាក់ ក្នុងនោះករណី បញ្ជូនមាន ០២ករណី គឺផ្នែកជំងឺទូទៅ ០១នាក់ប្រុស និងផ្នែកអេកូសាស្ត្រ ០១នាក់ស្រី ៕





គណៈអធិបតីក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ប្រជាពលរដ្ឋងាយរងគ្រោះចំនួន ៥០០គ្រួសារ ស្ថិតក្នុងស្រុកចំនួន០២ ទទួលបានអំណោយពីរាជរដ្ឋាភិបាល

ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ស្ថិតនៅក្នុងស្រុកចំនួន០២ គឺស្រុកឆែប និងស្រុកជ័យសែន ខេត្តព្រះវិហារ មានរៀបចំពិធីចែកអំណោយរបស់រាជរដ្ឋាភិបាល ដល់ប្រជាពលរដ្ឋងាយរងគ្រោះ សរុបចំនួន ៥០០គ្រួសារ ក្នុងនោះស្រុកឆែប ២០០គ្រួសារ និងស្រុកជ័យសែន ៣០០គ្រួសារ ក្រោមអធិបតីភាពឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ ពិធីនេះ ក៏មានការចូលរួមពីសំណាក់អភិបាលរងខេត្ត ថ្នាក់ដឹកនាំមន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋជាច្រើនរូបផងដែរ ដែលប្រារព្ធធ្វើឡើងនៅក្នុងបរិវេណសាលាស្រុកនៃស្រុកទាំង០២ ។



មានប្រសាសន៍ទៅកាន់បងប្អូនប្រជាពលរដ្ឋ នៅក្នុងឱកាសនោះឯកឧត្តម **គីម រិទ្ធី** បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដែលបានផ្តាំផ្ញើក្តីនឹករឮកការស្រឡាញ់យ៉ាងជ្រាលជ្រៅ និងគិតគូរជានិច្ចចំពោះសុខទុក្ខបងប្អូនប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ពិសេសប្រជាពលរដ្ឋដែលរងគ្រោះដោយសារគ្រោះធម្មជាតិ ស្ត្រីមេម៉ាយ ជនពិការ ចាស់ជរានិងប្រជាពលរដ្ឋដែលទីទាល់ក្រ ជួបការលំបាកដោយមិនប្រកាន់រើសអើងវណ្ណៈ ជាតិសាសន៍ ពណ៌សម្បុរ ឬនិន្នាការ



គណៈអធិបតីក្នុងពិធី



ទិដ្ឋភាពក្នុងពិធី

នយោបាយអ្វីឡើយ។ជាមួយនេះឯកឧត្តមក៏បានផ្តាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ឱ្យបន្តការយកចិត្តទុកដាក់ថែទាំសុខភាព ព្រមទាំងប្រកាន់ខ្ជាប់នូវអនាម័យល្អរស់នៅស្អាត ហូបស្អាត ផឹកស្អាត នឹងខិតខំបង្កបង្កើនផល ដើម្បីទ្រទ្រង់ជីវភាពគ្រួសារត្រូវខិតខំចិញ្ចឹមសត្វ និងដាំដុះដំណាំរួមផ្សំផ្សេងៗបន្ថែមទៀត ខណៈរដូវវស្សាក៏បានដល់ដើម្បីធ្វើយ៉ាងណាឱ្យជីវភាពរស់នៅមានលក្ខណៈសមរម្យ ក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន ។



*ប្រតិភូអមដំណើរ*

តាមរបាយការណ៍របស់លោក **រស់ ស៊ីផា** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានឱ្យដឹងថាការចែកអំណោយនេះ គឺដើម្បីរួមចំណែកក្នុងការ



*គណៈអធិបតីចែកអំណោយជូនប្រជាពលរដ្ឋ*



*ប្រតិភូអមដំណើរ*

លើកកំពស់សុខុមាលភាពប្រជាពលរដ្ឋ ជាពិសេសជនរងគ្រោះ និងងាយរងគ្រោះដោយធម្មជាតិ ដែលជាទិសដៅរបស់ក្រសួង បានដាក់ចេញជាយុទ្ធសាស្ត្រសម្រាប់អនុវត្តដោយផ្តោតលើកម្មវិធី និងអនុកម្មវិធីចំនួន០៤ ។ ជាក់ស្តែងនាពេលនេះប្រជាពលរដ្ឋចំនួន ២០០គ្រួសារ មកពី ០៨ឃុំ ក្នុង ០១ឃុំ ២៥គ្រួសារ ក្នុងស្រុកឆែប និង៣០០ គ្រួសារ មកពី ០៦ឃុំ ក្នុង ០១ឃុំ ៥០គ្រួសារក្នុងស្រុកជ័យសែន ដោយក្នុង០១គ្រួសារៗទទួលបាន៖អង្ករ ០១បេ,ទឹកសុីអុីវ ០១យួរ,ស្ករស០១ថង់,ប្រេងឆា ០១ដប,និងមុង០១ ៕

# ពិធីអបអរសាទរទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៦ ឆ្នាំ២០២៣

ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២៣ នៅវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ បានរៀបចំពិធីអបអរសាទរទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៦ ឆ្នាំ២០២៣ក្រោមប្រធានបទ"TVETផ្តល់ជំនាញ និងការងារសមរម្យ" ក្រោមអធិបតីភាពលោក **ឃឹម បញ្ញា** អភិបាលរងនៃគណៈអភិបាលខេត្ត និងជាអនុប្រធានគណៈកម្មាធិការបណ្ដុះបណ្ដាលខេត្ត និងមានការអញ្ជើញចូលរួមពីសំណាក់ប្រធាន អនុប្រធានមន្ទីរអង្គភាពជុំវិញខេត្ត អភិបាល អភិបាលរងក្រុង-ស្រុក មេឃុំ ចៅសង្កាត់ សហគ្រាសឯកជន អង្គការដៃគូអភិវឌ្ឍនានា នាយកវិទ្យាស្ថាន លោកគ្រូ អ្នកគ្រូ សិក្ខាកាម សិស្សា-នុសិស្សយ៉ាងច្រើនកុះករ ។



លោក ឃឹម បញ្ញា អភិបាលរងខេត្ត

លោក **តាំង ហ៊ុល** នាយកវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ បានអានរបាយការណ៍ឲ្យដឹងថាក្នុងឆ្នាំ២០២២ វិទ្យាស្ថានបានធ្វើការបណ្ដុះបណ្ដាលទទួលបានលទ្ធផល មានដូចជាការសិក្សាថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣(C3) រយៈពេល ១ឆ្នាំ សរុប ចំនួន ១៨នាក់ ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១(C1)រយៈពេល១ឆ្នាំ សរុបចំនួន ៧៩នាក់ ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ(C1)ពិសេស រយៈពេល ៤ខែ មានចំនួន ៨០នាក់ ថ្នាក់វិញ្ញាបនបត្រ( គម្រោងSAAMBAT )សិក្សារយៈពេល ៦ខែ សរុបចំនួន ៩០នាក់ថ្នាក់វិញ្ញាបនបត្រផ្នែកសេវាកម្មសិក្សារយៈពេលចំនួន ៤ខែ សរុបចំនួន ៩០នាក់ ថ្នាក់វិញ្ញាបនបត្រផ្នែកកសិកម្មសិក្សារយៈពេលចំនួន១ សប្តាហ៍សរុបចំនួន ៨០នាក់ ។ ដោយឡែកសម្រាប់ សម្រាប់ឆ្នាំ២០២៣ នេះវិទ្យាស្ថានបាននឹងកំពុងដំណើរការលើថ្នាក់ សញ្ញាបត្រ




គណៈអធិបតីក្នុងពិធី

ជាន់ខ្ពស់បច្ចេកទេស( បរិញ្ញាបត្ររងលើជំនាញបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យា មាននិស្សិតចំនួន ២៥នាក់ជំនាញអគ្គិសនីមាននិស្សិតចំនួន ២៥នាក់,សិស្សកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២(រយៈពេល១ឆ្នាំ)សរុបចំនួន២៥នាក់,សិស្សកម្រិតសញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ១(រយៈពេល១ឆ្នាំ)សរុបចំនួន ១១៩នាក់ និងសិក្ខាកាមវគ្គខ្លី(រយៈពេល០៧ខែ)មានចំនួនសរុបចំនួ ៤២នាក់ ។

បន្ទាប់ពីអានសារលិខិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋ មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួចមក លោក **ឃឹម បញ្ញា** អភិបាលរងខេត្តបានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី១៥ ខែមិថុនាជារៀងរាល់ឆ្នាំ ជាទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈក្នុងគោលបំណងលើកកម្ពស់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងធ្វើការផ្សព្វ



លោក តាំង ហ៊ុល នាយកវិទ្យាស្ថានពហុបច្ចេកទេស

ផ្សាយទៅដល់សិស្សានុសិស្ស និស្សិត យុវជន មាតាបិតា អាណាព្យា បាល កម្មករនិយោជិត និយោជក និងផ្នែកឯកជនព្រមទាំងសាធារណជនឱ្យបានយល់ដឹង កាន់តែច្បាស់អំពីសារៈសំខាន់ នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការអភិវឌ្ឍកម្លាំងពលកម្មជំនាញប្រកដោយគុណភាព និងប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។ លោកបានបន្តថាដើម្បីចូលរួម សម្រេចឱ្យបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជា ណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសការកសាងបាននូវកម្លាំងពលកម្ម ជំនាញ គំនិតច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ដើម្បីជានាថា "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត" ។

សូមបញ្ជាក់ផងដែរថា ពិធីនេះក៏មានការរៀបចំឲ្យមានការដាក់តាំងពិព័រណ៍ស្នាដៃ និងផលិតផល ដែលមានស្តង់ចូលរួមដូចជា៖ វិទ្យាស្ថានមានចំនួន ៨ស្តង់, មន្ទីរអប់រំ យុវជន និង កីឡាមានចំនួន២ស្តង់,មន្ទីរទេសចរណ៍ ២ស្តង់, មន្ទីរកិច្ចការនារី ២ស្តង់,មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ១ស្តង់, វិទ្យាស្ថាន និងបច្ចេកទេសនៃកម្ពុជា ១ ស្តង់, ក្រុមហ៊ុនគូបូតាកម្ពុជាចំនួន ២ ស្តង់, ក្រុមហ៊ុនហុងដា សាខា ខេត្តព្រះវិហារ ៣ស្តង់ ៕



គណៈអធិបតីពិនិត្យស្តង់ពិព័រណ៍



គណៈអធិបតីពិនិត្យស្តង់ពិព័រណ៍



គណៈអធិបតីប្រគល់រទេះរុញជូនជនពិការ

# ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម ចុះទស្សនកិច្ចក្រុមហ៊ុន ស៊ី.អេ.ឌី.អាយ ខូ អិលធីឌី



គណៈអធិបតីក្នុងពិធី

មានប្រសាសន៍ ក្នុងដំណើរទស្សនកិច្ច និងសំណេះសំណាលជាមួយតំណាងក្រុមហ៊ុន និងបុគ្គលិក-កម្មករ នៅក្រុមហ៊ុនវិនិយោគដំណាំ កសិ-ឧស្សាហកម្ម ស៊ី.អេ.ឌី.អាយ លើដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋ ជាង ៨ពាន់ហិកតា ស្ថិតនៅក្នុង ស្រុករវៀង ខេត្តព្រះវិហារ នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគូសបញ្ជាក់ថា គោលដៅសំខាន់របស់រដ្ឋាភិបាល ក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច ទៅឱ្យក្រុមហ៊ុន គឺដើម្បីអភិវឌ្ឍន៍ឱ្យរីកចម្រើនកាន់តែខ្លាំងលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងការចិញ្ចឹមសត្វជា



គណៈអធិបតីថតរូបអនុស្សាវរីយ៍

ដើមឱ្យក្លាយជាកន្លែងផលិតដែលមិនត្រឹម តែសម្រាប់ការផ្គត់ផ្គង់នៅក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ការនាំចេញទៅក្រៅប្រទេសផងដែរ ។

ឯកឧត្តមក៏បានជំរុញឲ្យគ្រប់ភាគីពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ត្រូវពង្រឹងការការពារដីវិនិ យោគរបស់ក្រុមហ៊ុន ដែលជាដីរបស់រដ្ឋ កុំឲ្យប្រឈមនឹងការចូលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍លើដីសម្បទានសេដ្ឋកិច្ច ទៅតាមផែនការកំណត់របស់រាជរដ្ឋាភិបាល ។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានអញ្ជើញទៅពិនិត្យការសាងសង់ឃ្លាំងស្តុក និងម៉ាស៊ីនកែច្នៃផលពោត ដែលប្រមូលបាន និងស្វែងយល់ពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធដាំដុះ ប្រព័ន្ធស្រោចស្រពទឹក ការប្រើប្រាស់គ្រឿងចក្រដើរដោយប្រព័ន្ធបច្ចេកវិទ្យាស្វ័យប្រវត្តិដូចជា ត្រាក់ទ័រ យន្តហោះដ្រូន ដើម្បីប្រតិបត្តិការស្រោចស្រពទឹកដាក់ជីបាញ់ថ្នាំការពារសត្វល្អិតចង្រៃ ព្យាបាលជំងឺដំណាំ និងប្រមូលផលដោយការប្រើប្រាស់គ្រឿងចក្រស្វ័យប្រវត្តិ ព្រមទាំងមធ្យោបាយដាំដុះដំណាំ ដែលអាចរក្សាគុណភាពដីប្រកបដោយនិរន្តរភាពផងដែរ ។ ជាមួយគ្នានោះ ឯកឧត្តមបានសម្តែងការចាប់

អារម្មណ៍ខ្ពស់ ចំពោះការដាំសណ្ដែកសៀង ដែលកំពុងមានទីផ្សារខ្ពស់ និងអាចជួយបង្កើនគុណភាពដីសម្រាប់ការដាំដំណាំផ្សេងទៀតដូចជាពោតជាដើម ។

សូមបញ្ជាក់ថា បច្ចុប្បន្នក្រុមហ៊ុន ស៊ី.អេ.ឌី.អាយ កំពុងវិនិយោគលើដំណាំពោត សណ្ដែក សៀង និងដំឡូងមី ដើម្បីកែច្នៃមុននឹងធ្វើការនាំចេញ ដែលបានសហការវិនិយោគជាមួយក្រុម ហ៊ុន ស៊ីភី គ្រុប ជាក្រុមហ៊ុនដ៏ធំមួយដែលមានភាពជោគជ័យខ្ពស់ក្នុងការនាំយកវត្ថុធាតុដើម ទៅកែច្នៃផលិតជាចំណីសត្វ ដើម្បីនាំចេញទៅលក់លើទីផ្សារនៅក្នុងតម្លៃសមរម្យ ដើម្បីជួយបង្កើននូវកំណើនសេដ្ឋកិច្ចជាតិ



គណៈអធិបតីពិនិត្យដំណាំសណ្ដែកសៀង



គណៈអធិបតីថតរូបអនុស្សាវរីយ៍

កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការបង្កើនប្រាក់ចំណូលផ្ទាល់ដល់ក្រុមសហគមន៍ជាអ្នកផលិត ។

ក្រោយបញ្ចប់ដំណើរទស្សនកិច្ចក្រុមហ៊ុនស៊ី.អេ.ឌី.អាយ ឯកឧត្តមរដ្ឋមន្ត្រីបានបន្ត ដំណើរ ចុះសិក្សាស្វែងយល់អំពីខ្សែសង្វាក់ផលិតកម្ម នៃការកែច្នៃគ្រាប់ស្វាយចន្ទីរបស់ក្រុមហ៊ុនសានតាណា អាគ្រូ ប្រដាក លីមីតធីត ដែលជាក្រុមហ៊ុនដ៏ធំមួយ បាននិងកំពុងមានសកម្មភាពយ៉ាងមមាញឹកក្នុងការកែច្នៃ វេចខ្ចប់គ្រាប់ស្វាយចន្ទីសម្រាប់ផ្គត់ផ្គង់ទៅកាន់ទីផ្សារប្រទេសចិន ៕



ដំណាំពោតក្នុងក្រុមហ៊ុនស៊ី.អេ.ឌី.អាយ (CADI)

# ពិធីប្រកាសតែងតាំងប្រធានមន្ទីរផែនការខេត្ត



*ទិដ្ឋភាពរួមក្នុងពិធី*

ថ្ងៃទី២៩ខែមិថុនាឆ្នាំ២០២៣ស្ថិតនៅអគារសាលាខេត្តជាន់ទី៣ មានរៀបចំពិធីប្រកាសតែងតាំងប្រធានមន្ទីរផែនការខេត្តព្រះវិហារ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ដែលពិធីនេះ មានវត្តមានចូលរួមពីសំណាក់ឯកឧត្តមជាគណៈប្រតិភូអមដំណើរ ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត ព្រមទាំងលោក លោកស្រីជាអភិបាលក្រុង-ស្រុក ថ្នាក់ដឹកនាំកងកម្លាំងទាំង៣មន្ទីរអង្គភាពជុំវិញខេត្ត មន្ត្រីរាជការនៃមន្ទីរផែនការខេត្តជាច្រើនរូបផងដែរ ។



*គណៈប្រគល់សេចក្តីប្រកាសជូនប្រធានមន្ទីរ*

បន្ទាប់ពីទទួលបានសេចក្តីប្រកាស និងត្រាពីឯកឧត្តមទេសរដ្ឋមន្ត្រី រួចមកលោកស្រី **ស៊ាន សុគីន** ប្រធានមន្ទីរផែនការដែលទើបតែងតាំងថ្មី ក៏បានឡើងប្តេជ្ញាចិត្ត និងបង្ហាញនូវក្តីសោមនស្សសប្បាយរីករាយ ដែលទទួលបាននូវការផ្តល់សេចក្តីទុកចិត្តពីថ្នាក់ដឹកនាំខេត្ត និងក្រសួងក្នុងការតែងតាំង លោកស្រីជាប្រធានមន្ទីរផែនការខេត្តព្រះវិហារនាពេលនេះ ។ លោកស្រីក៏បាន ប្តេជ្ញាគោរពប្រតិបត្តិដោយភក្តីភាពចំពោះបាវចនាជាតិ សាសនា ព្រះមហាក្សត្រ និងប្តេជ្ញាគោរពប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ ស្របទៅតាមច្បាប់បទបញ្ញាលិខិតបទដ្ឋានគតិយុត្ត ជាធរមាន ព្រមទាំងប្តេជ្ញាចូលរួមថែរក្សាការពារ សន្តិភាព កេរ្តិ៍ដំណែល សមិទ្ធផលដែលមាន



*លោកស្រី ស៊ាន សុគីន ប្រធានមន្ទីរផែនការ*



គណៈអធិបតីក្នុងពិធី



ប្រតិភូចូលរួមក្នុងពិធី

សព្វថ្ងៃឲ្យស្ថិតស្ថេរគង់វង្សជារៀងរហូត ។ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្ត និងគោរពតាមគោលការណ៍ណែនាំរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បង្កើនសាមគ្គីភាពផ្ទៃក្នុង ខិតខំបំពេញការងារតាមតួនាទីភារកិច្ច សហការជាមួយមន្ត្រីតាមការិយាល័យជំនាញក្នុងការសិក្សាស្វែងយល់ ពីការវិវឌ្ឍន៍នៃប្រព័ន្ធបច្ចេកវិទ្យា ថ្មីៗដើម្បីជំរុញការងារ ក្នុងមន្ទីរឲ្យកាន់តែប្រសើរ និងបន្តកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ មន្ទីរអង្គភាពជំនាញរដ្ឋបាលក្រុង ស្រុក ដើម្បីទទួលបានជោគជ័យនូវផែនការដែលថ្នាក់ដឹកនាំប្រគល់ជូន ។

មានប្រសាសន៍នាឱកាសនោះ លោក **មិន ស៊ីថា** អភិបាលរងខេត្តព្រះវិហារ បានសម្តែងនូវការចូលរួមអបអរសាទរចំពោះលោកស្រីប្រធានមន្ទីរផែនការខេត្ត ដែលទើបបានតែងតាំងថ្មី និងបានថ្លែងកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ លោក **សេខ ប៊ុនរឿន** អតីតប្រធានមន្ទីរផែនការចាស់ដែលកន្លងមក លោកបានខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចបានយ៉ាងល្អប្រសើរ និងទទួលបានការគោរពស្រលាញ់ពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** បានផ្តាំផ្ញើនិងជំរុញទៅដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរផែនការខេត្តពិសេសប្រធានមន្ទីរដែលទើបទទួលបានការតែងតាំងថ្មី ត្រូវខិតខំយកចិត្តទុកដាក់ដឹកនាំគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ បន្ថែមពីនេះត្រូវមានសាមគ្គីភាព ឯកភាពផ្ទៃក្នុងឲ្យបានល្អ ទាំងក្នុងមន្ទីរក៏ដូចជាតាមបណ្តាអង្គភាពដែលស្ថិតនៅក្រោមឱវាទរដ្ឋបាលខេត្តព្រះវិហារ ទាំងមូលឱ្យបានទូលំទូលាយ និងទទួលបានជោគជ័យរាល់ភារៈកិច្ច និងកាតព្វកិច្ចដែលថ្នាក់ដឹកនាំបានប្រគល់ជូន ជាពិសេសលើវិស័យផែនការ និងស្ថិតិ ៕



ប្រតិភូចូលរួមក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# អាជ្ញាធរជាតិព្រះវិហារ ប្រារព្ធពិធីអបអរសាទរខួបទី ១៥ឆ្នាំ នៃការចុះប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក



គណៈអធិបតីក្នុងពិធី

ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ អាជ្ញាធរជាតិព្រះវិហារ បានរៀបចំប្រារព្ធពិធីអបអរសាទរខួបទី ១៥ឆ្នាំ នៃការចុះប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោក ជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម **កុល ប៊ុនលី** រដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង ដែលមានការចូលរួមពី ឯកឧត្តមអ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ អភិបាលខេត្តព្រះវិហារ,តំណាងអង្គការយូណេស្កូ ,បណ្ដាអង្គទូតឥណ្ឌា អាមេរិក ចិន ជប៉ុន បារាំង ដែលជាសមាជិក (ICC PREAH VIHEAR), អាជ្ញាធរជាតិ អប្សរា, មន្ត្រីជាន់ខ្ពស់ថ្នាក់ជាតិ ព្រមទាំងកងកម្លាំង ប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅខេត្តព្រះវិហារ សរុបប្រមាណជាង ១២០០នាក់ ។

ឯកឧត្តម **គង់ ពុទ្ធិកា** អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ បានអានរបាយការណ៍ឲ្យដឹងថាប្រាសាទព្រះវិហារ ជាទីគោរពសក្ការៈបានប្រតិស្ឋានជំទើតយ៉ាងឆើតឆាយនៅលើកំពូលចំណោតភ្នំដ៏ខ្ពស់នៃជួរភ្នំដងរែក ដែលត្រូវបានធ្លាប់ឱ្យឈ្មោះថាជាភ្នំកំផែង ឬ ជញ្ជាំងភ្នំ បរិវេណរបស់ប្រាសាទនេះជាតំណាងឱ្យបទដ្ឋានផ្នែក ដួងព្រលឹង ផ្លូវចិត្ត និងសម្ភារ នៃអារ្យធម៌សម័យអង្គរដ៏មហារុងរឿង ហើយត្រូវបានក្លាយជាបេតិកភណ្ឌពិភព លោក នាសម័យប្រជុំពេញអង្គលើកទី៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៃអង្គការយូណេស្កូ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិច ប្រទេសកាណាដា ដោយសារថាប្រាសាទព្រះវិហារជា មហាស្នាដៃស្ថាបត្យកម្មដ៏លេចធ្លោរបស់ខ្មែរ ប្រាសាទនេះមានភាពបរិសុទ្ធ ទាំងផ្នែករៀបចំប្លង់


គណៈអធិបតីក្នុងពិធី

និងទាំងភាពលម្អិតនៅក្នុងក្បាច់រចនាតុបតែង ។

ឯកឧត្តមបានបន្ថែមថាក្នុងរយៈពេល ១៥ឆ្នាំកន្លងទៅនេះតំបន់ប្រាសាទព្រះវិហារត្រូវបាន ប្រែក្លាយពីតំបន់ដាច់ស្រយាល រងគ្រោះដោយសង្គ្រាមរាំរ៉ៃ គ្មានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ គ្មានសាលារៀន គ្មានមណ្ឌលសុខភាពទៅជាតំបន់ដ៏ស្រស់បំព្រងមួយប្រកបដោយ សុខដុមរមនាដោយសារសមិទ្ធិផលនានារបស់រាជរដ្ឋាភិបាលដូចជា៖ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ ជាពិសេសការកសាងផ្លូវឡើងប្រាសាទព្រះវិហារ ដោយមូលនិធិបាយន័ និងការកសាងជណ្ដើរឈើប្រវែង ១៥០០ម៉ែត្រ ស្របតាមជណ្ដើរ បុរាណខាងកើត សាងសង់សាលារៀន មណ្ឌលសុខភាព កសាងសារមន្ទីរធម្មជាតិសកលសម្ដេចតេជោ **ហ៊ុន សែន** ព្រះវិហារ ដើម្បីជាកន្លែងរក្សាទុកនូវវត្ថុសិល្បៈ ដែលរកឃើញនៅជុំវិញ



គណៈអធិបតីក្នុងពិធី

ប្រាសាទព្រះវិហារ បង្ហាញនូវប្រភេទសត្វ និងរុក្ខជាតិក្នុងតំបន់ រួមជាមួយសម្ភារៈប្រើប្រាស់ និងវប្បធម៌ ប្រពៃណីរបស់ជនជាតិដើមភាគតិចកួយ សម្រាប់ផ្ដល់នូវចំណេះដឹង និងការអប់រំបន្ថែមដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងតំបន់ផង និងដើម្បីជាព័ត៌មានបន្ថែមដល់ភ្ញៀវទេសចរផង។

បន្ទាប់ពីឯកឧត្ដម **កុល ប៊ុនលី** រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង បានអានព្រះរាជសាររបស់ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាអបអរសាទរខួបទី ១៥ឆ្នាំ នៃការចុះប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោករួចមកលោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានមានប្រសាសន៍រំលឹកពីអតីតកាលកាលពី ១៥ឆ្នាំមុន ដែលជាការចងចាំជាប្រវត្តិសាស្ត្ររបស់ជាតិខ្មែរ ដែលអង្គការយូណេស្កូបានសម្រេចដាក់បញ្ចូលប្រាសាទព្រះវិហាររបស់កម្ពុជា ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ ។ លោកជំទាវបណ្ឌិតសភាចារ្យបានបន្ថែមថា ការសម្រេចនេះគឺជោគជ័យដ៏ធំរបស់ជាតិកម្ពុជាទាំងមូល ក្នុងការប្រឹងប្រែងរក្សាឲ្យបាននូវទ្រព្យសម្បត្តិរបស់កម្ពុជា ដែលបន្សល់ទុកដោយដូនតា ហើយក៏ជាកិច្ចខំប្រឹងប្រែងជាច្រើនឆ្នាំ ទាំងយប់ ទាំងថ្ងៃ ទាំងកម្លាំងកាយ កម្លាំងប្រាជ្ញា ប្រើប្រាស់ផ្នែកការទូតយ៉ាងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៕



គណៈអធិបតីក្នុងពិធី



ទិដ្ឋភាពក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ពិធីប្រកាសក្រុមការខារនិស្សិតស្ម័គ្រចិត្ត របស់គម្រោងជំរុញផលិតកម្មគ្រាប់ពូជស្រូវ និងការនាំចេញអង្ករប្រកបដោយគុណភាព

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ មន្ទីរកសិកម្មខេត្ត បានរៀបចំពិធីប្រកាសទទួល ក្រុមការងារនិស្សិតស្ម័គ្រចិត្ត របស់គម្រោងជំរុញផលិតកម្មគ្រាប់ពូជស្រូវ និងការនាំចេញអង្ករប្រកបដោយគុណភាពនៅខេត្តព្រះវិហារ ក្រោមអធិបតីភាព ឯកឧត្តម**ឡឹក សុផា** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទឯកឧត្តម**គង់គា**ប្រធាននាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្ម លោក **អ៊ុក គីមសាន្ត** អភិបាលរងខេត្ត និងមានការអញ្ជើញចូលរួមពីអភិបាលរងស្រុក ប្រធានសហគមន៍កសិកម្ម និងមន្ត្រីរាជការនៃមន្ទីរសិកម្ម ។

បន្ទាប់ពីអានសេចក្តីប្រកាសរួចមក លោក **អ៊ុក គីមសាន្ត** អភិបាលរងខេត្ត បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារនិស្សិតស្ម័គ្រចិត្តទាំង ១៩នាក់ ដែលបានស្ម័គ្រចិត្តចុះជួយ និងបង្រៀនប្រជាពលរដ្ឋ ពីការផលិតគ្រាប់ពូជស្រូវដែលសុទ្ធល្អ ក្នុងទិសដៅជួយកសិករឱ្យទទួលបានពូជសុទ្ធ ដើម្បីប្រើប្រាស់និងនាំចេញទាំងក្នុង និងក្រៅប្រទេស ដើម្បីធ្វើយ៉ាងណាឱ្យនៅទូទាំងប្រទេសកម្ពុជា មានគ្រាប់ពូជស្រូវសុទ្ធប្រើប្រាស់ជំនួសគ្រាប់ពូជបច្ចុប្បន្ន ដែលមានពូជខ្លះជាពូជសុទ្ធ និងខ្លះជាពូជមិនសុទ្ធ ហើយតែងតែរងការរិះគន់ទៅលើបញ្ហាគុណភាពអង្ករ នៅពេលនាំចេញ និងពេលបរិភោគ» ។ ជាពិសេសគឺបានផ្តល់ឱកាសដល់និស្សិតកសិកម្ម ប្រឡូកក្នុងស្ថានភាពជាក់ស្តែង និងទទួលបានបទពិសោធគ្រប់គ្រាន់ ដើម្បីប្រែក្លាយខ្លួនជាកម្លាំងដ៏រឹងមាំនៃធនធានមនុស្សក្នុងវិស័យកសិកម្ម ។ លោកបានបន្ថែមថាខេត្តព្រះវិហារ គឺជាខេត្តមួយដែលពឹងផ្អែកលើវិស័យកសិកម្មដូច្នេះហើយ ទើបមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលធ្វើយ៉ាងណាជំរុញខេត្តនេះ លើវិស័យកសិកម្ម ដើម្បីឲ្យមានចំណូលដល់មូលដ្ឋាន និងប្រជាកសិករជាអ្នកផលិតស្របតាមគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម**ឡឹក សុផា** អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទបានឲ្យដឹងថា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាយុទ្ធសាស្ត្រ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដាក់ឲ្យមានមន្ត្រីកសិកម្មម្នាក់ នៅតាមបណ្តាឃុំនីមួយៗទូទាំងប្រទេសកម្ពុជា ក្នុងនោះជាជំហានទី១ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានជ្រើសរើសក្រុមការងារនិស្សិ



*គណៈអធិបតីប្រគល់ សេចក្តីប្រកាសក្រុមការងារនិស្សិតស្ម័គ្រចិត្ត*

តស្ម័គ្រចិត្តចំនួន ១៨២នាក់ របស់គម្រោងជំរុញផលិតកម្មគ្រាប់ពូជស្រូវ និងការនាំចេញអង្ករប្រកបដោយគុណភាព ដើម្បីចាត់តាំងទៅក្នុងខេត្តគោលដៅចំនួន ១៣ ក្នុងគោលបំណង ដើម្បីជួយគាំទ្របច្ចេកទេសដល់សហគមន៍កសិកម្មដែលផលិតគ្រាប់ពូជស្រូវ និងផលិតស្រូវចំណីជួយរៀបចំផែនការផលិតកម្ម និងសម្របសម្រួលការធ្វើកិច្ចសន្យាកសិកម្ម រវាងអ្នកផលិតគ្រាប់ពូជស្រូវ ជាមួយសហគមន៍ផលិតស្រូវចំណី និង រវាងអ្នកផលិតស្រូវចំណី ជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬ អ្នកនាំចេញ ។ ឯកឧត្តមបានជំរុញដល់និស្សិតស្ម័គ្រចិត្តទាំងអស់ ត្រូវធ្វើយ៉ាងណាជួយប្រមូលទិន្នន័យទាក់ទងនឹងស្ថានភាពផលិតកម្មគ្រាប់ពូជស្រូវ និងស្រូវចំណី គាំទ្របច្ចេកទេស និងជួយរៀបចំផែនការផលិតកម្មដល់សហគមន៍កសិកម្ម និងកសិករដែលជាអ្នកដាំដុះនៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង ។ សម្របសម្រួលជាមួយសហគមន៍ផលិតគ្រាប់ពូជ ឬ អ្នកផលិតគ្រាប់ពូជស្រូវ ឲ្យចុះបញ្ជីធ្វើផលិតកម្មគ្រាប់ពូជតាមប្រព័ន្ធ ប.គ.ព និង ការស្នើសុំអគ្គនាយកដ្ឋានកសិកម្ម ដើម្បីចុះធ្វើអធិការកិច្ចនិងយកសំណាកគ្រាប់ពូជទៅពិនិត្យគុណភាព ។ ត្រូវទំនាក់ទំនងនិងធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានភូមិ ឃុំនិងស្រុកជាពិសេសមន្ត្រីបច្ចេកទេស ដើម្បីជួយសម្រួល និងអន្តរាគមន៍នៅពេលដែលកសិករជួបប្រទះនូវបញ្ហាផ្សេងៗ ក្នុងផលិតកម្មគ្រាប់ពូជ ឬផលិតកម្មស្រូវចំណី និងត្រូវរៀបចំរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែជូនទៅអគ្គនាយកដ្ឋានកសិកម្ម ៕



គណៈអធិបតីក្នុងពិធី



ឯកឧត្តម ឡឹក សុជា អនុរដ្ឋលេខាធិការក្រសួងកសិកម្ម




គណៈអធិបតីប្រគល់ សេចក្តីប្រកាសក្រុមការងារនិស្សិតស្ម័គ្រចិត្ត

# ដីទំហំ ៣៣៥ហិកតាក្នុងតំបន់កូនភ្នំ ទទួលបានការសម្រេចពីរាជរដ្ឋាភិបាល អនុញ្ញាតិឲ្យរដ្ឋបាលខេត្ត ចុះវាស់វែងជូនប្រជាពលរដ្ឋ



*ដីតំបន់កូនភ្នំ*

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាល ខេត្តព្រះវិហារ បានអញ្ជើញជួបសំណេះសំណាល និងប្រកាសបើកយុទ្ធនាការចុះវាស់វែងកាត់ឆ្វៀលដីធ្លី ស្ថិតនៅតំបន់កូនភ្នំក្នុងភូមិភារកិច្ច សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ជូនបងប្អូនប្រជាពលរដ្ឋដែលមានទំហំសរុប ៣៣៥ហិកតា ដែលចែកចេញជាប្រភេទក្បាលដី សម្រាប់ចែកជូនប្រជាពលរដ្ឋ និងក្បាលដីបម្រុងរបស់រដ្ឋ ដែលក្នុងនោះដីបម្រុងរបស់រដ្ឋមានទំហំ ៨៥ហិកតា ។ ពិធីបានប្រព្រឹត្តទៅនៅក្នុងបរិវេណសាលាក្រុងព្រះវិហារ ដោយមានការចូលរួម ពីសំណាក់អភិបាលរងខេត្ត ថ្នាក់ដឹកនាំមន្ទីរអង្គភាពជុំវិញខេត្ត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងបងប្អូនប្រជាពលរដ្ឋស្ថិតក្នុងក្រុងព្រះវិហារ ប្រមាណជិត ៣០០នាក់ ។

មានប្រសាសន៍ ទៅកាន់បងប្អូននាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានឲ្យដឹងថា ដោយទទួលបាននូវការទទូចស្នើសុំពីសំណាក់បងប្អូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់កូនភ្នំ ស្តីពីការស្នើ សុំអោយជួយវាស់វែងដើម្បីចេញប្លង់កម្មសិទ្ធិទៅលើដីធ្លីដែលស្ថិត ក្នុងតំបន់ខាងលើជូនដល់ពួកគាត់ ។ ក្រោយពីទទួលបានការស្នើសុំរបស់បង





*ឯកឧត្តមអភិបាលខេត្ត រួមជាមួយប្រតិភូអមដំណើរ*

ប្អូនប្រជាពលរដ្ឋ តាមរយៈឯកឧត្តមផ្ទាល់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានសម្រេចអនុញ្ញាតអោយរដ្ឋបាលខេត្ត ព្រះវិហារ ចាត់ចែងក្រុមការងារ ដើម្បីវាស់វែងដីធ្លីដែលស្ថិតនៅក្នុងចំនុចតំបន់ខាងលើ ជូនដល់បងប្អូនប្រជាពលរដ្ឋទៅតាមសំណូមពរ ។ ក្នុងឱកាសនោះផងដែរ ឯកឧត្តមក៏បានចូលរួមអបអរសាទរជាមួយបងប្អូនប្រជាពលរដ្ឋ ដែលទទួលបានការយកចិត្តទុកដាក់គិតគូរពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ដើម្បីវាស់វែង និងផ្តល់ជូននូវប្លង់កម្មសិទ្ធិដីធ្លីជូនដល់បងប្អូន ។

ជាមួយគ្នានេះផងដែរឯកឧត្តមក៏បានស្នើឲ្យបងប្អូនត្រូវចុះកំណត់ព្រំដីរបស់បងប្អូនអោយ បានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការវាស់វែង និងត្រូវចេះអនុគ្រោះអត់អោនរវាងគ្នានិងគ្នាដែលមានព្រំដីជាប់គ្នា ។ នៅក្នុងឱកាសនោះបងប្អូនប្រជាពលរដ្ឋបានបង្ហាញនូវការរីករាយសប្បាយចិត្តជាខ្លាំង ដោយបានង្ហាញនូវអារម្មណ៍រីករាយ តាមរយៈការថ្លែងអំណរគុណ និងជូនពរជ័យសិរីមង្គលដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ពិសេសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី ទទួលបាននូវសុខភាពល្អ និងជ័យជំនះគ្រប់ភារកិច្ច ៕



ប្រជាពលរដ្ឋដែលទទួលបានការវាស់វែង



ប្រជាពលរដ្ឋដែលទទួលបានការវាស់វែង



ដីតំបន់កូនក្តំ

# កិច្ចប្រជុំពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយឱ្យកាន់តែមានប្រសិទ្ធភាព

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ នៅក្នុងសាលប្រជុំនៃមន្ទីរព័ត៌មានខេត្ត ស្ថិតក្នុងក្រុងព្រះវិហារ ខេត្តព្រះវិហារ បានរៀបចំកិច្ចប្រជុំគម្រោងកម្មវិធីវិទ្យុមិត្តភាព កម្ពុជា-ថៃ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាព លោក **មិន ស៊ីថា** អភិបាលរងខេត្តព្រះវិហារ នៃព្រះរាជាណាចក្រកម្ពុជា និង លោក **ឧសិន ស៊ីងគីរី** ប្រធានការិយាល័យផ្សព្វផ្សាយតំបន់ភូមិភាគ២ នៃរាជាណាចក្រថៃ ។ វត្តមានចូលរួមក្នុងកិច្ចប្រជុំនាឱកាសនោះ ខាងព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ លោក **មិន ស៊ីថា** អភិបាលរងខេត្ត ព្រមទាំងលោក លោកស្រី ជាប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ



*លោក មិន ស៊ីថា អភិបាលរងខេត្ត*



*ទិដ្ឋភាពក្នុងពិធី*

ខេត្តសៀមរាប(តាមZOOM) ព្រមទាំងលោក លោកស្រី ជាប្រធាន អនុប្រធានការិយាល័យ និងបុគ្គលិកនៃមន្ទីរព័ត៌មានខេត្តព្រះវិហារ នៃព្រះរាជាណាចក្រកម្ពុជា និងភាគីព្រះរាជាណាចក្រថៃដឹកនាំដោយ លោក **ឧសិន ស៊ីងគីរី** ប្រធានការិយាល័យផ្សព្វផ្សាយតំបន់ភូមិភាគ២ ព្រមទាំងលោក លោកស្រីជាគណៈប្រតិភូអមដំណើរជាច្រើនរូបទៀត ។

មានប្រសាសន៍នាឱកាសនោះលោក **មិន ស៊ីថា**បានសម្តែងនូវអំណរគុណ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានលោកប្រធានការិយាល័យផ្សព្វផ្សាយ តំបន់ភូមិភាគ២នៃរាជាណាចក្រថៃ ព្រមទាំងលោក លោកស្រី ជាគណៈប្រតិភូអមដំណើរ ដែលបានអញ្ជើញមកក្នុងកិច្ចសហប្រតិបត្តិការល្អរវាងខេត្តសុរិន្ទនៃព្រះរាជាណាចក្រថៃ និងខេត្តព្រះវិហារនៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរការផ្សព្វផ្សាយព័ត៌មានជាច្រើន ដើម្បីផ្តល់ឲ្យគ្នាទៅវិញទៅមកប្រកបដោយសាមគ្គីភាពល្អបង្កលក្ខណៈក្នុងនាមជាប្រទេសជាប់របងគ្នារស់នៅដោយមានសន្តិភាព និងការអភិវឌ្ឍន៍ ។

ថ្លែងនៅក្នុងឱកាសនោះ លោកស្រី **ហែម សុគុណពីសី** ប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ បានឲ្យដឹងថា



លោក ឧសិទ ស៊ីងគីរី ប្រធានការិយាល័យផ្សព្វផ្សាយតំបន់ភូមិភាគ២

គោលបំណងសំខាន់នៃកិច្ចប្រជុំនាថ្ងៃនេះគឺ ដើម្បីពិនិត្យនិងកែសម្រួលទៅលើប្រព័ន្ធបច្ចេកទេស និងការផលិតកម្មវិធីវិទ្យុមិត្តភាពកម្ពុជា-ថៃ ឲ្យកាន់តែប្រសើរឡើង ។ លោកស្រីបានឲ្យដឹងទៀតថា មន្ទីរព័ត៌មានខេត្តព្រះវិហារ ក្រោមការសម្របសម្រួលរបស់ក្រសួងព័ត៌មាន បានសហការជាមួយភាគីប្រទេសថៃ បង្កើនកិច្ចសហប្រតិបត្តិការផ្សាយវិទ្យុមិត្តភាពកម្ពុជា-ថៃ Twin Radio . ព្រះវិហារ-សុរិន្ទ ដើម្បីចែករំលែកព័ត៌មានផ្សព្វផ្សាយ នូវសកម្មភាពរួមគ្នា ទាក់ទងទៅនឹងជីវភាព និងការរស់នៅរបស់បងប្អូនប្រជាពលរដ្ឋនៃខេត្តទាំង២ ការផ្លាស់ប្តូចំណេះដឹងផ្នែកភាសា ប្រពៃណីទំនៀមទម្លាប់ និងផ្សព្វផ្សាយព្រឹត្តិការណ៍ថ្មីៗ ព្រឹត្តិការណ៍ SEA Games និង ASEAN Para Game នៅកម្ពុជា ស្ថានភាពកូវីដ-១៩ និងស្ថានភាពទូទៅក្នុងខេត្តជាដើម ។

លោកស្រីក៏បានលើកឡើង អំពីវឌ្ឍនភាពការងារដែលសម្រេចបានចាប់តាំងពីឆ្នាំ ២០២០ មករហូតដល់ ខែកក្កដា ឆ្នាំ២០២៣ កិច្ចសហប្រតិបត្តិការផ្សាយវិទ្យុមិត្តភាពកម្ពុជា-ថៃ សម្រេចបានចំនួនសរុប ៤១លើក ក្នុងនោះមានចំនួន ៣លើក រអាក់រអួលបញ្ហាបច្ចេកទេស ក្នុងការអនុវត្តកម្មវិធី ។ ទន្ទឹមនោះ ភាគីទាំង២ ក៏ធ្លាប់បានប្រជុំដកស្រង់បទពិសោធន៍ បច្ចេកទេស ជាលក្ខណៈទ្វេភាគីបាន ចំនួន ៤លើក ។

នៅក្នុងឱកាសនោះផងដែរ ភាគីទាំង២ ក៏បានដោះស្រាយ និងសម្របសម្រួលទៅលើបញ្ហាមួយចំនួន ដើម្បីសម្រួលដល់ការងារផ្សព្វផ្សាយ តាមវិទ្យុមិត្តភាពកម្ពុជា-ថៃ ឲ្យកាន់តែមានភាពប្រសើរឡើង ៕






គណៈអធិបតីប្រគល់វត្ថុអនុស្សាវរីយ៍




គណៈអធិបតីប្រគល់វត្ថុអនុស្សាវរីយ៍



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ពិធីសំណេះសំណាល ជាមួយក្រុមនិស្សិតស្ម័គ្រចិត្តមកពីប្រទេសបារាំង ដែលបំពេញបេសកកម្មជួយជួសជុល និងសាងសង់អគារសាលាបឋមសិក្សា

ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាល ជាមួយក្រុមនិស្សិតស្ម័គ្រចិត្តមកពីប្រទេសបារាំង ដែលចុះបំពេញបេសកកម្មជួយជួសជុល និងសាងសង់អគារសាលាបឋមសិក្សាសំរោង ស្ថិតក្នុងភូមិសំរោង ឃុំតស៊ូ ស្រុកជ័យសែន ខេត្តព្រះវិហារ ។ ពិធីនេះក៏មានការចូលរួមពីសំណាក់ អភិបាលរងខេត្ត អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ ព្រមទាំងប្រជាពលរដ្ឋជាច្រើនរូបទៀត ។

មានប្រសាសន៍ណាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានថ្លែងអំណរគុណ និងកោតសរសើរ ហើយវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចការងាររបស់ក្រុមនិស្សិតស្ម័គ្រចិត្តបារាំង លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរស្រុកទាំងអស់គ្នា ។ ការខិតខំរបស់ក្រុមនិស្សិតស្ម័គ្រចិត្ត លោកគ្រូ អ្នកគ្រូ គឺបានរួមចំណែកដ៏សំខាន់ជាមួយរាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត ។





គណៈអធិបតីក្នុងពិធី



ទិដ្ឋភាពការជួសជុល និងសាងសង់អាគារសាលាបឋមសិក្សាសំរោង ស្រុកជ័យសែន

ឯកឧត្តមបន្តថា ការងារស្ម័គ្រចិត្តរបស់និស្សិតមកពីប្រទេសបារាំងនេះ បានផ្តល់នូវចំណេះដឹងទូលំទូលាយដែលយើងមិនធ្លាប់ជួបប្រទះ ជាពិសេសវាផ្តល់ឱកាសឲ្យពួកគេប្រាស្រ័យទាក់ទងជាមួយមនុស្សនៅក្នុងសង្គម ដែលមានជំនាញចំណេះដឹងចំណង់ចំណូលចិត្តខុសៗគ្នា បង្កើតចំណងមិត្តភាព និងសមត្ថភាពការងារជាក្រុម ចែករំលែកចំណេះដឹងថ្មីៗ បទពិសោធន៍ដែលខ្លួនមិនធ្លាប់មានតាមរយៈការចូលរួមសកម្មភាពដោះស្រាយបញ្ហា និងការសិក្សាកែលម្អគ្នាទៅវិញទៅមក ។ បន្ថែមពីនេះ ឯកឧត្តមក៏បានជំរុញឲ្យអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមសហការជាមួយនិស្សិតបារាំងទាំងអស់ ឲ្យបានផុសផុលដើម្បីពន្លឿនការសាងសង់អគារនេះ ដើម្បីឆាប់បានសិស្សានុសិស្សចូលសិក្សារៀនសូត្រ ។ ជាមួយនេះក្រុមនិស្សិតស្ម័គ្រចិត្តបារាំងទាំងអស់ បានសំដែងនូវការសប្បាយរីករាយចំពោះវត្តមានរបស់ឯកឧត្តមអភិបាលខេត្តនាឱកាសនោះ និងថ្លែងអំណរគុណដល់អាជ្ញាធរមូលដ្ឋាន ដែលផ្តល់កន្លែងស្នាក់នៅ ហូបចុក និងសន្តិសុខផ្សេងៗទៀតជូនពួកគេផងដែរ ។

នៅថ្ងៃដដែលនេះ ឯកឧត្តមអភិបាលខេត្តបានដឹកនាំសហការី ចុះពិនិត្យប្រពន្ធ័ធារាសាស្ត្រទំនប់ស្រីស្នំស្ថិតនៅភូមិស្លែង ឃុំខ្យង ស្រុកជ័យសែន ដែលបានហូរច្រោះដាច់ខ្នងទំនប់ប្រវែង ៥ម៉ែត្រ កាលពីថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០២៣ កន្លងទៅ ត្រូវបានក្រុមការងារមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ សម្រេចធ្វើការជួសជុលរួចរាល់ទាំងស្រុងកាលពីពេលថ្មីៗនេះ ៕



គណៈអធិបតីថតរូបអនុស្សាវរីយ៍





និស្សិតស្ម័គ្រចិត្តមកពីប្រទេសបារាំង

# ពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តព្រះវិហារ



*ទិដ្ឋភាពក្នុងពិធី*

ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ស្ថិតនៅអគារជាន់ទី៣ សាលាខេត្តព្រះវិហារបានរៀបចំពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តខេត្តព្រះវិហារ និងជាអនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាថ្នាក់កណ្តាល ដែលពិធីនេះ មានវត្តមានចូលរួមពីសំណាក់លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិកសមាជិកា នៃសហភាពសហព័ន្ធ យុវជនកម្ពុជាខេត្តព្រះវិហារជាច្រើនរូបទៀត ។



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*

យោងតាមរបាយការណ៍របស់លោក **យុទ គីមហ៊ាន** ប្រធានសហភាពសហព័ន្ធ យុវជនកម្ពុជាខេត្តព្រះវិហារបានឲ្យដឹងថា បច្ចុប្បន្នសមាសភាពគណៈកម្មាធិការសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តព្រះវិហារ គិតមកដល់ត្រឹមថ្ងៃទី៥ ខែសីហាឆ្នាំ២០២៣នេះមានសមាជិកសរុបទូទាំងខេត្តចំនួន ៣៧៣៦រូប ស្រី ១៣៨៣រូប ក្នុងនោះគណៈកម្មាធិការសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត មានចំនួន ៦៩រូប ស្រី ០៤រូប និងគណៈកម្មាធិការក្រុង ស្រុកមានចំនួន៣៧៥រូប ស្រី ៩៧រូប ។ ព្រមទាំងក្រុមការងារសហភាពសហព័ន្ធយុវជនកម្ពុជា នៅតាមបណ្តាឃុំ សង្កាត់ និងតាមបណ្តាមន្ទីរអង្គភាពទូទាំងខេត្ត នៅតាមគ្រឹះស្ថានសិក្សាជុំវិញខេត្ត មានចំនួនសរុប ៣៣១២រូប ស្រី ១២១០រូប និងក្រុមសមាជិកគាំទ្រមានចំនួន ៦១រូប ស្រី ០៧រូប ។

មានប្រសាសន៍សំណេះសំណាល នាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានថ្លែងកោត សរសើរ និងអំណរគុណចំពោះប្រធាន អនុប្រធាន និងសមាជិកសមាជិកានៃសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត- ក្រុង- ស្រុក- ឃុំ- សង្កាត់ទាំងអស់ ដែលកន្លងមកបានចូលរួមយ៉ាងសកម្មក្នុងកម្មវិធីផ្សេងៗជាច្រើន ទាំងការងារសង្គម និងការងារមនុស្សធម៌

ជាពិសេសការចូល រួមសង្កេតការណ៍ក្នុងការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នាពេលកន្លងទៅថ្មីៗនេះ ។

ក្នុងឱកាសនោះផងដែរ ឯកឧត្តមក៏បានជំរុញ និងលើកទឹកចិត្តទៅដល់ សមាជិក សមាជិកា សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តទាំងអស់ ខិតខំពង្រឹងនូវសមត្ថភាពទាំងចំណេះដឹងនិងជំនាញជាបន្ថែមទៀតនិងបន្តចូលរួមឲ្យបានខ្លាំងក្លាទាំងការងារសង្គម និងការងារមនុស្សធម៌ ក៏ដូចជាការងារបរិស្ថាន ការងារអប់រំកីឡា ការងារពលរដ្ឋល្អ និងចូលរួមសកម្មភាពផ្សេងៗច្រើនទៀត ស្របតាមស្ថានភាពនិងការជាក់ស្តែងរបស់រដ្ឋបាល ខេត្ត-ក្រុង-ស្រុក ក្នុងន័យគាំទ្រ ដើម្បីរួមចំណែកធ្វើឲ្យសម្រេចបានកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលឲ្យទទួលបានជោគជ័យ ។

ជាមួយគ្នានោះផងដែរ ឯកឧត្តមក៏បានឧបត្ថម្ភទូរទស្សន៍ធំ ១៩គ្រឿង សម្រាប់ផ្តល់ជូនវិទ្យាល័យនៅតាមក្រុង-ស្រុកទាំង៨និងភ្លើងបំភ្លឺបំពាក់គោយន្ត ៤ម៉ឺន ៥ពាន់ចំណាំងផ្លាត សម្រាប់បំពាក់លើគោយន្តតាមក្រុង-ស្រុកនិងផ្តល់ជូនអគារផ្តល់ឈាមជូនមន្ទីរសុខាភិបាលខេត្តព្រះវិហារផងដែរ ៕



គណៈអធិបតីប្រគល់ទូរទស្សន៍ដល់ក្រុង-ស្រុក



គណៈអធិបតីប្រគល់ភ្លើងបំភ្លឺបំពាប់គោយន្តដល់ក្រុង-ស្រុក



ទិដ្ឋភាពក្នុងពិធី

# ពិធីសំណេះសំណាលជាមួយក្រុមអ្នកដើរព្រៃកម្ពុជា ក្រោមប្រធានបទ "កីឡាដើម្បីទេសចរណ៍ និង សហគមន៍"

ថ្ងៃទី១១ខែសីហា ឆ្នាំ២០២៣នៅអគារសាលាខេត្ត ជាន់ទី៣ មានរៀបចំពិធីសំណេះសំណាលជាមួយក្រុមអ្នកដើរព្រៃកម្ពុជា ក្រោមប្រធានបទ "កីឡាដើម្បីទេសចរណ៍និងសហគមន៍ " ក្រោមអធិបតីភាពលោក **វ៉ាត ប៉ាវ៉ានីន** អភិបាលរងខេត្តព្រះវិហារ ដែលពិធីនេះក៏មានវត្តមានចូលរួមពីសំណាក់ លោក លោកស្រី ជាអង្គាធរដែនដី ថ្នាក់ដឹកនាំមន្ទីរពាក់ព័ន្ធ ព្រមទាំងលោក លោកស្រី និងយុវជនជាក្រុមអ្នកដើរព្រៃកម្ពុជា ដែលបានអញ្ជើញមកពីរាជធានីភ្នំពេញប្រមាណជា២០០នាក់ ។

មានមតិសំណេះសំណាលនាឱកាសនោះ លោក **វ៉ាត ប៉ាវ៉ានីន** បានសម្តែងនូវការស្វាគមន៍ យ៉ាងកក់ក្តៅចំពោះ លោក លោកស្រី និងយុវជន ដែលជាក្រុមអ្នកដើរព្រៃកម្ពុជា ដែលបានអញ្ជើញមកធ្វើកម្មវិធីសប្បុរសធម៌ កីឡារត់ឡើងភ្នំ និងបោះតង់ នៅក្នុងខេត្តព្រះវិហារនាពេលនេះ ។ លោកក៏បានថ្លែងអំណរគុណដល់លោក លោកស្រី ព្រមទាំងយុវជនទាំងអស់ ដែលជាក្រុមអ្នកដើរព្រៃកម្ពុជា ដែលបាននាំយកនូវសម្ភារៈសិក្សា ពីបណ្តាដៃគូឧបត្ថម្ភមកចែកជូនដល់ សាលាបឋមសិក្សាថ្មីបីជុំលើខ្នងភ្នំត្បែងដែល



គណៈអធិបតីក្នុងពិធី



លោក វ៉ាត ប៉ាវ៉ានីន អភិបាលរងខេត្ត



ក្រុមអ្នកដើរព្រៃកម្ពុជា

ជាតំបន់ដាច់ស្រយាល និងមានការលំបាកនិងខ្វះខាតនូវសម្ភារៈសិក្សា ។ ឯកឧត្តមសុំឲ្យក្រុមកីឡារត់ឡើងភ្នំ និងបោះតង់ទាំងអស់គ្នា ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើបរិស្ថានសុខភាពរបស់ខ្លួន ជាងនេះទៅទៀតត្រូវផ្តិតយកនូវរូបភាពល្អៗ អំពីតំបន់អេកូទេសចេណ៍តាំងយូនៅ លើភ្នំត្បែងមានជ័យខេត្តព្រះវិហារ ដែលជាគោលដៅនៃកម្មវិធីអ្នកដើរព្រៃទេសចរណ៍ធម្មជាតិនាពេលនេះ ដើម្បីធ្វើការផ្សព្វផ្សាយទៅដល់ទេសចរណ៍ជាតិ និងអន្តរជាតិឲ្យពួកគាត់បានស្គាល់ និងចាប់អារម្មណ៍ ដើម្បីស្រូបទាញបាននូវភ្ញៀវទេសចរណ៍មកកំសាន្តកាន់តែច្រើនកុះករ ។ លោកក៏បានឲ្យដឹងទៀតថា បើសិនជាយើងមិន បានផ្តិតយករូបភាពល្អៗនៅតំបន់ទេសចរណ៍ ដើម្បីយកទៅផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់បណ្តាទេសចរណ៍នោះទេ តំបន់ទេសចរណ៍ទាំងនោះប្រៀបបានទៅ និងកូនក្រមុំដែលកំពុងចូលម្លប់ពុំមានអ្នកស្គាល់ ។

សូមបញ្ជាក់ថា ៖ ក្រុមអ្នកដើរព្រៃកម្ពុជា ដែលបានអញ្ជើញមកពីរាជធានីភ្នំពេញនាពេលនេះ មានកម្មវិធីចំនួន ៣ ក្នុងនោះទី១ កម្មវិធីសម្បុរសធម៌ក្នុងការចែកអំណោយដល់សាលាបឋមសិក្សា ថ្មបីដុំ ដែលបានប្រព្រឹត្តទៅនៅរសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ នៅវីសតអាកាសាស្ថិតនៅ ជើងភ្នំត្បែងក្នុងភូមិក្រាំងដូង ឃុំព្រះឃ្លាំងស្រុកត្បែងមានជ័យ និងកម្មវិធីទី២ កីឡារត់ឡើងភ្នំ ទី៣កម្មវិធីបោះតង់ និងប្រព្រឹត្តទៅនៅថ្ងៃទី ១២និង ១៣ខែសីហា ឆ្នាំ ២០២៣ នៅតំបន់អេកូទេចសរណ៍តាំងយូ នៅលើខ្នងភ្នំត្បែងមានជ័យ ស្ថិតក្នុងភូមិសេដ្ឋកិច្ច ឃុំឈានមុខស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ៕





ក្រុមអ្នកដើរព្រៃកម្ពុជា



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ពិធីចុះហត្ថលេខាលើកិច្ចសន្យាផលិតកម្មស្តីពីការផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គរវាងសហគមន៍កសិកម្ម



*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

កិច្ចសន្យាទិញលក់ស្រូវសរីរាង្គ ត្រូវបានរៀបចំឡើងនៅសាលប្រជុំមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោក **អ៊ុក គីមសាន** អភិបាលរងខេត្ត លោកឧកញ៉ា **សុខ សារ៉ែន** អគ្គនាយកក្រុមហ៊ុនអេមរ៉ុយស៍ លោកស្រី **សៅ សុនិតា** អគ្គនាយករង ក្រុមហ៊ុនហ្គោលដិនរ៉ាយស៍ អង្គការដៃគូរអភិវឌ្ឍន៍ មន្ទីរពាណិជ្ជកម្មខេត្ត សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ ថ្នាក់ដឹកនាំសហគមន៍កសិកម្ម និងកសិករជាក្រុមផលិតជាច្រើនរូបទៀត ។

លោក **ពឹង ទ្រីដា** ប្រធានមន្ទីរកសិកម្មខេត្ត បានបញ្ជាក់ថាសហភាពសហគមន៍ កសិកម្មព្រះវិហារមានជ័យ គឺជាសហភាពដំបូង ដែលបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងខែមេសា ឆ្នាំ២០១៦ មានសមាជិកសរុបចំនួន ២៥សហគមន៍ ជាមួយនឹងកសិករ ចំនួន ៥,៤០៣ គ្រួសារ ដែលមានទីតាំងនៅស្រុកទាំង ០៧នៃខេត្តព្រះវិហារ ហើយទស្សនៈវិស័យរបស់សហភាពគឺ "កសិករនៅខេត្តព្រះវិហារ នឹងមានជីវភាពធូរធារស់នៅប្រកបដោយភាពរុងរឿង និងសេចក្តីថ្លៃថ្នូរ" ។ សម្រាប់ពិធីចុះហត្ថលេខានាពេលនេះ គឺធ្វើឡើងដោយក្រុមហ៊ុនហ្គោលដេនរ៉ាយស៍នឹងទទួលទិញស្រូវសរីរាង្គចំនួន ១,២០០តោន ពីសហគមន៍កសិកម្មចំនួន ០៧ ដែលមានអ្នកផលិត ១,០០០គ្រួសារ និងក្រុមហ៊ុនអេមរ៉ាយស៍ នឹងទទួលទិញស្រូវ សរីរាង្គប្រភេទស្រូវសចំនួនប្រមាណ ១,០០០តោន ពីសហគមន៍កសិកម្មចំនួន៤ ដែលមានអ្នក ផលិត ៥០០គ្រួសារ ដែលជាកិច្ចសន្យាទិញបន្ថែមលើបរិមាណដែលបានចុះហត្ថលេខា កាលពីខែមិថុនាកន្លងមកថ្មីៗនេះ ។



*លោក ពឹង ទ្រីដា ប្រធានមន្ទីរកសិកម្ម*

· លោកឧកញ៉ា **សុខ សារ៉ែន** អគ្គនាយកក្រុមហ៊ុនអេមរ៉ាយ៍កម្ពុជាបានឲ្យដឹងថាឆ្នាំ២០២៣នេះគឺជាឆ្នាំទី៩ហើយ

នៃការចុះកិច្ចសន្យាបញ្ញាទិញស្រូវសរីរាង្គ ពីសហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ ។ លោកក៏បានប្តេជ្ញាខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញការផ្សព្វផ្សាយ និងនាំចេញអង្ករសរីរាង្គខេត្តព្រះវិហារ ឆ្ពោះទៅកាន់ទីផ្សារពិភពលោកឱ្យកាន់តែទូលំទូលាយ និងខ្លាំងក្លាបំផុតក្នុងគោលដៅធ្វើយ៉ាងណាឱ្យអង្ករព្រះវិហារ កាន់តែមានកេរ្តិ៍ឈ្មោះល្បីនៅឆាកអន្តរជាតិ ។ ហើយទោះបែបនេះក្តី លោកនៅតែបន្តទទូចស្នើសុំដល់កសិករផលិតទាំងអស់ សូមមេត្តាបន្តភាពស្មោះត្រង់របស់ខ្លួន ធ្វើយ៉ាងណាត្រូវគោរពទៅតាមគោលការណ៍កិច្ចសន្យាពិសេសស្តង់ដាសរីរាង្គ ។



លោក អ៊ុក គឹមសាន អភិបាលរងខេត្ត

លោក **អ៊ុក គឹមសាន** អភិបាលរងខេត្តព្រះវិហារ បានឲ្យដឹងថា រាជរដ្ឋាភិបាលបច្ចុប្បន្ន បាននឹងកំពុងសិក្សាលើការធ្វើពាណិជ្ជកម្ម ដើម្បីស្វែងរកទីផ្សារដោយការនាំចេញផលិតផលកសិកម្ម របស់ព្រះរាជាណាចក្រកម្ពុជាទៅកាន់ទីផ្សារពិភពលោក ហើយកសិកម្មគឺនៅតែជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ហើយខេត្តព្រះវិហារគឺជាខេត្តគោលដៅនៃវិស័យកសិកម្ម ។ លោកក៏បានធ្វើការវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងសហការគ្នា បានយ៉ាងល្អពីគ្រប់ភាគីពាក់ព័ន្ធ ដោយមានការសម្របសម្រួលពីមន្ទីរកសិកម្ម រហូតឈានដល់ការសម្រេចបានជាបន្តបន្ទាប់នូវក្នុងក្របខណ្ឌកសិកម្មតាមកិច្ចសន្យា ដែលអាចចាត់ទុកថាជាខ្សែបន្ទាត់ ឬ ជានិតិវិធី សម្រាប់ឲ្យភាគីអ្នកផលិត និងអ្នកបញ្ញាទិញដើរព្រមគ្នា ឆ្ពោះទៅទិសដៅមួយយ៉ាងជាក់លាក់ពិតប្រាកដ តម្លាភាព សច្ចភាព និងជំនឿទុកចិត្តគ្នា ដោយឈរលើគោលការណ៍សំខាន់ ៣គឺៈ ធានាបាននូវបរិមាណផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព គុណភាព ផលិតផល ធានាបាននូវតម្លៃ សាមគ្គីភាព កិច្ចសហការ ជំនឿទុកចិត្ត និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បី ជំរុញឲ្យវិស័យកសិកម្មនៅក្នុងខេត្តព្រះវិហារ នឹងក្លាយជាកសិកម្មបែបសរីរាង្គចាប់ពីមូលដ្ឋានរហូតដល់ទីផ្សារចរាចរផលិតផល ដើម្បីសម្រេចបាននូវគោលនយោបាយ ជំរុញផលិតកម្ម ស្បៀង និងការនាំចេញរបស់រាជរដ្ឋាភិបាលកម្ពុជា ជួយបង្កើននូវកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

សូមបញ្ជាក់ថាៈ នៅទូទាំងខេត្តព្រះវិហារការងារបង្ករបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០២៣ បានអនុវត្តន៍ផ្ទៃដីភ្ជួររាស់បាន ចំនួន ១០០,០៥៩ហិកតា និងផ្ទៃដីដែលបានព្រោះស្ទូង និងបុកដាំ មានចំនួន ១០០,៣០១ ហិកតា លើផែនការ ៩៩,៨១៧ហិកតា ស្មើនឹង ១០០,៤៨%។

ការបង្ករបង្កើនផលដំណាំរួមផ្សំ ដំណាំកសិឧស្សាហកម្ម និងដំណាំឈើហូបផ្លែ គិតត្រឹម ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៣ អនុវត្តន៍បាន ៨៤,០៣៧ ហិកតា នៃផែនការ ៨២,៣១៥ ហិក តា ស្មើនឹង ១០២,០៩% ។







ពិធីប្រគល់កិច្ចសន្យា

# ពិធីដាំកូនឈើអបអរសាទរទិវា រុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៣

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣នេះ ស្ថិតនៅក្នុងបរិវេណសាលាបឋមសិក្សាទំនប់ ក្នុងភូមិទំនប់ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ មានរៀបចំពិធីដាំកូនឈើ អបអរសាទរទិវា រុក្ខទិវា ៩ កក្កដា ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ព្រមទាំងវត្តមានចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត ថ្នាក់ដឹកនាំមន្ទីរអង្គភាពនានាជុំវិញខេត្ត អភិបាលក្រុង-ស្រុកទាំង៨ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋជាច្រើនរូប ។

មានមតិនាឱកាសនោះ លោក **ពឹង ឡើជា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារបានឲ្យដឹងថា ថ្ងៃនេះមន្ទីរកសិកម្មខេត្ត ដែលមានខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះវិហារ ជាសេនាធិការ រួមជាមួយអាជ្ញា ធរដែនដីគ្រប់លំដាប់ថ្នាក់បានរៀបចំពិធីនេះឡើង ដើម្បី អបអរសាទររុក្ខទិវា ៩កក្កដា ឆ្នាំ២០២៣ ។ សម្រាប់កូនឈើដែលបានយកមកដាំនាពេលនេះ ជាប្រភេទកូនឈើ ចម្រុះសរុបចំនួន ១០០០ដើមក្នុងនោះកូនឈើក្រញូងចំនួន
១០០ដើម កូនឈើបេង២០០ដើម និងកូនឈើធ្នង់ ៧០០ដើម ។ ជាមួយគ្នានេះផងដែរ ខណ្ឌរដ្ឋបាលព្រៃឈើខេត្ត


ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត


គណៈអធិបតីប្រគល់កូនឈើ



គណៈអធិបតីក្នុងពិធី



*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

ព្រះវិហារ ក៏បានចែកកូនឈើហូបផ្លែ សរុបចំនួន ៦០០ដើម ជូនដល់បងប្អូនប្រជាពលរដ្ឋ ដើម្បីយកទៅដាំតាមលំនៅដ្ឋាន ដែលក្នុងនោះរួមមាន កូនស្វាយចំនួន ២០០ដើម កូនខ្នុរចំនួន ២០០ដើម កូនអំពិលផ្អែម១០០ដើម និងកូនទាបបារាំងចំនួន ១០០ដើម ។

មានមតិក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** ក៏បានថ្លែងអំណរគុណដល់មន្ទីរកសិកម្មខេត្ត ក៏ដូចជាខណ្ឌរដ្ឋបាលព្រៃឈើខេត្ត ព្រមទាំងអាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកម្លាំងគ្រប់ប្រភេទ លោកគ្រូអ្នកគ្រូសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ ដែលបានសហការរៀបចំពិធីដ៏មានសារៈសំខាន់នេះឡើង ។

ឯកឧត្តមបានឲ្យដឹងថា ពិធីរុក្ខទិវាជា ចលនាបំផុសដាំដើមឈើ ដែលជាប្រពៃណីដ៏ល្អផូរផង់ឧត្តុងឧត្តមរបស់ប្រជាជាតិយើង ។ ចលនានេះមានតាំងពីសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជបូជនីយកិច្ចផ្តួចផ្តើម និងដឹកនាំរបស់ព្រះករុណា ព្រះមហាវីរក្សត្រព្រះវររាជបិតាជាតិខ្មែរព្រះបរមរតនកោដ្ឋ តាំងពីទស្សវត្សរ៍៣០មក ដោយមានការចូលរួមយ៉ាងផុសផុល ពីប្រជាពលរដ្ឋគ្រប់ស្រទាប់ក្លាយទៅជាសកម្មភាពទូលំទូលាយ ក្នុងចលនាទិវាពលកម្ម ដាំដើមឈើនៅក្នុងសង្គម ដែលទីបំផុតត្រូវបានទទួលស្គាល់ជាពិធីប្រពៃណីជាតិមួយ ហៅថាពិធីរុក្ខទិវា ដែលកំណត់ដោយព្រះរាជក្រឹត្យ លេខ ៧៣៨ នស.រកត ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៥២ ។ ជាមួយគ្នានេះដែរ ឯកឧត្តមបានជំរុញឲ្យមានការចូលរួមដាំដើមឈើ ឲ្យបានគ្រប់ៗគ្នា គ្រប់ប្រភេទ និងគ្រប់ទីកន្លែងអោយបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ និងត្រូវចូលរួមជួយទប់ស្កាត់ បញ្ឈប់ការកាប់ឈើ ការកាប់រានដុតឈូសឆាយដីព្រៃ ដើម្បីថែរក្សាការពារព្រៃឈើទុកសម្រាប់កូនចៅរបស់យើង នៅគ្រប់ជំនាន់ជាបន្តទៀត ៕



*អ្នកចូលរួមក្នុងពិធី*

# ទិវាអក្ខរកម្មជាតិអន្តរជាតិ ៨កញ្ញា លើកទី២៣ ក្រោមប្រធានបទ "អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃសហគ្រិនភាព និងសង្គមសេដ្ឋកិច្ច"

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ឈុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងឯកឧត្តម **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជាអធិបតីភាពក្នុងទិវាអក្ខរកម្មជាតិអន្តរជាតិ ៨កញ្ញា លើកទី២៣ ដែលបានប្រារព្ធធ្វើឡើងក្រោមប្រធានបទ " អក្ខរកម្មជាមូលដ្ឋានគ្រឹះ នៃសហគ្រិនភាពនិងសង្គមសេដ្ឋកិច្ច"។ពិធីនេះក៏មានការចូលរួមពីសំណាក់ ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ ឯកឧត្តមធិការជាតិរៀបចំបុណ្យជាតិ បានផ្តល់កិត្តិយសជ្រើសរើសឲ្យខេត្តព្រះវិហារ រៀបចំធ្វើជាម្ចាស់ផ្ទះក្នុងការប្រារព្ធទិវាអក្ខរកម្មអន្តរជាតិ ៨កញ្ញា លើកទី២៣ ដែលបានប្រារព្ធធ្វើឡើងក្រោមប្រធានបទ " អក្ខរកម្មជាមូលដ្ឋានគ្រឹះ នៃសហគ្រិនភាព និងសង្គមសេដ្ឋកិច្ច" ក្នុងអត្ថន័យជំរុញប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ឲ្យទទួលបានការសិក្សាពេញមួយជីវិតគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់មធ្យោបាយសំដៅសម្រេចឲ្យបាននូវការអភិវឌ្ឍធនធានមនុស្ស ស្របតាមទិសដៅយុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត ។




*គណៈអធិបតីក្នុងពិធី*

លោកជំទាវ ជាប្រតិភូអមដំណើរ អភិបាលរងខេត្ត ប្រធានមន្ទីរអង្គភាពជុំវិញខេត្ត លោកគ្រូ អ្នកគ្រូ នឹងសិស្សានុសិស្សយ៉ាងច្រើនកុះករ ។

មានមតិស្វាគមន៍នាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត បានសម្តែងនូវសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមសម្តែងគារវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម **ឈុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តព្រះវិហារ ពិតជាមានកិត្តិយសណាស់ ដែលក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មា



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*

ឯកឧត្តម **ណុះ ស្លេះ** អានសារលិខិតរបស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជា ក្នុងឱកាសប្រារព្ធទិវាអក្ខរកម្មជាតិឆ្នាំ២០២៣ថារាជរដ្ឋាភិបាលបាននិងកំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ដោយបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបម្រើប្រជាពលរដ្ឋ ពន្លឿនកិច្ចអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច និងជំរុញអនុវត្តកំណែទម្រង់កាន់តែស៊ីជម្រៅ និងទូលំទូលាយលើគ្រប់វិស័យ ។


ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការក្រសួងអបរំ

ឯកឧត្តមបន្តថា ប្រធានបទឆ្នាំនេះបានបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់ អក្ខរកម្មតាមគ្រប់រូបភាព និងជាការផ្តល់ឱកាសសារជាថ្មីដល់អ្នកសិក្សា ជាពិសេសអ្នកដែលមានសេដ្ឋកិច្ចទន់ខ្សោយ ជនបាត់បង់ឱកាសពលរដ្ឋក្រីក្រ កុមារ យុវជន និងជនជាតិដើមភាគតិច ដើម្បីឲ្យពួកគាត់មានសមត្ថភាពក្នុងការអាន សរសេរ គិតលេខ និងអាចដោះស្រាយ បញ្ហាមួយចំនួន នៅក្នុងជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង ។ សារលិខិតដដែលនេះលើកឡើងទៀតថាជាការពិតណាស់ អក្ខរកម្មជាមូលដ្ឋានគ្រឹះ នៃចំណេះដឹងនិងការអប់រំ ដែលជួយមនុស្ស គ្រប់រូបអាចយល់ដឹងពីប្រភេទព័ត៌មានទូទៅ និងទទួលបាននូវចំណេះដឹងថ្មីៗ ព្រមទាំងបង្កើន ឱកាសក្នុងការកែលម្អគុណភាពនៃជីវិតមនុស្ស និងជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិតផងដែរ ៕


អ្នកចូលរួមក្នុងពិធី


គណៈអធិបតីប្រគល់កងជូនសិស្ស

# ពិធីបិទវគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សា (១២+២) ជំនាន់ទី៣៩ របស់សាលាគរុកោសល្យ និងវិក្រឹតការខេត្ត



គណៈអធិបតីថតរូបអនុស្សាវរីយ៍

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ អញ្ជើញ ជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សា (១២+២) ដែលមានការអញ្ជើញចូលរួម ពីសមាជិកក្រុមប្រឹក្សាខេត្ត លោក លោកស្រី ជាអភិបាលរងខេត្ត ប្រធាន អនុប្រធានមន្ទីរអង្គភាពជុំវិញខេត្ត និងលោកគ្រូ អ្នកគ្រូជាច្រើនរូប ។ ពិធីបិទវគ្គនេះធ្វើឡើងនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ស្ថិតនៅក្នុងភូមិអណ្តូងពោធិ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ។

លោក **អ៊ុំ វត្ថនា** នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្ត បានឲ្យដឹងថាពិធីបិទវគ្គបណ្តុះបណ្តាលគ្រូបឋមសិក្សា (១២+២) ជំនាន់ទី៣៩ ឆ្នាំសិក្សា ២០២១-២០២៣ សរុប ចំនួន ២៥នាក់ ស្រី ១៦នាក់ ពិធីនេះក៏មានការចូលរួមពីគរុសិស្សពីរជំនាន់ គឺជំនាន់ទី៣៧ និង៣៨ ដែលបានបញ្ចប់វគ្គបណ្តុះ បណ្តាលគ្រូបឋមសិក្សា (១២+២) និងចែកសញ្ញាបត្រជូន ដល់ប្អូនៗផងដែរ ។ លោកបានបន្តថាបច្ចុប្បន្ននេះ សាលាគរុកោសល្យមាន បុគ្គលិកសរុប ចំនួន ៤២នាក់ ស្រី ២៥នាក់ បុគ្គលិកកិច្ចសន្យា ០១នាក់ បែងចែកជាពីផ្នែកគឺ សាលាគរុកោសល្យ និងវិក្រឹតការមាន បុគ្គលិកសរុប ២២នាក់ ស្រី ០៧នាក់ និងសាលាបឋមសិក្សា



គណៈអធិបតីថតរូបអនុស្សាវរីយ៍



អនុវត្តមានបុគ្គលិកសរុប ២០នាក់ ស្រី ១៨នាក់ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានថ្លែងកោតសរសើរ ចំពោះលោកនាយកសាលា និងគ្រូឧទ្ទេស ដែលបានខិតខំផ្តល់ការបង្ហាត់បង្រៀនណែនាំដល់ គរុសិស្សឲ្យទទួលបានការបណ្តុះបណ្តាល ដើម្បីក្លាយខ្លួនជាគ្រូបង្រៀនល្អ ក្នុងការបង្ហាត់បង្ហាញកុមារនៅតាមសហគមន៍ ។ ឯកឧត្តមក៏បានលើកឡើងនូវអនុសាស្ត្របញ្ចកោណមានបាវចនា៥, គោលដៅយុទ្ធសាស្ត្រ៥ និងអាទិភាពគន្លឹះ៥ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំ ដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណនេះ ត្រូវលើកកម្ពស់សមត្ថភាពកិត្តិយស សេចក្តីថ្លៃថ្នូរគ្រូបង្រៀនការបន្តអភិវឌ្ឍន៍កម្មវិធីសិក្សា សៀវភៅសិក្សាគោល ការពង្រឹងវិធីសាស្ត្របង្រៀន និងរៀនតាមនិន្នាការថ្មី (ការអប់រំឌីជីថល) ការពង្រឹងអធិការកិច្ចការគ្រប់គ្រងសាលារៀន ការពង្រឹងទំនាក់ទំនងជិតស្និទ្ធរវាងសាលា និងមាតា បិតាសិស្ស ការពង្រឹងការ ប្រឡងគ្រប់ប្រភេទ ការអនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្ស ថ្នាក់ជាតិ និងអន្តរជាតិ ៕



ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត



សាលាគរុកោសល្យ និងក្រឹតការខេត្ត



គណៈអធិបតីក្នុងអង្គពិធី

# ពិធីប្រកាសដាក់បញ្ចូលថ្នាំបង្ការជំងឺមហារីកមាត់ស្បូនដល់កុមារីអាយុ ៩ឆ្នាំ ក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៅទូទាំងប្រទេសកម្ពុជា

ថ្ងៃទី០៥ខែតុលា ឆ្នាំ២០២៣មន្ទីរសុខាភិបាលខេត្ត បានរៀបចំពិធីប្រកាសដាក់បញ្ចូលថ្នាំបង្ការជំងឺមហារីកមាត់ស្បូនដល់កុមារីអាយុ ៩ឆ្នាំ ក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៅទូទាំងប្រទេសកម្ពុជា ក្រោមអធិបតីភាព លោក **សុខ សាន្តតារ៉ា**អភិបាលរងខេត្តនិងមានការអញ្ជើញចូលរួមពីសំណាក់លោកវេជ្ជបណ្ឌិត **គួង ឡូ** ប្រធានមន្ទីរសុខភិបាលខេត្ត អភិបាលរងក្រុង/ស្រុក លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាលសិស្សជាច្រើនរូប ។

មានមតិស្វាគមន៍នាឱកាសនោះ លោក **គួង ឡូ** ប្រធានមន្ទីរសុខាភិបាលខេត្ត បានសម្តែងការអបអរសាទរជាមួយបងប្អូនប្រជាពលរដ្ឋ និងមាតាបិតាទាំងអស់ដោយកុមារីអាយុ ៩ឆ្នាំនៅទូទាំងប្រទេស បានទទួលថ្នាំបង្ការជំងឺមហារីកមាត់ស្បូនដោយមិនគិតថ្លៃថ្មីមួយទៀត បន្ថែមពីលើថ្នាំបង្ការជំងឺទាំង១១មុខនាពេលកន្លងមក ។ ហើយថ្នាំបង្ការឬវ៉ាក់សាំង ដែលបានផ្តល់ជូនទារក និងកុមារទាំង១១មុខរួមមាន ជំងឺរបេង គ្រុនស្វិតដៃជើង ក្អកមាន់ ខាន់ស្លាក់ តេតាណុស រលាកថ្លើមប្រភេទបេ ជំងឺរលាកសួត រលាកស្រោមខួរ ជំងឺកញ្ជ្រឹល ជំងឺស្អូច និងជំងឺរលាកខួរក្បាលជេអ៊ី ។



គណៈអធិបតីក្នុងពិធី





ចាក់ថ្នាំបង្ការជំងឺមហារីកមាត់ស្បូនដល់កុមារអាយុ ៩ឆ្នាំ




ចាក់ថ្នាំបង្ការជំងឺមហារីកមាត់ស្បូនដល់កុមារអាយុ ៩ឆ្នាំ

មានប្រសាសន៍ទៅកាន់អង្គពិធីនាពេលនោះ លោក **សុខ សាន្តតារ៉ា** អភិបាលរងខេត្ត បានឲ្យដឹងថាក្រោមការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ជាការវិនិយោគលើវិស័យសុខភាពសាធារណៈរបស់កុមារ ដ៏មានប្រសិទ្ធ ភាពមួយ ព្រមទាំងបានចូលរួមចំណែកដ៏សំខាន់ ក្នុងការកាត់បន្ថយអត្រាឈឺពិការភាព និងស្លាប់ របស់កុមារនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ តាមផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ( ពីឆ្នាំ២០២២-២០២៥ ) ក្រោមការជួយគាំទ្រថវិកាពីអង្គការ Gavi ព្រមទាំងមាន ការគាំទ្របច្ចេកទេសពីអង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វ ក្រសួងសុខាភិបាល បានអនុញ្ញាតឲ្យកម្មវិធីជាតិផ្តល់ថ្នាំបង្ការដាក់បញ្ចូលថ្នាំបង្ការជំងឺមហារីកមាត់ស្បូន លើកុមារីអាយុ ៩ឆ្នាំ ទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំនៅទូទាំង ២៥រាជធានីខេត្តនៅតាមសាលារៀន និងតាមមូលដ្ឋានសុខាភិបាលសាធារណៈក៏ដូចជាតាមសហគមន៍ ដោយឥតគិតថ្លៃចាប់ពីពេលនេះតទៅ ។ ដូចនេះលោកក៏បានអំពាវនាវដល់មាតាបិតាអាណាព្យាបាលនៃកុមារទាំងអស់សូមនាំកូនមកទទួលវ៉ាក់សាំងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការឲ្យបានគ្រប់ៗគ្នា នៅតាមសាលារៀន មណ្ឌលសុខភាព ឬ តាមបុគ្គលិកផ្តល់ថ្នាំបង្ការនៅតាមភូមិ ទៅតាមផែនការ និងការណាត់របស់បុគ្គលិកសុខាភិបាលកុំបីខាន ៕



អ្នកចូលរួមក្នុងពិធី



អ្នកចូលរួមក្នុងពិធី

# អភិបាលខេត្ត អញ្ជើញបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពកងរុករក និងសង្គ្រោះលេខ៧២១ នៃកងពលធំអន្តរាគមន៍លេខ៣



គណៈក្នុងអធិបតីក្នុងពិធី

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ នាទីបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពកងរុករក និងសង្គ្រោះលេខ៧២១ នៃកងពលធំអន្តរាគមន៍លេខ៣ ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស្រី ឌឹក** មេបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ និងមានការអញ្ជើញចូលរួមពីសំណាក់ អភិបាលរងខេត្ត មេបញ្ជាការ មេបញ្ជារង កងកម្លាំងទាំងបី ថ្នាក់ដឹកនាំមន្ទីរអង្គភាពជំនាញ ព្រមទាំងលោក លោកស្រី ជាសមាជិកក្រុមរុករកសង្គ្រោះគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តជាច្រើនរូបទៀត ។



គណៈក្នុងអធិបតីក្នុងពិធី

ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តបានថ្លែងថាប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រោះមហន្តរាយទឹកជំនន់ ខ្យល់កន្ត្រាក់ បានបង្កផលប៉ះពាល់ជាច្រើនដល់អាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស ក៏ដូចជាខេត្តព្រះវិហាររបស់យើងស្ទើររៀងរាល់ឆ្នាំ ។ ជាក់ស្តែងកន្លងមកនេះយើងក៏ធ្លាប់បានទទួលរងនូវទឹកជំនន់ ទឹកភ្លៀងនៅតាមតំបន់ជួរភ្នំដងរ៉ែក និងតំបន់ជាប់ស្ទឹងសែន ។ ដោយមើលឃើញអំពីតម្រូវការចាំបាច់ គណៈកម្មាធិការគ្រប់គ្រងគ្រោះ





គណៈក្នុងអធិបតីក្នុងពិធី



មហន្តរាយ បានធ្វើការណែនាំដល់លេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ គ្រប់លំដាប់ថ្នាក់ឱ្យត្រៀមលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងការជួយសង្គ្រោះករណីមានគ្រោះមហន្តរាយ កើតឡើងជាយថាហេតុណាមួយ ។

ជាមួយនេះ ផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ និងអនុវត្តតាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រះវិហារ បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងអនុវត្តលំហាត់សមយុទ្ធរុករក និងសង្គ្រោះគ្រោះមហន្តរាយដល់កងកម្លាំង និងមន្ត្រីនៃលេខាធិការដ្ឋានក្នុងគោលបំណងបង្កើនចំណេះដឹង ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យ យន្តការគ្រប់គ្រងឆ្លើយតបនានា ការយល់ដឹងអំពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ហាឧបទ្ទវហេតុ និងការប្រើប្រាស់ឧបករណ៍រុករក និងសង្គ្រោះលើផ្ទៃទឹកដូចជាការ ប្រើប្រាស់ទូកសង្គ្រោះការប្រើប្រាស់ខ្សែសុវត្ថិភាពជាដើម ។

បន្ថែមពីនេះ ឯកឧត្តមក៏បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់សូមយកចិត្តទុកដាក់សិក្សារៀនសូត្រ ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដូចជាការអនុវត្តលំហាត់សមយុទ្ធ



សិក្ខាកាមសិក្សាវគ្គបណ្តុះបណ្តាលសង្គ្រោះ

និងយុទ្ធវិធីនានា ដើម្បីទទួលបាននូវចំណេះដឹង និងជំនាញនានាក្នុងការគ្រប់គ្រង ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ។ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលតាមរយៈការជំរុញដំណើរការ និងការចូលរួមឱ្យបានពេញលេញ ជាពិសេសការអនុវត្តលំហាត់សមយុទ្ធឱ្យកៀកទៅនឹងការពិតជាក់ស្តែង ហើយត្រូវយកចំណេះដឹង និងជំនាញដែលទទួលបានទៅប្រើប្រាស់ឱ្យចំគោលដៅនិងមានប្រសិទ្ធភាពខ្ពស់ ក្នុងការជួយសង្គ្រោះករណីមានគ្រោះមហន្តរាយកើតឡើងជាយថាហេតុ ៕



សិក្ខាកាមសិក្សាវគ្គបណ្តុះបណ្តាលសង្គ្រោះ



# រដ្ឋមន្ត្រីក្រសួងសុខាភិបាល អញ្ជើញចុះពិនិត្យស្ថានភាព និងវឌ្ឍនភាពសុខាភិបាល

ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានអញ្ជើញចុះពិនិត្យស្ថានភាព និងវឌ្ឍនភាពសុខាភិបាល នៅមន្ទីរពេទ្យបង្អែក១៦មករានៃខេត្តព្រះវិហារ មានការអញ្ជើញចូលរួមក្នុងឱកាសនោះ រួមមាន លោកស្រី **ឆាំង វ៉ាទី** អភិបាលរងខេត្ត និងប្រតិភូក្រសួងសុខាភិបាល ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃមន្ទីរសុខាភិបាលខេត្ត លោកគ្រូ អ្នកគ្រូពេទ្យជាច្រើនរូប ។



ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល

មានប្រសាសន៍នាឱកាសនោះ លោកស្រី **ឆាំង វ៉ាទី** បានសម្តែងនូវក្តីសោមនស្ស សប្បាយរីករាយចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី ដែលបានឆ្លៀតឱកាសដ៏មមាញឹកចុះមកពិនិត្យវឌ្ឍនភាព និងជួបសំណេះសំណាលជាមួយមន្ត្រីសុខាភិបាលខេត្តព្រះវិហារនាឱកាសនេះ ។ នេះសបញ្ជាក់អោយឃើញពីការយកចិត្តទុកដាក់ គិតគូរអំពីខឿនសុខភាព សុខទុក្ខរបស់ក្រុមគ្រូពេទ្យ មន្ត្រីសុខាភិបាលដែលកំពុងបំពេញការងារនៅក្នុងខេត្តព្រះវិហារ ពីសំណាក់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ សម្តេចបវរមហាធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ក្នុងឱកាសនោះផងដែរ






គណៈអធិបតីថតរូបអនុស្សាវរីយ៍



ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល

លោកស្រីក៏បានថ្លែងអំណរគុណ និងកោតសរសើរនូវការតស៊ូព្យាយាម អំណត់ឆ្លងកាត់នូវការលំបាកសព្វបែបយ៉ាងក្នុងស្មារតីទទួលខុសត្រូវក្នុងការ បំពេញការងារនាពេលកន្លងមករបស់លោកគ្រូ អ្នកគ្រូពេទ្យទាំងអស់ ក្នុងការពិនិត្យព្យាបាលសុខភាព ជូនដល់បងប្អូនប្រជាពលរដ្ឋនៅទូទាំងខេត្តព្រះវិហារ ។

ការចុះពិនិត្យស្ថានភាព និងវឌ្ឍនភាពសុខាភិបាលពីសំណាក់ ឯកឧត្តម **ឈាង រ៉ា** នាឱកាសនេះ ដើម្បីពិនិត្យមើលការអនុវត្តយុទ្ធសាស្ត្រអាទិភាពចម្បង របស់ក្រសួងសុខាភិបាល ដែលបានដាក់ចេញដោយផ្ដោតសំខាន់លើលទ្ធផលនៃការបម្រើសេវា សុខាភិបាលជូនប្រជាពលរដ្ឋតាមរយៈការពង្រឹងរៀបចំឱ្យបានកាន់តែប្រសើរ ទាំងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការបំពាក់បរិក្ខារវេជ្ជសាស្ត្របន្ថែម ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រសម្រាប់ការគាំទ្ររោគវិនិច្ឆ័យជំងឺ និងប្រសិទ្ធភាពនៃការថែទាំព្យាបាល រួមទាំងការត្រួតពិនិត្យនិងពង្រឹងធនធានមនុស្សឆ្លើយតបបានតាមតម្រូវការជាបន្តបន្ទាប់ ។



គណៈអធិបតីថតរូបអនុស្សាវរីយ៍

ក្នុងឱកាសនោះផងដែរ ឯកឧត្តមក៏បានលើកឡើងអំពីយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំរបស់ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជូនដល់អង្គពិធីឲ្យបានជ្រាបកាន់តែច្បាស់ ក្នុងនោះវិស័យសុខាភិបាលត្រូវបានរាជរដ្ឋាភិបាល យកចិត្តទុកដាក់ខិតខំពង្រឹងបន្ថែមនូវសមត្ថភាព មនសិការ វិជ្ជាជីវៈគុណភាពក្រឹត្យក្រមការងារ



លោកស្រី ប៉ាង វ៉ារី អភិបាលរងខេត្ត



លោកគ្រូ អ្នកគ្រូពេទ្យចូលរួមក្នុងពិធី

នៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យទូទាំងខេត្ត និងជំរុញឲ្យមានសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូដោយអនុវត្តឲ្យស្របទៅតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីទទួលបានលទ្ធផលកាន់តែល្អប្រសើរ ៕

# ពិធីបុណ្យអុំទូក បណ្ដែតប្រទីប បង្ហោះគោម អុជកាំជ្រួច និងតាំងពិព័រណ៌ផលិតផលនានានៅខេត្ត



ទិដ្ឋភាពរួមក្នុងកម្មវិធី




គណៈអធិបតីក្នុងពិធី

ក្នុងរយៈពេល០២ថ្ងៃ ថ្ងៃទី១៨ និង១៩ ខែវិច្ឆិកា ឆ្នាំ ២០២៣ រដ្ឋបាលខេត្តព្រះវិហារ ក្រោមការដឹកនាំរបស់ ឯកឧត្តម **គីម រិទ្ធី** ជាអភិបាលនៃគណៈអភិបាលខេត្ត បានផ្ដួចផ្ដើមរៀបចំពិធីប្រណាំងទូក "ង" បណ្ដែតប្រទីប បង្ហោះគោម អុជកាំជ្រួច និងតាំងពិព័រណ៍ផលិតផលនានា នៅរមណីយដ្ឋានទេសចរណ៍ទំនប់៩៥ ស្ថិតនៅភូមិទំនប់ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ដើម្បីបង្កើតភាពសប្បាយរីករាយ សម្រាប់បងប្អូនប្រជាពលរដ្ឋនៅទូទាំងខេត្ត ក៏ដូចជាភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ បានមកកំសាន្តសប្បាយនៅក្នុងខេត្តព្រះវិហារ និងដើម្បីចូលរួមអបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ដែល នឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៦.២៧ និងទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ខាងមុខនេះ ។

ថ្លែងក្នុងឱកាសបិទបញ្ចប់ នៃព្រឹត្តិការណ៍ប្រណាំងទូក "ង" ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ បានសម្ដែងនូវក្ដីសោមនស្សរីករាយ និងសូមអបអរសាទរចំពោះថ្នាក់ដឹកនាំ គណៈកម្មការ អនុគណៈកម្មការ ក្រុមការងារបច្ចេកទេស ក្រុមការងាររៀបចំ និងពិធីការ ព្រមទាំងថ្នាក់ដឹកនាំ កីឡាករទាំងអស់ ដែលបានចូលរួម និងរៀបចំពិធីប្រណាំ



ងទូក "ង" ទូកខ្នាតអន្តរជាតិ ទូកសហគមន៍ បណ្តែតប្រទីបបង្ហោះគោម អុជកាំជ្រួច និងការតាំងពិព័រណ៌ ប្រព្រឹត្តទៅដោយរលូន ទទួលបានជោគជ័យ និងមានភាពអធិកអធម ព្រមទាំងមានការចូលរួមទស្សនាយ៉ាងច្រើនកុះករ ។

ជាមួយនេះឯកឧត្តម ក៏បានសម្តែងនូវការចូលរួមសូមអបអរសាទរចំពោះថ្នាក់ដឹកនាំ និងបងប្អូនកីឡាករទូក ដែលទទួលបានជ័យលាភីចំណាត់ថ្នាក់លេខ១ លេខ២ និងលេខ៣ ទាំងទូកចំណុះ ២២នាក់ ទូកចំណុះ ១២នាក់ និង



កន្លែងអ្នកអត្ថាធិប្បាយ

ទូកចំណុះ៥នាក់ ហើយក៏សូមលើកទឹកចិត្តចំពោះថ្នាក់ដឹកនាំ និងបងប្អូនកីឡាករ ដែលពុំទទួលបានជ័យលាភី ដែលបានខិតខំប្រឹងប្រែង ចូលរួមប្រណាំងដោយស្មារតីសាមគ្គីភាព សំដៅញ៉ាំងឱ្យពិធីអុំទូកមានភាពអធិកអធម និងមានការគាំទ្រពីបងប្អូនទស្សនិកជនយ៉ាងច្រើន ។ ជាមួយគ្នានេះ ទាំងកីឡាករចំណុះទូក ដែលទទួលបានជ័យលាភី និងពុំទទួលបានជ័យលាភី ក៏មានថវិកាឧបត្ថម្ភលើកទឹកចិត្តដូចគ្នា គ្រាន់តែអ្នកទទួលបានជ័យលាភីទទួលបានថវិកាឧបត្ថម្ភច្រើនជាងប៉ុណ្ណោះ ។

ឯកឧត្តមអភិបាលខេត្តបានបន្តថា ព្រឹត្តិការដ៏សប្បាយរីករាយនេះ គឺស្ថិតក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ដែលបានសបញ្ជាក់ឱ្យឃើញអំពីភាពរីកចម្រើន និងសុដុមរមនីយកម្ម នៃសង្គមជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តដឹកនាំប្រទេសជាតិឱ្យមានសុខសន្តិភាព និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត ក្នុងការប្រតិបត្តិតាមមាគ៌ាមរតកនយោបាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** ដែល



កីឡាករអុំទូក

ជាប្រតិបត្តិករដ៏ឆ្នើមនៃការរំដោះប្រទេសជាតិ និងសង្គ្រោះប្រជាជនឱ្យរួចផុតពីរណ្តៅមរណៈ នៃរបបប្រល័យពូជសាសន៍ដ៏យង់ឃ្នង និងបានស្វែងរកសុខសន្តិភាព ជូនជាតិមាតុភូមិកម្ពុជា តាមរយៈការអនុវត្តប្រកបដោយជោគជ័យនូវ គោល នយោបាយ ឈ្នះ! ឈ្នះ! ។

ទន្ទឹមនឹងនេះឯកឧត្តម **គីម រិទ្ធី** ក៏បានលើកឡើងថានឹងកែប្រែសោភ័ណភាពរមណីដ្ឋានទំនប់៩៥ ឲ្យកាន់តែមានភាពទាក់ទាញថែមទៀត ជាមួយនឹងការអភិវឌ្ឍពង្រីកផ្លូវខ្នងទំនប់ដោយ ក្រាលកៅស៊ូ ធ្វើផ្លូវក្រាលក្រួសក្រហមជុំវិញបឹង និងធ្វើវេទិការអុំទូកឱ្យបានស្អាត ដើម្បីឲ្យពិធីប្រណាំងទូកនៅឆ្នាំក្រោយ ឆ្នាំ២០២៤ កាន់តែមានភាពទាក់ទាញ និងអធិកអធមថែមទៀត ។

បើតាមរបាយការណ៍ របស់មន្ទីរទេសចរណ៍ខេត្តព្រះវិហារបានបង្ហាញថាពិធីបុណ្យអុំទូក បណ្តែតប្រទីបសំពះព្រះខែអកអំបុក និងតាំងពិព័រណ៌ផលិតផល និងសក្តានុពលរបស់ខេត្ត រយៈពេល ០២ថ្ងៃនេះ មានបងប្អូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិអន្តរជាតិបានមកទស្សនាកម្សាន្តយ៉ាងច្រើនកុះករ ប្រកបដោយទឹកមុខសប្បាយរីករាយនៅក្នុងព្រឹត្តិការណ៍វប្បធម៌ និងទេសចរណ៍នេះសរុបប្រមាណជាង ២៥,៣០០នាក់ បើធៀបនឹងពិធីបុណ្យអុំទូកឆ្នាំមុន កើនឡើងចំនួន១៦៦,៣២% ៕

# ពិធីបញ្ចុះបឋមសិលា សាងសង់អគារព្យាបាលអ្នករស់នៅជាមួយ មេរោគអេដស៍ ដោយឱសថប្រឆាំងមេរោគអេដស៍

អភិបាលខេត្តព្រះវិហារ អំពាវនាវដល់អ្នកពាក់ព័ន្ធពិសេសក្រុមប្រឈមមុខខ្ពស់ ចូលរួមផ្សព្វផ្សាយបង្ការទប់ស្កាត់ការចម្លងថ្មី និងឈានទៅបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ ឱ្យបានសម្រេចជោគជ័យ ។



គណៈអធិបតីក្នុងពិធី

អភិបាលខេត្តព្រះវិហារ ឯកឧត្តម **គីម រិទ្ធី** បានអំពាវនាវដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ពិសេសក្រុមប្រឈមមុខខ្ពស់ក្នុងចំណោមយុវជននិងអ្នកបម្រើសេវាកម្សាន្តនានា ត្រូវយកចិត្តទុកដាក់ក្នុងការអប់រំផ្សព្វផ្សាយទាក់ទង នឹងការបង្ការ ថែទាំ ព្យាបាលជំងឺអេដស៍ និងកាមរោគដល់ប្រជាជនទូទៅ ជាពិសេសក្រុមដែលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ត្រូវចូលរួមក្នុងការអនុវត្តនូវវិធានការបង្ការការចម្លងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ដើម្បីសុខភាពផ្ទាល់ខ្លួន និងដើម្បីទប់ស្កាត់ការចម្លងថ្មី និងឈានទៅបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ ឱ្យបានសម្រេចជោគជ័យ ។



ការថ្លែងបែបនេះ បានធ្វើឡើងក្នុងកំឡុងពេលដែលឯកឧត្តមបានអញ្ជើញជាអធិបតីភាព ក្នុងពិធីបញ្ចុះបឋមសិលា សាងសង់អគារព្យាបាលអ្នករស់នៅជាមួយមេរោគអេដស៍ ដោយឱសថប្រឆាំងមេរោគអេដស៍ ក្នុងបរិវេណមន្ទីរ




គណៈអធិបតីក្នុងពិធី

ពេទ្យបង្អែកជាំក្សាន្ត ស្ថិតក្នុងភូមិសាស្ត្រភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ។

ក្នុងឱកាសនោះដែរ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ក៏បានផ្តាំផ្ញើរដល់ប្រជាពលរដ្ឋ ពិសេសស្រទាប់យុវជនត្រូវនាំគ្នាអនុវត្តនូវវិធីសាស្ត្រ មិត្តអប់រំមិត្ត ក្នុងការចាកឆ្ងាយពីគ្រឿងញៀន ភាពភ្លើតភ្លើនផ្លូវភេទ ដែលជាហានិភ័យខ្ពស់នៃការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគផ្សេងៗ ។ ជាមួយនេះក្នុងករណីសង្ស័យថាបានប្រឈមនឹងមេរោគអេដស៍ត្រូវស្វែងរកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តមេរោគអេដស៍ឱ្យបានឆាប់បំផុត ទទួលបានការថែទាំសុខភាព និងត្រូវប្រើថ្នាំប្រឆាំងឱ្យបានត្រឹមត្រូវ ទៀតទាត់ និងជាប់លាប់ ។ លើសពីនេះទៀត ត្រូវចូលរួមលើកទឹកចិត្ត និងមិនរើសអើង ឬ មាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ឡើយ ។

សូមបញ្ជាក់ថា បើយោងតាមរបាយការណ៍របស់លោកវេជ្ជបណ្ឌិត **គួច ឡូ** ប្រធានមន្ទីរសុខាភិបាលខេត្តបានឲ្យដឹងថា ការបញ្ចុះបឋមសិលាសាងសង់អគារព្យាបាលជំងឺអេដស៍ និងកាមរោគនៅក្នុងថ្ងៃនេះ គឺមានទំហំ ៧ម៉ែត្រគុណនិង១៦ម៉ែត្រ ធ្វើអំពីថ្ម ប្រក់ស៊ីប្រូស៊ីម៉ង់ និងគ្រោងបញ្ចប់ការសាងសង់ក្នុងកំឡុងចុងខែកុម្ភៈ ឆ្នាំ២០២៤ខាងមុខ ដោយចំណាយថវិកាសរុបប្រមាណជិត ៣ម៉ឺនដុល្លាអាមេរិច ក្រោមជំនួយថវិការបស់មូលនិធិសកល តាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។



ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត



អ្នកចូលរួមក្នុងពិធី



ទិដ្ឋភាពរួមក្នុងពិធី

# កម្ពុជា-ថៃបើកកិច្ចប្រជុំពិភាក្សាលើការបើកឲ្យដំណើរការច្រកទ្វារព្រំដែនអានសេះ-អានម៉ា ទៅជាច្រកអន្តរជាតិ

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្ថិតនៅចំនុចភូមិអានសេះឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានរៀបចំកិច្ចប្រជុំប្រជុំពិភាក្សា លើការបើកអោយដំណើរការច្រកទ្វារព្រំដែនអាន សេះ-អានម៉ា ទៅជាច្រកអន្តរជាតិ ដែលភាគីកម្ពុជាដឹកនាំដោយ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត នឹងភាគីថៃដឹកនាំដោយឯកឧត្តម **ស៊ុំផាសិទ្ធ ក្វចារឿនយុត** អភិបាលខេត្តឧប៊ុនរាជធានី ព្រមទាំងមានការចូលរួមពីគណៈប្រតិភូនៃខេត្តទាំងពីរជាច្រើនរូបផងដែរ ។



ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត

ឯកឧត្តម **គីម រិទ្ធី** បានឲ្យដឹងថា កន្លងមកយើងសម្រេចបាននូវលទ្ធផលជាច្រើន ដែលកើតឡើងពីខិតខំ




គណៈអធិបតីថតរូបអនុស្សាវរីយ៍

ប្រឹងប្រែងរវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនតាមបណ្តោយព្រំដែន ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥ អំឡុងពេលកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃ(JCR)លើកទី២ ការសម្របសម្រួលដល់ការ ធ្វើជំនួញផលិតផលកសិកម្មឆ្លងកាត់ព្រំដែន ការសម្របសម្រួលប្រជាពលរដ្ឋនៅព្រំដែន បានឆ្លងដែនទៅព្យាបាលជំងឺនៅមន្ទីរពេទ្យស្រុកណាំយ៉ឺននិងមន្ទីរពេទ្យខេត្តឧប៊ុនរាជធានី ការសហការរៀបចំរួមគ្នាក្នុងវិស័យប្រពៃណីសាសនា ការដង្ហែទៀនវស្សា បុណ្យកឋិនទាន ការដាំកូនឈើ និងបុណ្យប្រពៃណីផ្សេងៗទៀត ព្រមទាំងការបញ្ជូនសិស្ស-និស្សិត ទៅបន្តនៅតាមសកល វិទ្យាល័យនានាក្នុងខេត្តឧប៊ុនរាជធានីផងដែរ ។

ជាមួយនេះ ដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការក៏ដូចជាពង្រឹងចំណងមិត្តភាព សាមគ្គីភាព ឲ្យកាន់តែជិតស្និទ្ធថែមមួយកម្រិតទៀតរវាងខេត្តព្រះវិហារ និងខេត្តឧប៊ុនរាជធានី ឯកឧត្តម **គីម រិទ្ធី** បានស្នើសុំដល់ភាគីថៃនូវសំណើមួយ

ចំនួនដូចជា ស្នើសុំឲ្យអាជ្ញាធរនៃខេត្តទាំង២ ត្រូវបន្តកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរព័ត៌មានអោយគ្នានូវរាល់សភាពការណ៍ និងបាតុភាពនានា ដែលកើតមានតាមបណ្តោយព្រំដែន នឹងជំរុញការបើកអោយដំណើរការ ច្រកអានសេះ-អានម៉ា ៧ថ្ងៃក្នុងមួយសប្តាហ៍ និងឈានទៅដំឡើងជាច្រកអន្តរជាតិ តាមស្មារតីកិច្ចប្រជុំកាលពីថ្ងៃទី១០៦ ខែកញ្ញា ឆ្នាំ២០២២ ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត ។ បន្ថែមពីនេះសុំបន្តពង្រឹងចំណងសាមគ្គីភាពរវាងកងកម្លាំងការពារព្រំដែនប្រទេសទាំងពីរ រក្សាបានព្រំដែនសន្តិសុខមិត្តភាព និងសុំរក្សាស្ថានភាពដើមនៅតំបន់ព្រំដែនដែលមិនទាន់មានការឯកភាពគ្នា រហូតដល់គណៈកម្មការព្រំដែននៃប្រទេសទាំងពីរ ឯកភាពលើខ័ណ្ឌសីមា និងបោះបង្គោលព្រំតាមតំបន់នោះឲ្យរួចរាល់ជាស្ថាពរសិន ។

សូមបញ្ជាក់ថា ការស្នើសុំជំរុញការបើកឲ្យដំណើរការច្រកអានសេះ-អានម៉ា ៧ថ្ងៃក្នុងមួយសប្តាហ៍ និងឈានទៅដំឡើងជាច្រកអន្តរជាតិ ខាងភាគីថៃ នឹងស្នើសុំទៅក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រថៃពន្លឿនការបើកឲ្យដំណើរការច្រកទ្វាមួយនេះ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ឲ្យកាន់តែល្អប្រសើរតាមរយៈការទំនាក់ទំនងការផ្លាស់ប្តូរទំនិញរួមគ្នា ៕



ឯកឧត្តម ស៊ីផាសិទ្ធិ កូចារឿនយុត អភិបាលខេត្តឧប៊ុន




ទិដ្ឋភាពក្នុងកិច្ចប្រជុំ



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំកំណត់តំបន់ដីផលិតកម្មដំណាំកសិកម្មសរីរាង្គក្នុងខេត្ត



*ទិដ្ឋភាពរួមក្នុងសិក្ខាសាលា*

មន្ត្រីជាន់ខ្ពស់ក្រសួងកសិកម្ម បានលើកឡើងថា ខេត្តព្រះវិហារគឺជាខេត្តគោលដៅតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលដាក់ទិសដៅជំរុញឲ្យក្លាយជាខេត្តផលិតកម្មដំណាំកសិកម្មសរីរាង្គ ។

ថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំកំណត់តំបន់ដីផលិតកម្មដំណាំកសិកម្មសរីរាង្គ ក្នុងខេត្តព្រះវិហារ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ ឯកឧត្តម **ស៊្រុន សុខុម** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឲ្យដឹងថារាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីបានដាក់ចេញនូវទិសដៅសំខាន់ ៗ ចំនួន០៣ សម្រាប់ខេត្តព្រះវិហារ គឺ៖ ទីមួយ.កំណត់យកខេត្តព្រះវិហារ ជាខេត្តផលិតនូវកសិផលដំណាំសរីរាង្គ ជាពិសេសដំណាំស្រូវ ដំណាំចន្ទី និងដំណាំដំឡូងមី ។ ទីពីរ.ជំរុញការធ្វើស្លាកសញ្ញាសម្គាល់នូវកសិផលសរីរាង្គទាំងអស់នោះ និងទីបី.ជំរុញឲ្យមានការរៀបចំសហគមន៍កសិកម្ម ដែលមានសមាហរណកម្មខ្ពស់ឆ្លើយតបទៅទីផ្សារ ។ ឯកឧត្តម បានបន្ថែមទៀតថា ផ្តើមចេញពីទស្សនៈវិស័យនេះខេត្តព្រះវិហារ គឺជាខេត្តគោលដៅតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលរាជរដ្ឋាភិបាលដាក់ទិសដៅជំរុញឲ្យ




*គណៈអធិបតីក្នុងសិក្ខាសាលា*



ក្លាយជាខេត្តផលិតកម្មដំណាំកសិកម្មសរីរាង្គ ។ ជាក់ស្តែង សិក្ខាសាលាដែលរៀបចំឡើងនៅក្នុងថ្ងៃនេះ គឺបានកំណត់យកស្រុកចំនួន ៥ក្នុង ចំណោមក្រុង-ស្រុក ទាំង ៨ក្នុងខេត្តព្រះវិហារ ជាស្រុកគោលដៅរួមមាន៖ ស្រុករវៀង ស្រុកជ័យសែន ស្រុកឆែប ស្រុកគូលែន និងស្រុកជាំក្សាន្ត ដែលអាចកំណត់តំបន់ដែរមានសក្តានុពល ធ្វើសរីរាង្គបានមានចំនួន ៥ស្រុក២៨ឃុំនិង១១៧ភូមិនិងសិក្សាបន្តដែលមានដំណាំសក្តានុពលសរីរាង្គចំនួន ០៨ប្រភេទ រួមមាន៖ ស្រូវ ដំឡូងមី ចន្ទី សណ្តែកដី សណ្តែកបាយ សណ្តែកសៀង បន្លែ និងម្រេច ។

មានមតិស្វាគមន៍នាឱកាសនោះ លោក **មិន ស៊ីថា** អភិបាលរងខេត្ត បានឲ្យដឹងថាខេត្តព្រះវិហារ គឺជាខេត្តមួយក្នុងចំណោមខេត្ត/ក្រុងទាំង ២៥ របស់ព្រះរាជាណាចក្រ



*ទិដ្ឋភាពរួមក្នុងសិក្ខាសាលា*

កម្ពុជា ដែលមានសក្តានុពលធ្វើកសិកម្មសរីរាង្គ និងជាប្រភពផ្គត់ផ្គង់កសិផលសរីរាង្គច្រើនជាងគេដូចជា៖ ស្រូវសរីរាង្គ ដំឡូងមីសរីរាង្គ ស្វាយចន្ទីសរីរាង្គជាដើម ។ ឯកឧត្តមបានបន្តថា ភាពជោគជ័យរបស់ខេត្ត ក្នុងការអនុវត្តកសិកម្មសរីរាង្គមានកត្តាចំនួន ៣ធំៗ៖ ទីមួយ.កត្តាភូមិសាស្ត្រ៖ខេត្តព្រះវិហារ មានដីដែលមាននូវជីវជាតិខ្ពស់ ដីស្រែទួលខ្ពស់ដែលមិនសូវមានហានីភ័យ ក្នុងការឆ្លងនូវសារធាតុគីមី ។ ទីពីរ.កត្តាមនុស្ស៖ប្រជាជនតាំងលំនៅតំបន់នេះបានប្រកបមុខរបរកសិកម្មបែបប្រពៃណីជាយូរលង់ ព្រមទាំងមានភាពស្មោះត្រង់រវាងគ្នានិងគ្នា និងទីបី. កត្តាដៃគូរពាក់ព័ន្ធ ដែលមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ។ហើយផលប្រយោជន៍ដែលទទួលបានពីភាពជោគជ័យនេះ គឺប្រាក់ចំណូលរបស់ប្រជាកសិករ ដែលចូលរួមក្នុងការអនុវត្តកសិកម្មសរីរាង្គតាមរយៈការទទួលបានតម្លៃបន្ថែមពីថ្លៃបុព្វ លាភនៃការ



*ទិដ្ឋភាពរួមក្នុងសិក្ខាសាលា*

លក់ផលិតផលសរីរាង្គ និងយន្តការនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលធានាបានថាកសិផលសរីរាង្គរបស់កសិករ គឺមានទីផ្សារច្បាស់លាស់តាំងពីពេលចាប់ផ្តើមដាំដុះមកម្ល៉េះ ដោយមិនមានកង្វល់ពីការស្វែងរកទីផ្សារ ។

លោក **ពឹង ធ្វឺដា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បានបញ្ជាក់ថា គោលបំណងនៃការរៀបចំសិក្ខាសាលានេះឡើង គឺដើម្បីជូនដំណឹងដល់ភាគីពាក់ព័ន្ធឲ្យបានដឹងពីការ រៀបចំកំណត់តំបន់ដីផលិតកម្មដំណាំកសិកម្មសរីរាង្គក្នុងខេត្តព្រះវិហារ ។ ដើម្បីប្រមូលព័ត៌មានបឋមពីតំបន់គោលដៅ នៃផលិតកម្មសរីរាង្គដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន និងកំណត់តំបន់សក្តានុពលមួយចំនួនដែលអាចផលិតដំណាំសរីរាង្គបាននៅក្នុងខេត្ត និងដើម្បីប្រមូលធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធក្នុងខ្សែរសង្វាក់ផ្គត់ផ្គង់កសិផលសរីរាង្គពីដំណើរការនៃការកំណត់ដែនសរីរាង្គ នេះ និងដើម្បីកំណត់តំបន់ដីផលិតកម្មសរីរាង្គណាមួយ ដែលមានសក្តានុពល ដើម្បីចាប់ផ្តើមអនុវត្តការធ្វើសាកល្បង៕




*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

# សកម្មភាពថ្នាក់ដឹកនាំ

*កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្ត ក្រោមអធិបតីភាពឯកឧត្តម មាស សុភា ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣*









*តំបន់ប្រតិបត្តិការសឹករងខេត្ត បិទវគ្គហ្វឹកហ្វឺន បំប៉នយុទ្ធវិធីខ.គ ថ្មើរជើង ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម គឹម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣*









# សកម្មភាពថ្នាក់ដឹកនាំ







ឯកឧត្តម គីម រិទ្ធី អភិបាលនៃគណៈអភិបាលខេត្ត ដឹកនាំក្រុមការងារថ្នាក់ខេត្ត នាំយកថវិកាចំនួន ២៩១លានរៀល ទៅប្រគល់ជូនមន្ទីរពេទ្យគន្ធបុប្ផាខេត្តសៀមរាប ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣







ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣






កិច្ចប្រជុំពិភាក្សាគម្រោងគំនូសប្លង់គោល នៃការកែលម្អ និងអភិវឌ្ឍន៍ខេត្ត ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣






កិច្ចប្រជុំបូកសរុបលទ្ធផលការងារការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ឆ្នាំ២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាព លោកជំទាវ ប្រាក់ ថាវៈភារី អគ្គនាយករងនៃមូលនិធិជាតិជំនួយសង្គម ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម អ៊ុំ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ក្នុងកិច្ចប្រជុំត្រួតពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣






សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជននិងកីឡាឆ្នាំសិក្សា២០២១.២០២២ និងលើកទិសដៅឆ្នាំសិក្សា២០២២.២០២៣ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣














ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នឹងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាអធិបតីភាពក្នុងពិធីសម្ពោធឆ្លងសាលារៀន សាលាវិបស្សនា នឹងបញ្ចុះបឋមសិលាសាងសង់មណ្ឌលចិញ្ចឹម នឹងថែទាំមនុស្សចាស់ជរា ក្នុងវត្តព្រះបរមរាជ មហាពោធិ បញ្ចុះសហស្សារាម ហៅវត្តពោធិ៍៥០០០ដើម ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ជួបសម្តែងការគួរសមជាមួយ ឯកឧត្តម យ៉ុំសន ខុនប៉ាសើត អគ្គកុងស៊ុលនៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំខេត្តស្ទឹងត្រែង ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣*






*និស្សិត ៣ជំនាន់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចុះកម្មសិក្សាស្វែងយល់ពីសក្តានុពលវិស័យកសិកម្មរបស់ខេត្តព្រះវិហារ ដឹកនាំដោយលោក អេង លេង ព្រឹទ្ធបុរសរងមហាវិទ្យាល័យសេដ្ឋកិច្ច កសិកម្ម និងអភិវឌ្ឍន៍ជនបទ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣*







# សកម្មភាពថ្នាក់ដឹកនាំ

*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ជាអធិបតីក្នុងពិធីបិទការប្រកួតបាល់ទាត់មហាជនពានរង្វាន់ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពដើម្បី អបអរសាទរទិវាសិទ្ធនារីអន្តរជាតិ ៨មីនាខួបលើកទី១១២ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣*









*ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្ត ក្រោមអធិបតីភាព ឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣*














នាយឧត្តមសេនីយ៍ ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិ អញ្ជើញបិទសន្និបាតបូក សរុបលទ្ធផលការងារឆ្នាំ២០២២ នឹងលើកទិសដៅអនុវត្តឆ្នាំ២០២៣ របស់ស្នងការដ្ឋាន នគរបាលខេត្ត ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣






ពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលឆ្នាំ២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ឯកឧត្តម ខូយ យុនហ៊ី ប្រធានក្រុមប្រឹក្សាខេត្តស្ដីទី ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣









ឯកឧត្តម មាស សុខសេនសាន អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះសួរសុខទុក្ខ និងនាំយកអំណោយមកផ្តល់ជូន កងកម្លាំងការពារព្រំដែន ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២៣ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣










ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចុះសួរសុខទុក្ខ និងនាំយកអំណោយមកផ្តល់ជូនកម្លាំងនគរបាលជាតិប្រចាំទិសភូមិភាគ៤ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនកម្លាំងបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្ត
ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២៣ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣






ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនស្នងការដ្ឋាននគរបាលខេត្ត
ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២៣ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣






# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំ២០២៣ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣









ពិធីសូត្រមន្ត និងចែកអំណោយដល់គណៈអភិបាល-ក្រុមប្រឹក្សាខេត្ត-ក្រុង-ស្រុកទូទាំងខេត្ត ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ









លោក មិន ស៊ីថា អភិបាលរងខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបុណ្យកាត់ខ្សែបូសម្ពោធឆ្លងកុដិ របង ចេតិយ និងសមិទ្ធផលនានាក្នុងវត្តសិលានិមិត្ត ហៅវត្តកំពង់ពុទ្រា ស្ថិតនៅភូមិពុទ្រា ឃុំពុទ្រា ស្រុកជ័យសែន ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣









កិច្ចប្រជុំរៀបចំពិធីជូនដំណើរផ្ញើមាតុភូមិនិវត្តន៍អដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាម ក្រោមអធិបតីភាពលោក អ៊ុង វុទ្ធី អភិបាលរងខេត្ត និងលោកជំទាវ ង្វៀង ធីថាញ់ឡឹប អនុប្រធានគណៈកម្មាធិការប្រជាជនខេត្តយ៉ាឡាយ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ









ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ២០២៣ ដែលកម្ពុជាយើងធ្វើជាម្ចាស់ផ្ទះ ខេត្តព្រះវិហារបានចាក់បញ្ចាំងស្លាយ និងចាក់បញ្ចាំងតាមកញ្ចក់LED ចាប់ពីថ្ងៃទី០២ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣










ឧត្តម គីម រិទ្ធី អភិបាលខេត្ត  អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងស្រុកឆែប ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត និងជាប្រធានកិត្តិយសសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត ក្នុងពិធីប្រគល់សម្ភារគ្រឿងឧបភោគ បរិភោគជូនសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣









រដ្ឋបាលខេត្តព្រះវិហាររៀបចំពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាគម្រប់ព្រះជន្ម៧០ យាងចូល ៧១ព្រះវស្សា ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត ជាអធិបតីក្នុងទិវាជាតិនៃការចងចាំ ២០ឧសភា ក្នុងតំបន់១០៣ ស្រុករវៀង ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣











លោក ឃឹម បញ្ញា អភិបាលរងខេត្ត បើកវិញ្ញាសាប្រឡងក្របខណ្ឌក្រសួងមហាផ្ទៃ ដើម្បីបម្រើការងារនៅសាលាស្រុកត្បែងមានជ័យសម្រាប់ឆ្នាំ២០២៣ នៅសាលាជាស៊ីមត្បែងមានជ័យ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ






កិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០២៣ របស់គណៈកម្មាធិការបណ្តុះបណ្តាលខេត្ត ក្រោមអធិបតីលោក យឹម បញ្ញា អភិបាលរងខេត្ត ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣






ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញចុះសំណេះសំណាល និងបើកយុទ្ធនាការអំពីការកាត់ឈៀលដីជូនប្រជាពលរដ្ឋ នៅភូមិអភិវឌ្ឍន៍ សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ






ពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តជូនមន្ទីរពេទ្យបង្អែក ១៦មករា ខេត្តព្រះវិហារ នៅស្រុកត្បែងមានជ័យ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣






ពិធីសំណេះសំណាល និងបំពាក់មេដាយជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា ចំនួន ៣៦៥ នាក់ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ក្នុងបរិវេណតំបន់ប្រតិបត្តិការសឹករងខេត្ត ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

*សន្និបាតបូកសរុបការងារក្រុមប្រឹក្សាគណៈឱសថការីខេត្តព្រះវិហារអាណត្តិទី២ និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគណៈឱសថការីខេត្ត ក្រោមអធិបតីភាពឯកឧត្តមឱសថការី បាន បុត្តា អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣*






*ពិធីសំណេះសំណាល និងបំពាក់មេដាយជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា ចំនួន ៦៧២នាក់ ក្រោមអធិបតីភាពឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ស្រុកជាំក្សាន្ត ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣*






# សកម្មភាពថ្នាក់ដឹកនាំ

*ពិធីសំណេះសំណាល និងបំពាក់មេដាយជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា ចំនួន ២៦៥នាក់ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ក្នុងស្រុករវៀង ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣*









*កិច្ចប្រជុំក្រុមការងារផ្សព្វផ្សាយបណ្តាញសង្គម KSM2 ប្រចាំខេត្ត ក្រោមអធិបតីភាពលោក ណុប វុទ្ធី អភិបាលរងខេត្ត និង ជាប្រធានក្រុមការងារ  ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣*










# សកម្មភាពថ្នាក់ដឹកនាំ






ពិធីជួបសម្ដែងការគួរសមរវាងឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ជាមួយអគ្គកុងស៊ុលកូរ៉េប្រចាំខេត្តសៀមរាប និងបន្តជួប
អគ្គកុងស៊ុលវៀតណាមប្រចាំខេត្តបាត់ដំបង ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣







ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចុះពិនិត្យលក្ខណៈបច្ចេកទេស និងតាមដានវឌ្ឍនភាពការងារសាងសង់ផ្លូវលំជនបទ ០១ខ្សែ
ក្រាលកៅស៊ូប្រភេទDBST ដែលមានប្រវែង ប្រមាណ ២៤,២គីឡូម៉ែត្រ ក្នុងស្រុកសង្គមថ្មី ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣









ឯកឧត្តម អ៊ុំ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងមហាផ្ទៃអញ្ជើញជាអធិបតី កិច្ចប្រជុំបូកសរុបលទ្ធផលការងារអនុវត្តគោលនយោបាយ "ភូមិឃុំ សង្កាត់មានសុវត្ថិភាព"ប្រចាំត្រីមាសទី២ និងលើកទិសដៅអនុវត្តការងារត្រីមាសទី៣ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣









យុទ្ធនាការផ្សព្វផ្សាយអប់រំសុខភាពស្ដីពីជំងឺគ្រុនឈាមក្រោមប្រធានបទ(ខ្ញុំនិងគ្រួសារខ្ញុំជាគ្រួសារគំរូ ព្រោះផ្ទះខ្ញុំនិងលំនៅដ្ឋានរបស់ខ្ញុំគ្មានជង្រុកទឹក និងគ្មានវត្ថុដែលអាចដក់ទឹកបាន) លោក មិន ស៊ីថា អភិបាលរងខេត្ត ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ក្រុមគ្រូពេទ្យស្ម័គ្រចិត្តឯកឧត្តម ហ៊ុន ម៉ានី ប្រចាំខេត្តព្រះវិហារ ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ឃុំកំពង់ស្រឡៅ ស្រុកឆែប ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣









ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញបើកការដ្ឋានសាងសង់ផ្លូវក្រាលក្រួសក្រហម ០១ខ្សែប្រវែង ១.២០០ម៉ែត្រ និងសម្ពោធសមិទ្ធផលផ្លូវនានាក្នុងក្រុងព្រះវិហារ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣










ពិធីសម្ពោធសមិទ្ធិផលនានាក្នុងវត្តទក្សិណគីរី ហៅវត្តសំឡាញ ស្ថិតក្នុងភូមិសំឡាញ ឃុំភ្នំត្បែងមួយ ក្នុងស្រុកសង្គមថ្មី ក្រោមអធិបតីភាពឯកឧត្តម មាស សុភា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣









ពិធីដាក់ឲ្យប្រើប្រាស់សាលកុំព្យូទ័រសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (ស.ស.យ.ក.) នៅវិទ្យាល័យគូលែន ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ






ពិធីដាក់ឲ្យប្រើប្រាស់សាលកុំព្យូទ័រសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (ស.ស.យ.ក.)នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ជា ស៊ីម ត្បែងមានជ័យ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣






ពិធីដាក់ឲ្យប្រើប្រាស់សាលកុំព្យូទ័រសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (ស.ស.យ.ក.) នៅវិទ្យាល័យតាសែងព្រះខ័ន ស្រុកសង្គមថ្មី ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣






ការជួបសម្តែងការគួរសមជាមួយឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជា ជាមួយឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត នៅសាលាខេត្តព្រះវិហារ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣






ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ចូលរួមក្នុងពិធីប្រគំតន្ត្រីអបអរសាទរខួបលើកទី១៥ នៃការចុះបញ្ជីប្រាសាទព្រះវិហារជាសម្បត្តិបេតកភ័ណ្ឌពិភពលោក នៅរង្វង់មូលស្រអែម ស្រុកជាំក្សាន្ត ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងបរិវេណសាលាក្រុងព្រះវិហារ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣










ពិធីដាក់ឲ្យប្រើប្រាស់សាលកុំព្យូទ័រសហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (ស.ស.យ.ក.) នៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ជាំក្សាន្ត នៅស្រុកជាំក្សាន្ត ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

ពិធីបើកវគ្គហ្វឹកហ្វឺនបំប៉នពង្រឹងនាយទាហាន នាយទាហានរង ពលទាហាន និងវគ្គហ្វឹកហ្វឺនម្ចាស់ការនៅហ្នឹងកន្លែងយុទ្ធវិធីថ្នាក់ពួក ក្រុម កងអនុសេនាតូច ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាល ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣









ទិដ្ឋភាពនៃការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្នុងខេត្តព្រះវិហារ មានប្រជាពលរដ្ឋចំនួន ១២៧,១០៣ នាក់ ស្មើនិងជាង ៨៤% បានអញ្ជើញទៅបោះឆ្នោត ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣
















ទិដ្ឋភាពនៃការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្នុងខេត្តព្រះវិហារ មានប្រជាពលរដ្ឋចំនួន ១២៧,១០៣ នាក់ ស្មើនិងជាង ៨៤% បានអញ្ជើញទៅបោះឆ្នោត ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣






វគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តកម្មវិធី និងការឧបត្ថម្ភអត្រាថ្មីសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារ ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ២ឆ្នាំ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣









កិច្ចប្រជុំពិភាក្សាការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីស្តីពីកិច្ចការពារសិទ្ធិស្ត្រី និងការលើកម្ពស់សមភាពយេនឌ័រក្នុងការអនុវត្តច្បាប់ និងវិធានការនានា ក្រោមអធិបតី លោកជំទាវ កែវ ចរិយា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣









គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំសន្និបាតបូកសរុបលទ្ធផលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោក វ៉ាត ប៉ាក់នីន អភិបាលរងខេត្ត ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

ឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងបរិវេណសាលាស្រុកជាំក្សាន្ត ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣











កិច្ចប្រជុំពិភាក្សាការងារគ្រប់គ្រងសមាគម សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងខេត្តព្រះវិហារ ក្រោមអធិបតីភាពលោក វ៉ត ប៉ាវ៉ានីន អភិបាលរងខេត្ត ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣











# សកម្មភាពថ្នាក់ដឹកនាំ

*ឯកឧត្តម ប្រាក់ សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត និងជាប្រធានគណៈកម្មាធិការ រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាខេត្ត អញ្ជើញទទួលដំណើរទស្សនកិច្ច គណៈប្រតិភូក្រសួងការពារជាតិវៀតណាម ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣*









*ក្រុមអ្នកដើរព្រៃកម្ពុជា CAT បានរៀបចំកម្មវិធីបោះតង់ និងកីឡារត់ឡើងភ្នំដំបូងក្នុងខេត្តព្រះវិហារ នៅតំបន់ទេសចរណ៍លើភ្នំត្បែង មានជ័យនៃសហគមន៍តាំងយូរ ក្រោមប្រធានបទ " កីឡាដើម្បីទេសចរណ៍ និងសហគមន៍" ថ្ងៃទី១២-១៣ ខែសីហា ឆ្នាំ២០២៣*









# សកម្មភាពថ្នាក់ដឹកនាំ









ឯកឧត្តម មាស សុភា ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហា នាំយកទៀនព្រះវស្សា គ្រឿងឧបភោគបរិភោគ និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា នៅក្នុងប្រាសាទគោកបេង ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣










ឯកឧត្តម ប្រាក់ សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម គីម រិទ្ធី អភិបាលខេត្តបានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី លើកដំបូងនីតិកាលទី៧ នៃរដ្ឋសភា តាមរយៈប្រព័ន្ធបញ្ជូនរូប និងសម្លេង(zoom meeting) ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ










ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ទទួលជួបសម្តែងការគួរសមជាមួយគណៈប្រតិភូខេត្តយ៉ាឡាយនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ឯកឧត្តម ហូ វ៉ាន់នៀន ប្រធានក្រុមប្រឹក្សាប្រជាជនខេត្តយ៉ាឡាយ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣












គម្រោងនើធ័រ ចុះកិច្ចព្រមព្រៀងជាមួយមន្ទីរកសិកម្ម និងមន្ទីរធនធានទឹកខេត្ត ដើម្បីរួមគ្នាគាំទ្រដល់គ្រួសារកសិករខ្នាតតូច ក្រោមវត្តមានលោក ពឹង ទ្រីដា ប្រធានមន្ទីរកសិកម្ម លោក វង្ស ឡូ អនុប្រធានមន្ទីរធនធានទឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

*កិច្ចប្រជុំក្រុមការងារផ្សព្វផ្សាយបណ្តាញសង្គម KSM2 ខេត្តព្រះវិហារ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣*










*វគ្គបណ្តុះបណ្តាលស្តីពីការជំរុញ និងពន្លឿនស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល ក្រោមអធិបតីភាពលោក អ៊ុក គីមសាន្ត អភិបាលរងខេត្ត ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣*









# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្តព្រះវិហារ ទទួលថវិកាចំនួន ៥,០០០ដុល្លារ (ប្រាំពាន់ ដុល្លារអាមេរិក) ពីអគ្គិសនីកម្ពុជា សាខាខេត្តស្ទឹងត្រែង-ព្រះវិហារ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣










កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២៤-២០២៦ ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣










# សកម្មភាពថ្នាក់ដឹកនាំ











ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងបរិវេណទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣









ពិធីបើកយុទ្ធនាការកំណត់អត្តសញ្ញាណកម្ម ចុះសម្ភាសន៍ផ្តល់បណ្ណសមធម៌ ជូនបុគ្គល ឬ គ្រួសារមានសមាជិកបម្រើការក្នុងវិស័យសេវាកម្សាន្ត ទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោមអធិបតីលោក សុខ សាន្តតារា អភិបាលរងខេត្ត ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ






ក្រុមចលនាស្ត្រីចុះជួបសំណេះសំណាល និងផ្តល់សម្ភារៈសិក្សាដល់កុមារដែលកំពុងសិក្សា នៅមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ប៉ាលហាល ដឹកនាំដោយ លោកជំទាវ ខូយ ប៊ុនថាន ប្រធានក្រុមចលនាស្ត្រីខេត្តព្រះវិហា ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣






ពិធីក្រុងពាលីដើម្បីត្រៀមរៀបចំអបអរសាទរការចុះបញ្ជីរម្មណីយដ្ឋាន ប្រាសាទកោះកេរក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត និង លោកជំទាវ នេត ភូមរី រដ្ឋលេខាធិការក្រសួងវប្បធម៌ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

*វេទិកាសាធារណៈស្តីពីសុខភាព ឆ្នាំ២០២៣ ក្រោមអធិបតីភាព លោកវេជ្ជបណ្ឌិត គួង ឡូ ប្រធានមន្ទីរសុខាភិបាលខេត្ត លោក ហោ ប៊ុនហួរ អភិបាលស្រុករវៀង ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣*










*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញដឹកនាំកិច្ចប្រជុំស្តីពី "វឌ្ឍនភាពការងារសម្រេចបានសម្រាប់ត្រីមាសទី៣ និងលើកទិសដៅអនុវត្តសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ របស់គណៈកម្មាធិការបណ្តុះបណ្តាលខេត្ត ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣*










# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី អភិបាលខេត្តព្រះវិហារ ជួបសម្តែងការគួរសមជាមួយលោក កែវ វង្សស័យ អគ្គកុង់ស៊ុលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំខេត្តស្ទឹងត្រែងនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣









ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជួបសម្តែងការគួរសមជាមួយប្រធានអង្គការអាជ្រាប្រចាំប្រទេសកាណាដា និងប្រធានក្រុមប្រឹក្សាភិបាលអង្គការអាជ្រាកាណាដា ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣














ឯកឧត្តម គីម រិទ្ធី ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជាខេត្ត បាននាំយកអំណោយមនុស្សធម៌ទៅផ្តល់ជូនបងប្អូន ប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ ចំនួន ២៨គ្រួសារ សង្កាត់កំពង់ប្រណាក ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣






ថ្នាក់ដឹកនាំមន្ត្រីរាជការនៃមន្ទីរព័ត៌មានខេត្ត បាននាំយកគ្រឿងឧបភោគបរិភោគ ភេសជ្ជៈ រួមនិងបច្ច័យមួយចំនួន ចូលរួម បុណ្យកាន់បិណ្ឌវេនទី២ នៅវត្តឦសានគិរីសោមគ្គីមានជ័យ ហៅវត្តប្រយុទ្ធ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ









ឯកឧត្តម លេង ផាលី ប្រធានប្រតិបត្តិក្រុមការងារគ្រូពេទ្យស្ម័គ្រចិត្តឯកឧត្តម ហ៊ុន ម៉ានី និងសហការីបាននាំយកនូវសម្ភារៈបរិក្ខាពេទ្យមកផ្តល់ជូនមន្ទីរសុខាភិបាលខេត្ត ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣









ឯកឧត្តម មាស សុខសេនសាន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះសួរសុខទុក្ខ និងនាំយកអំណោយជូនដល់កងកម្លាំងប្រដាប់អាវុធដែលឈរជើងតាមបន្ទាត់ព្រំដែន ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនាពេលខាងមុខ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ

រដ្ឋបាលខេត្ត ប្រារព្ធពិធីគោរពវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ គម្រប់ខួប ១១ឆ្នាំ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣









ថ្នាក់ដឹកនាំមន្ត្រីរាជការនៃមន្ទីរព័ត៌មានខេត្ត បាននាំយកគ្រឿងឧបភោគបរិភោគ ភេសជ្ជៈ រួមនិងបច្ច័យមួយចំនួន ចូលរួមបុណ្យកាន់បិណ្ឌវេនទី១៣ នៅវត្តឧត្តមមុនី ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

ពិធីបិទវគ្គហ្វឹកហ្វឺនបំប៉នពង្រឹង នាយទាហាន នាយទាហានរង និងពលទាហាន តំបន់ប្រតិបត្តិការសឹករងព្រះវិហារ ចំណុះ យោធភូមិភាគទី៤ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣









សិក្ខាសាលាផ្សព្វផ្សាយស្ដីពី «គោលនយោបាយជាតិស្ដីពីស្វាយចន្ទីឆ្នាំ២០២៣-២០២៧» ក្រោមអធិបតីភាពលោកជំទាវ គង់ សិទ្ធិកា អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម លោក មិន ស៊ីថា អភិបាលរងខេត្ត ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ






ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងបរិវេណទីបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ ស្រុកជាំក្សាន្ត ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣






កិច្ចសហប្រតិបត្តិការបន្តរកអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តដែលបានធ្វើពលិកម្មក្នុងសម័យសង្គ្រាម ក្រោមអធិបតីលោក យ៉ុង គីមហ៊ាន អភិបាលរងខេត្ត លោកជំទាវ ង្វៀន ធីថាញ់លិច ប្រធានគណៈកម្មាធិការប្រជាជនខេត្តយ៉ាឡាយ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ









ពិធីបិទវគ្គហ្វឹកហ្វឺកឆ្នាំ២០២២ និងបើកវគ្គហ្វឹកហ្វឺកឆ្នាំ២០២៣ របស់កងពលធំអន្តរាគមន៍លេខ៣ ក្រោមអធិបតីភាព ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ឯកឧត្តម ឧត្តមសេនីយ៍ឯក ស្រី ឌឹក មេបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣









មីទ្ទីងអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងខួបលើកទី១៩ ឆ្នាំនៃការគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ









ទិដ្ឋភាពនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០២២-២០២៣ នៅខេត្ត ដែលមានបេក្ខជនមកប្រឡងសរុប ១,៨២២នាក់ និងអវត្តមាន ចំនួន ១៨នាក់ ដែលភាគច្រើនជាសិស្សស្វ័យរិន និងបំពេញវិជ្ជា ដែលបានប្រព្រឹត្តិទៅ រយៈពេល ០២ថ្ងៃ គឺថ្ងៃទី០៦ និងថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

*សិក្ខាសាលាផ្សព្វផ្សាយស្ដីពី នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រោមអធិបតីភាព លោកជំទាវ ខុន នារី អនុរដ្ឋលេខាធិការ នៃក្រសួងផែនការ និង លោក យុង គឹមហ៊ាន អភិបាលរងខេត្ត ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣*










*ឯកឧត្តម ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត អគ្គនាយក អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ មេបញ្ជាការរងកងទ័ពជើងគោក ក្នុងពិធីសំណេះសំណាលសាកសួរសុខទុក្ខ និងចែកអាវរងារដល់កងកម្លាំងចំណុះទិសទី១ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣*


















ឯកឧត្តម គឹម រិទ្ធី អភិបាលខេត្ត កាត់ស្រោមសំបុត្រលទ្ធផលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នាសម័យប្រឡង ០៦ ខែវិច្ឆិកា ២០២៣ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣









ពិធីក្រុងពាលី សែនព្រេន សុំសេចក្ដីសុខ និងសំណេះសំណាលជាមួយក្រុមកីឡាករទូក"ង" ដែលត្រៀមនឹងចូលរួមប្រណាំងអុំទូកថ្នាក់ជាតិ ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក នៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣










ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តក្រោមប្រធានបទ «ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់» ក្នុងបរិវេណស្នងការដ្ឋាននគរបាលខេត្ត ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣









ពិធីបិទវគ្គហ្វឹកហ្វឺនបំប៉នការងារអប់រំចិត្តសាស្ត្រ និងជំនាញស្រាវជ្រាវបង្ក្រាបបទល្មើសប្រចាំឆមាសទី២ ឆ្នាំ២០២៣ របស់កងរាជអាវុធហត្ថខេត្ត ក្រោមអធិបតីឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣









រដ្ឋបាលខេត្តព្រះវិហារ រៀបចំពិធីដង្ហែក្បួនអបអរសាទរដល់ទូក «ង» ខេត្តព្រះវិហារ ដែលទទួលបានចំណាត់ថ្នាក់លេខ៣ ទូកតូពិសេសដែលមានល្បឿនលឿនជាងគេនៅទូទាំងប្រទេស ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត និងឯកឧត្តម ប្រាក់ សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ

ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងទិវាពិភពលោក ប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣ ក្រោមប្រធានបទ "សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍" នៅបរិវេណសាខាកាកបាទក្រហមកម្ពុជាខេត្ត ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣






ឯកឧត្តម សៀក សុជាតិ រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាអនុប្រធានគណៈកម្មការចំពោះកិច្ចរបស់រាជរដ្ឋាភិបាល បានដឹកនាំក្រុមការងារបើកកិច្ចប្រជុំពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញចូលរបស់ពលករខ្មែរតាមព្រំដែន ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣







# សកម្មភាពថ្នាក់ដឹកនាំ









សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធពិធីអុជធូបថ្វាយគ្រឿងសក្ការៈ និងបួងសួងសុំសេចក្តីសុខ សេចក្តីចម្រើន ជូនប្រទេសជាតិ និងប្រមុខដឹកនាំប្រទេសកម្ពុជា នៅព្រះអង្គចតុមុខ និងប្រាសាទដំរី នៃក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ ដែលមានទីតាំងស្ថិតនៅ ភូមិតាសែង ឃុំរណសិរ្ស ស្រុកសង្គមថ្មី ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣









# សកម្មភាពថ្នាក់ដឹកនាំ






ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត និងជាអនុប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាថ្នាក់កណ្តាល ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ស.ស.យ.កខេត្ត ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣






ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់រដ្ឋបាលខេត្ត ក្រោមអធិបតីភាព ឯកឧត្តម ប្រាក់ សុវណ្ណ ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

# សកម្មភាពថ្នាក់ដឹកនាំ









ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉ៅ សុផាន់ អគ្គមេបញ្ជាការរងកង យោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ ជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់រដ្ឋបាលខេត្ត ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣









# សួស្តីឆ្នាំថ្មី ឆ្នាំសកល 2024

សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល
វិបុលសុខ មហាប្រសើរ ជូនចំពោះ

## ឯកឧត្តម នេត្រ ភក្ត្រា

### រដ្ឋមន្ត្រីក្រសួងព័ត៌មាន



## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៤

សូម **ឯកឧត្តម និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារប្រកបដោយសុខភាពល្អបរិបូរណ៍
កម្លាំងមាំមួន ជន្មាយុយឺនយូរ ដើម្បីដឹកនាំក្រសួងព័ត៌មានឱ្យមានភាពរីកចម្រើន
ទទួលបានជោគជ័យបន្តទៅមុខទៀត និងសូមជួបតែពុទ្ធពរទាំងបួនប្រការ
គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមគោរពជូនពរពី**
**នាងខ្ញុំ ហែម សុគុណពិសី ប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ**
**ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់**

# សួស្តីឆ្នាំថ្មី ឆ្នាំសកល 2024

សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល
វិបុលសុខ មហាប្រសើរ ជូនចំពោះ

## ឯកឧត្តម ប្រាក់ សុវណ្ណ

### ប្រធានក្រុមប្រឹក្សា ខេត្តព្រះវិហារ



## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៤

សូម **ឯកឧត្តម** ទទួលបានសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន
ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ រួមចំណែកកសាង
និងអភិវឌ្ឍន៍ខេត្តព្រះវិហារ ឱ្យកាន់តែរីកចម្រើនថ្កុំថ្កើងថែមទៀត
សូម **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ជាទីស្រលាញ់
ជួបតែសុភមង្គល វិបុលសុខ និងសមប្រកបតែពុទ្ធពរទាំងបួនប្រការ
គឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពជូនពរពី**

**នាងខ្ញុំ ហែម សុគុណពិសី ប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ**
**ព្រមទាំងមន្ត្រីគ្រប់ជាន់ថ្នាក់**

# សួស្តីឆ្នាំថ្មី ឆ្នាំសកល 2024

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល
វិបុលសុខមហាប្រសើរ ជូនចំពោះ

## ឯកឧត្តម គីម រិទ្ធី

### អភិបាល នៃគណៈអភិបាល ខេត្តព្រះវិហារ



## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៤

សូម **ឯកឧត្តម** ទទួលបានសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន
ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ រួមចំណែកកសាង
និងអភិវឌ្ឍន៍ខេត្តព្រះវិហារ ឱ្យកាន់តែរីកចម្រើនថ្កុំថ្កើងថែមទៀត
សូម **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ជាទីស្រលាញ់
ជួបតែសុភមង្គល វិបុលសុខ និងសមប្រកបតែពុទ្ធពរទាំងបួនប្រការ
គឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពជូនពរពី**

**នាងខ្ញុំ ហែម សុគុណពិសី ប្រធានមន្ទីរព័ត៌មានខេត្តព្រះវិហារ**
**ព្រមទាំងមន្ត្រីគ្រប់ជាន់ថ្នាក់**





បណ្ណព័ត៌មាន ខេត្តព្រះវិហារ

បណ្ណព័ត៌មាន ខេត្តព្រះវិហារ



គណៈអធិបតីថតរូបអនុស្សាវរីយ៍



គណៈអធិបតីថតរូបអនុស្សាវរីយ៍





ទិដ្ឋភាពក្នុងពិធីសំណេះសំណាល



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ទិវាអន្តរជាតិ៨ មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ
# “ស្ត្រីរួមគ្នារក្សាសុខសន្តិភាពដើម្បីកិច្ចអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល”



*គណៈអធិបតីក្នុងពិធី*

នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ រដ្ឋបាលខេត្តព្រះវិហារ បានរៀបចំពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ"ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត និងលោកជំទាវ ឯកឧត្តម **ប្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត លោកជំទាវ **ចឹក ហេង** សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ៨ លោកជំទាវ **ហ៊ឿង ដារ័ត្ន សួសយ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ ព្រមទាំងមានវត្តមានចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការសាលាខេត្តជាច្រើនរូប ។

បន្ទាប់ពីបានស្តាប់ព្រះរាជសារ សម្តេចព្រះមហាក្សត្រីនរោត្តម **មុនិនាថ សីហនុ** ព្រះវររាជមាតា ជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលអានដោយលោកជំទាវ **ង៉ាន់ រ៉ាវី** អភិបាលរងខេត្តព្រះវិហារ ផ្ញើជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជារាស្ត្រទាំងអស់នៅក្នុងខេត្តព្រះវិហាររួចមក ឯកឧត្តម **គីម រិទ្ធី** មានមតិសំណេះសំណាលឲ្យដឹងថា ការប្រារព្ធពិធីអបអរសាទរខួបលើកទី១១២នៃទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ«ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍជាតិ ក្នុងយុគសម័យឌីជីថល» ក្នុងគោលបំណងរំលេចពីការចូលរួមចំណែកដ៏ចម្បងរបស់ស្ត្រី ក្នុងកិច្ចអភិវឌ្ឍន៍លើគ្រប់វិស័យ និងគ្រប់កាលៈទេសៈស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលចាត់ទុកស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ជាពិសេសសុខសន្តិភាពដែលកម្ពុជារកបានយ៉ាងលំបាក ក្នុងរយៈពេលកន្លងមក ។



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*

ឯកឧត្តមបន្តថា ស្ត្រីបានចូលរួមយ៉ាងច្រើននៅគ្រប់សកម្មភាព និងបានលើកតម្លៃស្ត្រី រួមទាំងសីលធម៌សង្គម វប្បធម៌និងប្រពៃណីដ៏ល្អផូរផង់របស់កម្ពុជា ក្នុងនោះក៏បានរួមចំណែកធ្វើឲ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ជាមួយនេះ ឯកឧត្តមក៏បានផ្តាំផ្ញើទៅដល់ថ្នាក់ដឹក នាំនិងមន្ត្រីរាជការទាំងអស់ ត្រូវបន្តរក្សាឲ្យបាននូវសុខសន្តិភាព និងបន្តគាំទ្រនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់តាមបែបវិមជ្ឈការនិងសហវិមជ្ឈការ ហើយបន្តផ្តល់សេវាសាធារណៈ និងខិតខំដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋអោយបានល្អបន្ថែមទៀត ៕


អ្នកចូលរួមក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍


គណៈអធិបតីថតរូបអនុស្សាវរីយ៍

# មហាសន្និបាតប្រចាំឆ្នាំ របស់សហគមន៍កសិកម្ម

សហគមន៍កសិកម្មលើកកម្ពស់កសិករ ស្ថិតនៅឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ បានប្រកាសពីភាពជោគជ័យរបស់ខ្លួនថាក្នុងឆ្នាំ២០២២ សហគមន៍មួយនេះរកប្រាក់ចំណេញបានជាង ៩៧លានរៀល ពីមុខរបរចម្បងរបស់ខ្លួនដូចជាការផ្តល់ឥណទានកសិកម្មខ្នាតតូច និងដាក់ប្រាក់សន្សំដល់សមាជិកសហគមន៍, ការផ្តល់សេវាកម្មទឹកស្អាត និងការទិញស្រូវ និងដំឡូងមីពីសមាជិកសម្រាប់ផ្គត់ផ្គង់ជូនក្រុមហ៊ុនដៃគូរ តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ។ នេះបើតាមការបញ្ជាក់ពីលោក **ឡៀប ចម** ប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម លើកកម្ពស់កសិករថ្លែងក្នុងមហាសន្និបាតប្រចាំឆ្នាំរបស់ខ្លួនដែលធ្វើឡើងនាព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ក្រោមអធិបតីភាពឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ។



ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត



គណៈអធិបតីប្រគល់ពូជដំឡូងសេរីវ៉ាង្គជូនសហគមន៍

លោក **ឡៀប ចម** បានបញ្ជាក់ឱ្យដឹងថា សហគមន៍កសិកម្មលើកកម្ពស់កសិករ ត្រូវបានចាប់បដិសន្ធិឡើងកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ចាប់ផ្តើមពីសមាជិកចំនួន ៩២នាក់ និងមានទុនដំបូងជាង ៦៨លានរៀលមកដល់ឆ្នាំ២០២២ សហគមន៍មានសមាជិកសរុបរហូតដល់ ៤៥៣នាក់ និងមានដើមទុនកើនដល់ប្រមាណជាង ២៦៨ លានរៀល ។ លោកថាក្នុងឆ្នាំ២០២២ សហគមន៍រកប្រាក់ចំណូលបានប្រមាណជាង២៤៦លានរៀលដោយបានផាត់ការចំណាយផ្សេងៗប្រមាណជាង ១៤៨លានរៀល ដោយនៅប្រាក់ចំណេញសុទ្ធជាង ៩៧លានរៀល ។

លោក **ពឹង ឡើជា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បានគូសបញ្ជាក់ថា តាមច្បាប់សហគមន៍កសិកម្ម បានចែងថាសហគមន៍កសិកម្មត្រូវតែរៀបចំធ្វើមហាសន្និបាតពេញអង្គយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដើម្បី

បង្ហាញសមិទ្ធផលរយៈពេលពេញមួយឆ្នាំរបស់ខ្លួន និងជាឱកាសមួយយ៉ាងសំខាន់ សម្រាប់ថ្នាក់ដឹកនាំសហគមន៍និងសមាជិកសហគមន៍ទាំងអស់ បានបញ្ចេញនូវមតិយោបល់នានា ព្រមទាំងបានបង្ហាញនូវចំណុចខ្លាំង ចំណុចខ្សោយរួមនិងផែនការទិសដៅផ្សេងៗ ដែលសហគមន៍ត្រូវធ្វើបន្ត។ ហើយមហាសន្និបាតថ្ងៃនេះទៀតសោតន៍ ក៏មានរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល នៃគណៈកម្មាធិការត្រួតពិនិត្យដើម្បីដឹកនាំបន្តសម្រាប់ឆ្នាំ២០២៣ ។

ក្នុងឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ បានសម្តែងការសប្បាយរីករាយ និងថ្លែងកោតសរសើរដល់សហគមន៍កសិកម្មលើកកម្ពស់កសិករ ដែលបានដឹកនាំគ្រប់គ្រង ប្រកបដោយស្មារតីសាមគ្គីភាពផ្ទៃក្នុងល្អធ្វើឱ្យសហគមន៍ទទួលបានការរីកចម្រើន គួរឱ្យចាប់អារម្មណ៍បំផុត ខណៈដែលពេញមួយឆ្នាំ ឆ្នាំ២០២២ សហគមន៍អាចរកប្រាក់ចំណេញបានរហូត ដល់ជិត១០០លានរៀល ដែលបានធ្វើឱ្យប្រសើរឡើង នូវការអភិវឌ្ឍន៍សហគមន៍កសិកម្មបង្កើនប្រាក់ចំណូលកសិករ សំដៅលើកកម្ពស់វិស័យកសិកម្មរួមចំណែកទ្រទ្រង់ខឿនសេដ្ឋកិច្ចជាតិ ដែលជាទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ៕



ប្រជាសហកមន៍ចូលរួមក្នុងពិធី



ប្រជាសហកមន៍ចូលរួមក្នុងពិធី



គណៈអធិបតីប្រគល់ក្រមាជូនប្រជាសហគមន៍

# ថៃចុះកិច្ចព្រមព្រៀង ស្តីពីការអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងការផ្គត់ផ្គង់ដំឡូងមី ជាមួយសហគមន៍ក្រុមអ្នកផលិតកសិកម្មក្នុងខេត្ត

នៅថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២៣ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈក្នុងភាពជាដៃគូធុរកិច្ច រវៀងសហគមន៍កសិករចំនួន៦ និងក្រុមហ៊ុន ហេងក្លាង ផាប់ប្លិក ខមផានី លីមីធីត ក្នុងការផ្គត់ផ្គង់នូវកសិផលដំណាំដំឡូងមី ក្រោមអធិបតីភាព លោក **ពឹង ទ្រីដា** ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ ដែលមានការចូលរួមពីសំណាក់តំណាងសហគមន៍ទាំង៦ តំណាងក្រុមហ៊ុនបញ្ជាទិញ និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត ។


លោក ពឹង ទ្រីដា ប្រធានមន្ទីរកសិកម្ម

តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈ ក្នុងភាពជាដៃគូកសិធុរកិច្ច រវាងសហគមន៍កសិកម្មទាំង៦ និងក្រុមហ៊ុនប្រមូលទិញនាពេលនេះ គឺជាការចាប់ផ្តើមមួយដ៏ល្អដោយ បានផ្តល់ប្រយោជន៍ជាច្រើនដល់ភាគីទាំងពីរ



គណៈអធិបតីក្នុងពិធី

ដូចជាការសាងទំនុកចិត្ត រវាងអ្នកផលិត និងអ្នកបញ្ជាទិញដោយធានានូវបរិមាណ និងគុណភាពដោះស្រាយបញ្ហាទីផ្សារដោយផលិតផល របស់កសិករមានដៃគូក្នុងការប្រមូលទិញបំពេញនូវតម្រូវការ និងការផ្គត់ផ្គង់ព្រមទាំងពង្រឹងពង្រីកខ្សែសង្វាក់តម្លៃទីផ្សារផលិតផលកសិកម្ម ។ ទាំងនេះពិតជាបានចូលរួមចំណែក ធ្វើឲ្យវិស័យកសិកម្មនៅក្នុងខេត្តព្រះវិហារ កាន់តែមានភាពរីកចំរើន និងបានជួយដល់កសិករក្នុងការខិតខំជំរុញការផលិត ឲ្យបានកាន់តែខ្លាំងក្លាថែមទៀត ។ មិនតែប៉ុណ្ណោះ ទាំងនេះក៏ជាយន្តការមួយដ៏សំខាន់ដើម្បីសម្រេចបាននូវគោលនយោបាយ ជំរុញផលិតកម្មស្បៀង និងការនាំចេញរបស់រាជរដ្ឋាភិបាលកម្ពុជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈ ការបង្កើនប្រាក់ចំណូលផ្ទាល់ដល់ក្រុមកសិករជាអ្នកផលិត ។

សូមបញ្ជាក់ថាក្រុមហ៊ុន ហេងក្លាង ផាប់ប្លិក ខមផានី លីមីធីត ជាក្រុមហ៊ុននាំចេញ នូវផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ បានចុះកិច្ចព្រមព្រៀងសាងភាពជាដៃគូអាជីវកម្ម ទៅលើដំណាំដំឡូងមី ជាមួយសហគមន៍កសិកម្មចំនួន៦ ក្នុងខេត្តព្រះវិហារសម្រាប់ឆ្នាំ ២០២៣ ក្នុងការប្រមូលទិញដំណាំដំឡូងមីស្ងួត ចំនួន៤៥០តោន និងដំឡូងមីសើមចំនួន ១០០០តោន ដើម្បីជាការចូលរួម ចំណែកក្នុងការ លើកកម្ពស់ខ្សែសង្វាក់តម្លៃកសិកម្ម ប្រកបដោយចីរភាព និងធ្វើយ៉ាងណាទ្រទ្រង់វិស័យនេះអោយមានភាពរីកចតម្រើនដោយផ្សារភ្ជាប់ តាំងពីការដាំដុះរហូតដល់ទីផ្សារលក់ចេញ ៕



ពិធីចុះកិច្ចសន្យា

ដែលកំពុងទទួលបាននូវការលើកកម្ពស់តួនាទីផលប្រយោជន៍ ការការ ពារសិទ្ធ និងត្រូវការជាចាំបាច់នូវការជួយឧបត្ថម គាំទ្រទាំងជីវភាព ស្មារតី និងសម្ភារៈពីគ្រប់មជ្ឈដ្ឋាន ។

ក្នុងឱកាសនោះ ឯកឧត្តម **សន សុផល** ក៏បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជានិច្ចជាកាល តែងតែផ្តល់នូវក្តីអាណិតស្រលាញ់ សណ្តោសប្រណី យកចិតទុកដាក់ និងគិតគូខ្ពស់អំពីសុខទុក្ខរបស់បងប្អូនជនមានពិការភាពគ្រប់ៗរូប ។ ឯកឧត្តម បានបន្តថា គិតចាប់ពីឆ្នាំ២០១៦ មកដល់បច្ចុប្បន្ននេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តល់របបគោលនយោបាយ ជនពិការភាពក្រីក្រនៅតាមសហគមន៍ទូទាំងរាជធានីខេត្ត សរុបចំនួន ១៩,៧៧២នាក់ ក្នុងនោះខេត្តព្រះវិហារ មានជនពិការភាពចំនួនប្រមាណ ៣០០០នាក់ ។ បន្ថែមពីនេះទៀត ក្រសួងសង្គមកិច្ចក៏បានកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហានានា ជូនជនមានពិការភាពប្រកបដោយប្រសិទ្ធភាពខ្ពស់ ជំរុញឲ្យសង្គមមួយ ដែលគ្មានឧបសគ្គសម្រាប់ជនមានពិការភាព ហើយអាចរស់នៅប្រកបដោយស្មើមុខមាត់គ្នា ដោយគ្មានការរើសអើងដូចប្រជាពលរដ្ឋទូទៅផងដែរ ៕



ឯកឧត្តម សន សុផល អគ្គនាយកស្តារសម្បទាន



លោកស្រី ប៉ាង រ៉ាវី អភិបាលរងខេត្ត



ឯកឧត្តម សន សុផល អគ្គនាយកស្តារសម្បទា

# ពិធីបើកការដ្ឋានសាងសង់ផ្លូវក្រាលកៅស៊ូ DBST មួយខ្សែប្រវែងជាង ២៤ គីឡូម៉ែត្រ ស្ថិតក្នុងស្រុកសង្គមថ្មី

កំណាត់ផ្លូវក្រាលក្រួសក្រហមមួយខ្សែ ពីឃុំចំរើន ទៅឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ប្រវែងជាង២៤ គីឡូម៉ែត្រ ត្រូវបានបើកការដ្ឋានសាងសង់ជាផ្លូវក្រាលកៅស៊ូ ពីរជាន់ប្រភេទ DBSTជាផ្លូវការហើយ នៅព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី **មាស សុភា** ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តព្រះវិហារ ដោយមានការចូលរួមពីសំណាក់ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ ព្រមទាំងថ្នាក់ដឹកនាំមន្ត្រីរាជការជាច្រើនរូបទៀត ។



គណៈអធិបតីក្នុងពិធី

នៅឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **មាស សុភា** បានថ្លែងពាំនាំនូវប្រសាសន៍ ផ្តាំផ្ញើរសាកសួរសុខទុក្ខដោយក្តីនឹករលឹក ពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត**ប៊ុន រ៉ានី ហ៊ុនសែន** ដែលជានិច្ចជាកាលសម្តេច ទាំងទ្វេតែងគិតគូរយកចិត្តទុកដាក់ចំពោះសុខទុក្ខ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ។ ឯកឧត្តមក៏បានថ្លែងទៀតថា ថ្ងៃនេះប្រជាពលរដ្ឋរស់នៅ ឃុំចំរើន និងឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ទទួលបាននូវសមិទ្ធិផលថ្មីមួយទៀត ដែលជាអំណោយរបស់រាជរដ្ឋាភិបាល ដែលបានផ្តល់ជូនសម្រាប់ប្រជាពលរដ្ឋនៅស្រុកសង្គមថ្មី ហើយការបើកការដ្ឋាននៅពេលនេះ គឺជាគម្រោងមួយ ក្នុងចំណោមគម្រោងដ៏ទៃផ្សេងៗជាច្រើនទៀត ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងបន្តការអភិវឌ្ឍន៍ ។




ភ្ញៀវកិត្តិយសចូលរួមក្នុងពិធី

ឯកឧត្តមទេសរដ្ឋមន្ត្រី **មាស សុភា** ក៏បានថ្លែងអំពាវនាវដល់ប្រជាពលរដ្ឋ ត្រូវចូលរួមថែរក្សាការពារផ្លូវនេះដើម្បីប្រើប្រាស់បានយូរអង្វែង និងត្រូវបន្តចូលរួមថែរក្សានូវសុខសន្តិភាពឱ្យនៅគង់វង្សយូរអង្វែង ដើម្បីឱ្យប្រទេសជាតិយើងបន្តការអភិវឌ្ឍន៍រីកចំរើនថែមទៀត ត្រូវគាំទ្រកម្មវិធីគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ពិសេសគោលនយោបាយភូមិ ឃុំ-មានសុវត្ថិភាព និងត្រូវទៅចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិតិកាលទី៧នៃរដ្ឋសភា នាខែកក្កដាខាងមុខឱ្យបានគ្រប់ៗគ្នា ៕



ភ្ញៀវកិត្តិយសចូលរួមក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍



គណៈអធិបតីក្នុងពិធី



ការដ្ឋានសាងសង់ផ្លូវ





អ្នកចូលរួមក្នុងកម្មវិធី

# សាខាកាកបាទក្រហមកម្ពុជាខេត្ត ចុះសួរសុខទុក្ខ និងនាំយកអំណោយ ចែកជូនដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់

ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **គីម រិទ្ធី** ប្រធានគណៈកម្មាធិការ សាខាកាកបាទក្រហមកម្ពុជាខេត្តព្រះវិហារ និងជាអភិបាលខេត្តរួមជាមួយក្រុមការងារបានចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ចែកជូនដល់ប្រជាពលរដ្ឋរងគ្រោះដោយសារខ្យល់កន្ត្រាក់ ចំនួន១៤០គ្រួសារ ស្ថិតក្នុងឃុំទាំង៦ ទូទាំងស្រុកគូលែន ដែលក្នុងនោះរងគ្រោះខូចខាតទាំងស្រុង ចំនួន ១១គ្រួសារ ខូចខាតមធ្យម ចំនួន ១២៩គ្រួសារ ហើយការចុះសួរសុខទុក្ខចែកចេញជាបីទីតាំងផ្សេងៗគ្នា ដែលទីតាំងទី១ ប្រព្រឹត្តទៅនៅក្នុងឃុំស្រយង់ ទី២នៅក្នុងឃុំគូលែនត្បូង និងទី៣ នៅឃុំថ្មី ។



គណៈអធិបតីក្នុងពិធី

មានមតិសំណេះសំណាលនាឱកាសនោះឯកឧត្តម **គីម រិទ្ធី** បានពាំនាំនូវប្រសាសន៍ ផ្តាំផ្ញើសាកសួរសុខទុក្ខពីសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដល់បងប្អូនប្រជាពលរដ្ឋដោយក្តីអាណិតអាសូរ និងសោកស្តាយជាទីបំផុតចំពោះឧប្បទ្ទវហេតុគ្រោះធម្មជាតិ ដែលបានបំផ្លាញនៅទ្រព្យសម្បត្តិរបស់បងប្អូនដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់នាពេលនេះ ព្រមទាំងបានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ សូមមានការប្រុងប្រយ័ត្នចំពោះផ្គររន្ទះ នៅពេលមានភ្លៀងត្រូវបិទទូរទស្សន៍ និងស្វែងរកកន្លែងដែលមានសុវត្ថិភាព ។ ឯកឧត្តមក៏បានបន្តទៀតថា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា សម្តេចតែងតែយកចិត្តទុក្ខដាក់គិតគូរ អំពីសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ពេលវេលា គ្រប់កាលៈទេសៈ ដោយមិនប្រកាន់និន្នាការនយោបាយបក្សពួកនិយមណាមួយនោះទេ ពោល"ទីណាមានទុក្ខទីនោះ មានកាកបាទក្រហមកម្ពុជា ហើយកាកបាទក្រហមកម្ពុជាសម្រាប់យើងគ្រប់ៗគ្នា" ។



គណៈអធិបតីក្នុងពិធី



ប្រតិភូអមដំណើរ

សម្ភារៈដែលបានផ្តល់ជូននាឱកាសនោះ រួមមាន ក្នុងមួយគ្រួសារៗទទួលបាន៖អង្ករ ២៥គីឡូក្រាម មី១កេស ត្រីខ១យួរ ទឹកស៊ីអ៊ីវ១យួរ និងថវិកាចំនួន ៥០,០០០រៀល ក្នុងនោះគ្រួសាររងគ្រោះខូចខាតទាំងស្រុង ទទួលបានតង់ចំនួន ១បន្ថែមទៀត ។ ប្រគេនព្រះសង្ឃនៅវត្តសុវណ្ណបុរីបញ្ញោ(ហៅវត្តគូលែនត្បូង) អង្ករ ៥០គីឡូក្រាម មី ២កេស ត្រីខ២យួរ ទឹកស៊ីអ៊ីវ២យួរ បច្ច័យចំនួន ២០០,០០០រៀល។ ជូនតាជីយាយជី ចំនួន ២៩នាក់ ម្នាក់ៗថវិកា ២០,០០០ រៀលផងដែរ ៕



គណៈអធិបតីក្នុងពិធី




ប្រជាពលរដ្ឋដែលរងគ្រោះដោយខ្យល់កន្ត្រាក់






ប្រជាពលរដ្ឋដែលរងគ្រោះដោយខ្យល់កន្ត្រាក់




ទិដ្ឋភាពក្នុងពិធី

# ពិធីបុណ្យពុទ្ធាភិសេកព្រះអង្គធំ និងសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តសុវណ្ណរស្មីភ្នំត្បែង (ហៅវត្តត្រាវគៀត)



លោក ណុប រិទ្ធី អភិបាលរងខេត្ត



គណៈអធិបតីក្នុងពិធី

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ លោក **ណុប ឫទ្ធី** អភិបាលរងខេត្ត បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យពុទ្ធាភិសេកព្រះអង្គធំ និងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសុវណ្ណរស្មីភ្នំត្បែង ហៅវត្តត្រាវគៀត ស្ថិតនៅភូមិត្រាវគៀត ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំមន្ទីរអង្គភាពជុំវិញខេត្ត និងពុទ្ធបរិស័ទជាច្រើនរូប ។

ក្នុងឱកាសនោះ លោក **ណុប ឫទ្ធី** បានកោតសរសើរដល់ព្រះចៅអធិការវត្ត និងព្រះសង្ឃគ្រប់ព្រះអង្គ ជាពិសេស ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា លោក លោកស្រី ជាពុទ្ធបរិស័ទទាំងអស់ដែលមានសទ្ធាជ្រះថ្លាក្នុងវិស័យពុទ្ធសាសនា ដែលបានលះបង់នូវថវិកាផ្ទាល់ខ្លួនចូលរួមកសាងនូវសមិទ្ធផលនានា ទុកជាកេរ្តិ៍មរតកសម្រាប់ព្រះពុទ្ធសាសនា និងបានជាប្រយោជន៍ដល់សាធារណៈជនទូទៅ ។

លោកក៏បានផ្តាំផ្ញើដល់ព្រះសង្ឃ សូមបន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងអភិបាលកិច្ច និងគោរពប្រតិបត្តិធម៌វិន័យ និងការចូលរួមការងារសង្គមជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអប់រំនូវសីលធម៌សង្គមឲ្យបានល្អផូរផង់ធានាបាននូវសាមគ្គីភាព នៅក្នុងជួរពុទ្ធសាសនិក ដែលជាប្រការដ៏សំខាន់បំផុត ។ លោកក៏បានលើកឡើងអំពីទំនាក់ទំនង ដែលមិនអាចខ្វះបានរវាងពុទ្ធចក្រ និងអាណាចក្រ ដែលបានរួមគ្នាយ៉ាងជិតស្និទ្ធ រក្សាក្តីសុខសាន្តជូនសង្គមជាតិ ហើយលោកក៏បានសុំឲ្យបន្តស្មារតីដឹងគុណនូវគោលនយោបាយ"ឈ្នះៈឈ្នះ" និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបាននូវសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ។

តាមរបាយការណ៍ ព្រះអង្គគ្រូ **តាំ ពិធូ** បានឲ្យដឹងថាសមិទ្ធផលសម្ពោធឆ្លងនាពេលនេះ មានសាលាឆាន់ខ្លោងទ្វា ពុទ្ធរូបទ្រង់បិណ្ឌបាត និងសមិទ្ធផលមួយចំនួនទៀតដែលបានកសាងចាប់តាំងពីឆ្នាំ២០១២មក ចំណាយថវិកាអស់ ២២៤,០០០ដុល្លា ដែលថវិកាទាំងអស់នេះបានមកពីសទ្ធាជ្រះថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីជាពុទ្ធបរិស័ទមកពីគ្រប់ទិសទី ៕



ព្រះអង្គធំពុទ្ធាភិសេក



ព្រះអង្គធំពុទ្ធាភិសេក



គណៈអធិបតីក្នុងពិធី



អ្នកចូលរួមក្នុងពិធី





អ្នកចូលរួមក្នុងពិធី

# អភិបាលខេត្តអញ្ជើញចុះជួបសំណេះសំណាល ជាមួយបងប្អូនកម្មករ កម្មការនី ប្រមាណជាង ២០០នាក់




គណៈអធិបតីក្នុងពិធី

ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត បានដឹកនាំក្រុមការងារអញ្ជើញជួបសំណេះសំណាលជាមួយកម្មករកម្មការនី ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ក្រោមប្រធានបទ "សន្តិភាព ស្ថិរភាព មុខរបរ និងការងារ" ដែល ពិធីនេះបានប្រព្រឹត្តទៅនៅចំណុច ក្រុមហ៊ុន **ទ្រី គាព** ក្នុងភូមិសាស្រ្តភូមិអូរពោធិ៍ ឃុំរម្មណីយ ស្រុករវៀង ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអភិបាលរងខេត្ត មន្ទីរអង្គភាព ពាក់ព័ន្ធ អាជ្ញាធរដែនដី និងបងប្អូនជាកម្មករ កម្មការនី ។



ប្រតិភូអមដំណើរ

យោងតាមរបាយការណ៍របស់លោក **ហេង ភួយ** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានឲ្យដឹងថាខេត្តព្រះវិហារគិតត្រឹមខែមេសា ឆ្នាំ២០២៣នេះ មានសហគ្រាស គ្រឹះស្ថានសរុបចំនួន ១១០កន្លែង ក្នុងនោះក្រុមហ៊ុនដែលបានចុះបញ្ជីនៅមន្ទីរ សរុបចំនួន ១០៤កន្លែង មានកម្មករនិយោជិតសរុប ២,៩៤៣នាក់ ក្នុងនោះកម្មករនិយោជិតជនជាតិខ្មែរ សរុបចំនួន ៣៣៨៣នាក់ ស្រីចំនួន ១២១៣នាក់ ។



ថ្លែងទៅកាន់បងប្អូនកម្មករនិយោជិតនាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានគូសបញ្ជាក់ថាប្រធានបទដែលយើងបានជួបជុំគ្នានៅថ្ងៃនេះ គឺពិតជាមានអត្ថន័យយ៉ាងជ្រាលជ្រៅបំផុត ខណៈពេលដែលសេដ្ឋកិច្ចពិភពលោកមានភាពមិនប្រាកដប្រជា ដោយមានការប្រែប្រួលដែលបង្កឡើងមួយផ្នែកដោយវិបត្តិកូវីដ-១៩ និងមួយផ្នែកទៀតបង្កឡើងដោយការប្រកួតប្រជែង ភូមិសាស្ត្រ នយោបាយ សង្គ្រាមពាណិជ្ជកម្ម ការប្រែប្រួលអាកាសធាតុ ការឡើងថ្លៃនៃថាមពល ការបង្កឡើងដោយសង្គ្រាមរុស្ស៊ី អ៊ុយក្រែន ការធ្លាក់ចុះផលិតភាព និងតម្រូវការសកល ដែលប៉ះពាល់ដល់សេដ្ឋកិច្ចការបាត់បង់ការងាររបស់កម្មករនិយោជិត ។ និយាយដោយឡែកសម្រាប់កម្ពុជា អាចរក្សាបាននូវលំនឹងសេដ្ឋកិច្ច អាជីវកម្ម ពាណិជ្ជកម្ម សន្តិភាព ស្ថិរភាពនយោបាយ និងមានការអភិវឌ្ឍន៍ រីកចម្រើនលើគ្រប់វិស័យ ជាពិសេសគឺវិស័យការងារ ។

ឯកឧត្តមបានបន្តថា ដោយផ្អែកលើរបាយការណ៍របស់ប្រធានមន្ទីរការងារ សម្រាប់ខេត្តព្រះវិហារ បានបង្ហាញឲ្យឃើញពីវឌ្ឍនភាព និងភាពរីកចម្រើនលើវិស័យការងារក្នុងការផ្តល់ ឱកាសការងារ ការគិតគូរ ដល់កម្មករ កម្មការនីនិយោជិត និយោជក ព្រមទាំងការបង្កលក្ខណៈសព្វបែបយ៉ាងសម្រាប់ វិនិយោគគិន ក្នុងការចូលមកវិនិយោគលើវិស័យសំខាន់ៗ ក្នុងខេត្តព្រះវិហារ ។ ជាមួយគ្នានេះរាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវកម្មវិធីកំណែទម្រង់ដ៏ស៊ីជម្រៅនិងកម្មវិធីនយោបាយនានា យុទ្ធសាស្ត្រចតុកោណដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឲ្យមានភាពរីកចម្រើន សម្រេចបាននូវចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជាជាប្រទេសមានចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ៕



ទិដ្ឋភាពក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# អាវភ្លៀងជាអំណោយរបស់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បាននាំយកទៅចែកជូនដល់កងកម្លាំងបណ្តាអង្គភាពទិសទី១

ថ្ងៃទី០៨ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ហ៊ុន ម៉ានី** តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាព ក្នុងពិធីចែកអាវភ្លៀង នឹងគ្រឿងឧបភោគ បរិភោគ ដល់កងកងកម្លាំងបណ្តាអង្គភាពទិសទី១ ប្រាសាទព្រះវិហារ ។ ពិធីនេះក៏មានការចូលរួមពីសំណាក់ ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ព្រមទាំងឯកឧត្តមមេបញ្ជាការ មេបញ្ជាការរង តំណាងអង្គភាពស្ថាប័ន នឹងកងកម្លាំងជាច្រើនរូបទៀត ដែលពិធីនេះធ្វើឡើងនៅទីបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។



ឯកឧត្តម ហ៊ុន ម៉ានី

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស្រី ឌឹក** មេបញ្ជាការកងពលធំអន្តរាគមន៍លេខ៣ បានលើកឡើងអំពីសភាពការណ៍ទូទៅ នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ-ឡាវ ដែលគណៈបញ្ជាការឯកភាពទិសទី១ ទទួលខុសត្រូវ រហូតមកដល់ពេលនេះហាក់មានសភាពស្ងប់ស្ងាត់ធម្មតា បើទោះបីកន្លងមកធ្លាប់មានសកម្មភាពមិនប្រក្រតីខ្លះៗ បានកើតឡើងយ៉ាងណាក្តី តែភាគីទាំងសងខាងបានព្យាយាមរួមគ្នាដោះស្រាយដោយសន្តិវិធី និងបញ្ចៀសបានរាល់សកម្មភាពទាំងឡាយណា ដែលនាំអោយឈានទៅរកការប្រឈមមុខគ្នាដោយប្រដាប់អាវុធ ។ ជាមួយនេះបណ្តាអង្គភាពជួរមុខទាំងអស់ បាននឹងកំពុងអនុវត្តបានយ៉ាងមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រសំខាន់ទាក់ទង នឹងបញ្ហាព្រំដែន បន្តអនុវត្តចក្ខុវិស័យប្រែក្លាយអតីតតំបន់ប្រយុទ្ធ មកជាតំបន់អភិវឌ្ឍន៍ ពីសមរភូមិទៅជាទីផ្សារ ពីស្នូរគ្រាប់កាំភ្លើងទៅជាកន្លែងសូត្រធម៌ ស្តាប់ភ្លេង ស្តាប់ចម្រៀង ពីតំបន់




គណៈអធិបតីក្នុងពិធី



*ឯកឧត្តម ហ៊ុន ម៉ានី តំណាងដ៏ខ្ពង់ខ្ពស់សម្តេចតេជោប្រគល់អំណោយដល់បណ្តាលអង្គភាព*

គ្រោះថ្នាក់ឲ្យទៅជាតំបន់ទេសចរណ៍ និងកសាងខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ឱ្យទៅជាខ្សែព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ។

មានមតិសំណេះសំណាលនាឱកាសនោះឯកឧត្តម **ហ៊ុន ម៉ានី** បានពាំនាំនូវការសួរសុខទុក្ខ និងសេចក្តីនឹករឭកពីសម្តេចទាំងទ្វេនិងថ្លែងអំណរគុណព្រមទាំងកោតសរសើរដល់កងកម្លាំងប្រដាប់អាវុធទាំងអស់ ដែលឈរជើងនៅតាមបន្ទាត់ព្រំដែន ហើយបានខិតខំបំពេញ ភារកិច្ចរបស់ខ្លួនជូនជាតិមាតុភូមិ ដោយបង្ហាញនូវភាពម៉ឺងម៉ាត់ក្នុងការថែរក្សា សន្តិសុខ សន្តិភាព ស្ថិរភាព ការពារបូរណភាពទឹកដី នឹងបានបន្តចូលរួមយ៉ាងសកម្ម ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋនៅក្នុងស្ថានការណ៍គ្រោះមហន្តរាយនានា ។

ឯកឧត្តមបន្តថា បើទោះបីកម្ពុជាកំពុងតែមានភាពសំបូរសប្បាយជាមួយការរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមក្តី ប៉ុន្តែសម្តេចទាំងទ្វេមិនដែលភ្លេចកងកម្លាំង ដែលឈរជើងនៅតាមបន្ទាត់ព្រំដែននោះទេ ដែលនេះជាការឆ្លុះបញ្ចាំងពីស្មារតីយកចិត្តទុកដាក់ខ្ពស់ចំពោះកងកម្លាំងប្រដាប់អាវុធ ដែលកំពុងឈរជើងយ៉ាងអង់អាចក្លាហាន ក្នុងកិច្ចការពារអធិបតេយ្យភាព បូរណភាពទឹកដី មាតុភូមិកម្ពុជានៃយើង ៕



*កងកម្លាំងការពារព្រំដែន*



*កងកម្លាំងការពារព្រំដែន*

# យុទ្ធនាការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់សហគមន៍ នៃតំបន់ការពារធម្មជាតិ

នៅថ្ងៃទី១០ខែឧសភាឆ្នាំ២០២៣នៅអគារសាលាខេត្តជាន់ទី៣មានរៀបចំកិច្ច ប្រជុំស្តីពីការប្រកាសក្រុមការងារដើម្បីអនុវត្តអនុក្រឹត្យ លេខ២៤៥ អនក្រ.បក និង បើក យុទ្ធនាការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់សហគមន៍ នៃតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ក្រោមអធិបតីភាពឯកឧត្តម **មាស សុភា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ ពិធីខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដែលពួកគាត់ទន្ទឹងរង់ចាំយូរមកហើយ ។ ឯកឧត្តមក៏បានឲ្យដឹងថាសម្រាប់ខេត្តព្រះវិហារ មានតំបន់សហគមន៍ដែលអាចកាត់ឆ្វៀលបានមានផ្ទៃដីប្រមាណជា៩៨.៣៦៣ ហិកតាគ្របដណ្តប់ លើ ៨ក្រុង/ស្រុកលើ៥១ ឃុំសង្កាត់ មានលក្ខណៈជាស្បែកខ្លា ។ ហើយរដ្ឋបាលខេត្ត បានបង្កើតក្រុមការងារ ដើម្បីអនុវត្តអនុក្រឹត្យ លេខ២៤៥ អនក្រ.បក ស្តីពីការកំណត់តំបន់




*គណៈអធិបតីក្នុងពិធី*

នេះ ក៏មានវត្តមានចូលរួមពីសំណាក់ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្តព្រះវិហារ ឯកឧត្តម **ច្រាក់ សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្ត ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត ថ្នាក់ដឹកនាំមន្ទីរអង្គភាពជុំវិញខេត្ត អភិបាលក្រុង/ស្រុកទាំង៨ កងកម្លាំងទាំង៣ និង មេឃុំ ចៅសង្កាត់ជាច្រើនរូប ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម **គីម រិទ្ធី** បានលើកឡើងថាការបើកយុទ្ធនាការ ចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ពិតជាមានសារៈសំខាន់




*អភិបាលខេត្ត និងអភិបាលរងខេត្តចូលរួមក្នុងពិធី*

សហគមន៍ក្នុងតំបន់ការពារធម្មជាតិ ដែលចែកចេញជាក្រុមការងារថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ក្រុង/ស្រុក ។ ក្រោយពីបានស្តាប់នូវសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារដើម្បីអនុវត្តអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងបទបង្ហាញស្តីពីអនុក្រឹត្យ លេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការកំណត់តំបន់សហគមន៍នៃ តំបន់ការពារធម្មជាតិដោយលោក ប្រធានមន្ទីរបរិស្ថាន និងបទបង្ហាញស្តីពី នីតិវិធីនៃការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋក្នុងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដោយលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ព្រមទាំងបានស្តាប់នូវមតិចូលរួម ពិភាក្សារបស់សមាជិកសមាជិកានៃអង្គប្រជុំរួចមក ឯកឧត្តម **មាស សុភា** ក៏បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទីភារកិច្ច របស់ខ្លួននាពេលកន្លងមក ។ ឯកឧត្តមក៏បានជំរុញបន្ថែមសុំអោយខិតខំប្រឹងប្រែងបន្តទៀត ជាពិសេសក្នុងការបើកយុទ្ធនាការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្រ្តខេត្តព្រះវិហារឲ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរ ៕



អ្នកចូលរួមក្នុងពិធី



អ្នកចូលរួមក្នុងពិធី



គណៈអធិបតីថតរូបអនុស្សាវរីយ៍

# ពិធីប្រគល់ ទទួល និងជូនដំណើរអដ្ឋិធាតុយុទ្ធជនពលីកងទ័ពស្ម័គ្រចិត្តវៀតណាម




គណៈអធិបតីក្នុងពិធី

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ស្ថិតនៅស្តូបគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន យុទ្ធនារី កម្ពុជា-វៀតណាម ស្ថិតនៅក្នុងភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ មានរៀបចំពិធីប្រគល់ ទទួល និងជូនដំណើរអដ្ឋិធាតុយុទ្ធជនពលីកងទ័ពស្ម័គ្រចិត្តវៀតណាម ធ្វើមាតុភូមិនិវត្តន៍លើកទី១៩ ក្រោមវត្តមាន លោក **អ៊ុង ឧុទ្ធី** អភិបាលរងខេត្ត និងលោកជំទាវ **ឡៀន ធីថាញ់ឡិច** អនុប្រធានគណៈកម្មាធិការ ប្រជាជនខេត្ត យ៉ាឡាយ និងជាប្រធានគណៈកម្មាធិការអដ្ឋិធាតុខេត្តយ៉ាឡាយ ដែលមានចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត កងកម្លាំងទាំង៣ ថ្នាក់ដឹកនាំមន្ទីរអង្គភាពនានាជុំវិញខេត្ត យុវជនកាយរិទ្ធ កាកបាទក្រហម លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងបងប្អូនប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ។

កម្មវិធីបានចាប់ផ្តើមឡើង ក្រោមការឡើងអុជធូប និងដាក់កម្រងផ្កាពីសំណាក់គណៈប្រតិភូ និងអង្គពិធីដែលបានចូលរួម ដើម្បីគោរពដល់វិញ្ញាណក្ខន្ធនៃអដ្ឋិធាតុទាំង ០៧រូប ដែលជាវីរយុទ្ធជន យុទ្ធនារីកងទ័ពស្ម័គ្រចិត្តវៀណាម ដែលបានពលីជីវិតក្នុងសម័យសង្គ្រាមនៅកម្ពុជា



អ្នកចូលរួមក្នុងពិធី





*លោក អ៊ុង វុទ្ធី អភិបាលរងខេត្ត*

ដែលបានរុករកដោយក្រុមការងារ k៥២ ក្នុងខេត្តព្រះវិហារ។

ថ្លែងក្នុងឱកាសនោះ លោក **អ៊ុំង វុទ្ធី** បានលើកឡើងថា ថ្ងៃនេះគឺជាលើកទី១៩ហើយ ដែលខេត្តព្រះវិហារជាមួយខេត្តយ៉ាឡាយបានសហការ ធ្វើពិធីប្រគល់ទទួល និងជូនដំណើរអដ្ឋិធាតុពលីកងទ័ពស្ម័គ្រចិត្តវៀតណាម លើភូមិសាស្ត្រខេត្តព្រះវិហារ ធ្វើមាតុភូមិនិវត្តន៍ សរុបទាំងអស់ចំនួន ៥១៦អដ្ឋិធាតុ ។ លោកបានបន្តថាក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ប្រជាពលរដ្ឋទូទាំងខេត្តព្រះវិហារ សូមសម្តែងនូវភាពសោកសៅ និងសោកស្តាយស្រណោះអាឡោះអាល័យពន់ពេកចំពោះយុទ្ធជន យុទ្ធនារី កម្មាភិបាល នៃវីរៈយុទ្ធជនកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានចូលរួមចំណែកយ៉ាងសកម្ម និងអង់អាចក្លាហានក្នុងការរំដោះប្រទេស និងប្រជាជនកម្ពុជា ចេញពីរបបយង់ឃ្នង ហើយបានពលីជីវិតនៅលើសមរភូមិ នៃទឹកដីខេត្តព្រះវិហារ ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល គុណូបការៈនេះហើយដែលធ្វើឲ្យថ្នាក់ដឹកនាំ ក៏ដូចជាប្រជាពលរដ្ឋកម្ពុជាសូមចូលរួមរំលែកនូវមហាទុក្ខ ដ៏ក្រៀមក្រំនេះ ជាមួយនិងប្រជាជនវៀតណាម ។ ផ្តើមចេញពីសហប្រតិបត្តិការរុករកអដ្ឋិធាតុនេះបានធ្វើឲ្យចំណង នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដែលជាប្រទេសភូមិផងព្រំដែនជាប់គ្នា កាន់តែរឹតចំណងសាមគ្គី រឹងមាំថែមទៀត និងបង្កើនកិច្ចទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពរវាងគ្នា និងគ្នាយូរអង្វែង ៕




*ពិធីចុះហត្ថលេខាប្រគល់ ទទួលអដ្ឋិធាតុ*




*គណៈអធិបតីថតរូបអនុស្សាវរីយ៍*

# រដ្ឋមន្ត្រីក្រសួងកសិកម្ម ចុះពិនិត្យវឌ្ឍនភាពការងារកសិកម្ម ក្នុងខេត្ត


ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម

ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាថ្ងៃទី២៤ និង២៥ ខែឧសភា ឆ្នាំ២០២៣ បានដឹកនាំប្រតិភូក្រសួងអញ្ជើញចុះពិនិត្យ និងវាយតម្លៃ អំពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ស្ថិតនៅឃុំរមទម ស្រុករវៀង និងស្នាក់ការសហភាព សហគមន៍កសិកម្មព្រះវិហារមានជ័យ ស្ថិតនៅសង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ។ ដែលក្នុងដំណើរទស្សនកិច្ចនាពេលនេះ ក៏មានវត្តមានអញ្ជើញចូលរួមពីសំណាក់ លោក **អ៊ុំ ឧុទ្ធី** អភិបាលរងខេត្ត ព្រមទាំងអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញពាក់ព័ន្ធជាច្រើនរូបទៀត ។ យោងតាមរបាយការណ៍របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ បានបង្ហាញថាសហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ មានសមាជិកសរុប ២៩៦នាក់ មានមុខ របរសំខាន់ៗចំនួន៨ រួមមានមុខរបរឥណទានកសិកម្មខ្នាតតូច, លក់តង់, លក់ធាតុចូលកសិកម្ម ទិញ-លក់ស្រូវសរីរាង្គដំឡូងមីក្រៀម និងស្វាយចន្ទីជាដើម។ ដោយឡែកសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ ជាសហភាពទី១ នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានចុះបញ្ជីទទួល ស្គាល់ដោយនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីឆ្នាំ២០១៦ ។ បច្ចុប្បន្នសហភាពមានសមាជិកសរុប ២៥សហគមន៍កសិកម្ម ស្មើនិង ៥,៤០៣គ្រួសារ ក្នុងនោះមានសមាជិកដែលជាអ្នកផលិតសរីរាង្គសរុប ៣,៧១៤គ្រួសារ ។សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ មានមុខរបរសំខាន់ៗចំនួន ០៥ រួមមានៈ មុខរបរសម្របសម្រួលទីផ្សារស្រូវសរីរាង្គ, ទីផ្សារសណ្តែកដីសរីរាង្គ, ផ្គត់ផ្គង់ធាតុចូលកសិកម្ម, កិនអង្ករសរី



គណៈអធិបតីក្នុងពិធី

រាង្គលក់ និងឥណទានរយៈពេលខ្លី ។

ក្នុងឱកាសនោះឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម បានបង្ហាញនូវចំណាប់ អារម្មណ៍ចំពោះខេត្តព្រះវិហារដែលមានសក្តានុពលក្នុងការធ្វើកសិកម្មសរីរាង្គ ហើយជាគោលដៅ នឹងរៀបចំខេត្តនេះឱ្យទៅជាខេត្តផលិតស្រូវសរីរាង្គ ដែលមានតម្លៃទីផ្សារខ្ពស់ និងងាយប្រកួតប្រជែងទីផ្សារ ។ ជាមួយនេះដោយសង្កេតឃើញពីសក្តានុពល និងមុខរបរសំខាន់ៗរបស់សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ឯកឧត្តមបានធ្វើការណែនាំដល់សហគមត្រូវធ្វើផែនការ ច្បាស់លាស់ក្នុងការចិញ្ចឹម និងដាំដុះរបរកសិករដើម្បីធានាការផ្គត់ផ្គង់តាមតម្រូវការទីផ្សារ ដោយធ្វើយ៉ាងណាចំណាយតិចចំណេញច្រើន។មួយវិញទៀតគម្រោងគួរលើក



ប្រតិភូអមដំណើរ



ប្រតិភូអមដំណើរ

ផែនការនិងថវិកា ផ្អែកលើតម្រូវការរបស់កសិករ និងខេត្ត ដើម្បីឱ្យការរៀបចំអនុវត្តត្រូវតាមគោលការណ៍ ។ ទន្ទឹមនឹងនេះក៏ត្រូវពិនិត្យលទ្ធភាពគ្រប់គ្រង និងប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាពសម្រាប់វិស័យកសិកម្ម ។

ជាមួយគ្នានេះដែរ ឯកឧត្តមរដ្ឋមន្ត្រីក៏បានណែនាំទៅដល់សហភាពសហគមន៍កសិកម្ម ព្រះវិហារមានជ័យ យកចិត្តទុកដាក់សិក្សាពីខ្សែសង្វាក់តម្លៃ និងត្រូវមានផែនការផលិតច្បាស់លាស់ ជំរុញការធ្វើស្រូវសរីរាង្គតាមរយៈការប្រើប្រាស់ពូជស្រូវសុទ្ធ ដើម្បីផលិតភាពខ្ពស់ គុណភាពល្អ តម្លៃល្អ និងងាយប្រកួតប្រជែង ។ ជាមួយគ្នានេះដែរត្រូវគិតគូរលើការវេចខ្ចប់ ឱ្យមានភាពទាក់ទាញបង្ហាញពីអត្តសញ្ញាណស្លាកយីហោអង្ករបស់យើង ៕



ពូជចន្ទីសរីរាង្គ

# ពិធីបិទបញ្ចប់វគ្គហ្វឹកហ្វឺនបំប៉នការងារការរក្សាសណ្តាប់ធ្នាប់ប្រចាំឆមាស ទី០១ ឆ្នាំ២០២៣



*ឯកឧត្តម គីម រិទ្ធី អភិបាលខេត្ត*

ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ នៅទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះវិហារ មានរៀបចំពិធីបិទបញ្ចប់វគ្គហ្វឹកហ្វឺនបំប៉នការងារការរក្សាសណ្តាប់ធ្នាប់ ប្រចាំឆមាសទី០១ ឆ្នាំ២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត និងជាប្រធានគណបញ្ជាការឯកភាពរដ្ឋបាលខេត្ត ។ ពិធីនេះក៏មានការចូលរួមពីសំណាក់មេបញ្ជាការ មេបញ្ជាការរង កងកម្លាំងទាំងបី លោក លោកស្រី ជាប្រធានមន្ទីរអង្គភាពពាក់ព័ន្ធជាច្រើនរូបទៀត ។

លោកឧត្តមសេនីយ៍ត្រី **កង សៅគុណា** មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះវិហារ បានថ្លែងថាការហ្វឹកហ្វឺននេះ ធ្វើឡើងក្នុងន័យលើកកម្ពស់សមត្ថភាពយល់ដឹងបន្ថែមអំពីតួនាទីភារកិច្ចលើការបំពេញបេសកកម្ម ទាំងចំណេះដឹង ចំណេះធ្វើ លើមុខវិជ្ជាយោធា មុខវិជ្ជាជំនាញអាវុធហត្ថដើម្បីឱ្យនាយទាហាន នាយទាហានរង កងរាជអាវុធហត្ថខេត្តព្រះវិហារ មានស្មារតីទទួលខុសត្រូវ គោរពច្បាប់ ក្រមសីលធម៌ គុណធម៌ មានមនសិកាការងារ និងអត្តចរិតស្លូតត្រង់ នឹងពង្រឹងសមត្ថភាពដឹកនាំបញ្ជា អនុវត្តន៍ច្បាប់ប្រកបទៅដោយប្រសិទ្ធភាព ។ លទ្ធផលទទួលបាន ជោគជ័យនាពេលនេះ ក៏ដោយសារមានការយកចិត្តទុកដាក់ចង្អុលបង្ហាញ និងឧបត្ថម្ភគាំទ្រពី សំណាក់ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសព្រមទាំង ឯកឧត្តម **គីម រិទ្ធី** អភិបាលខេត្ត ដែលតែងតែរំលឹកដាស់តឿន ជំរុញលើការងារ ហ្វឹកហ្វឺនជាប្រចាំ សំដៅធ្វើឱ្យកងកម្លាំងមានសមត្ថភាពក្នុងការដឹកនាំបញ្ជា អនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងសម្រេចបានជោគជ័យគ្រប់



*លោកឧត្តមសេនីយ៍ត្រី កង សៅគុណា មេបញ្ជាកងរាជអាវុធហត្ថខេត្ត*

ភារកិច្ច ។

ឯកឧត្តម **គីម រិទ្ធី** បានមានប្រសាសន៍ថា វគ្គហ្វឹកហ្វឺនក្នុងរយៈពេលជិត ១៥ថ្ងៃកន្លងមកនេះ ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ និងគុណតម្លៃបំផុតដល់ខឿនរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈទប់ស្កាត់រាល់បាតុភាពអនាធិបតេយ្យនានា ។ ទន្ទឹមនេះឯកឧត្តមក៏បានថ្លែងកោតសសើរ និងវាយតម្លៃខ្ពស់ពីការខិតខំបំពេញភារកិច្ចរបស់កងរាជអាវុធហត្ថខេត្តក្នុងការបង្ក្រាបបទល្មើសនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅធានាឱ្យកងកម្លាំងកងរាជអាវុធហត្ថមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តកាតព្វកិច្ចទទួលបានជោគជ័យជូនជាតិ និងមាតុភូមិ ។ បន្ថែមពីនេះ កម្លាំងកងរាជអាវុធហត្ថខេត្តត្រូវការពារឱ្យបាននូវសុខសន្តិភាព ដែលមានតម្លៃមិនអាចកាត់ថ្លៃបានបើទោះ



*គណៈអធិបតីក្នុងពិធី*